គឹម ពេជ្រពីនន់
KIM PICHPINUM

# អ្នកនិពន្ធរឿងល្ខោនល្បីៗ



# THE FAMOUS PLAYWRIGHTS

UNESCO
CAMBODIA

# អ្នកនិពន្ធរឿងល្ខោនល្បីៗ

ស្រាវជ្រាវ កែប្រែសំរួល និង រៀបរៀង

00003490

ដោយ

**គីម ពេជ្រពីរនន់**

**អនុបណ្ឌិតសិល្បៈ**

ព្រឹទ្ធបុរសរង មហាវិទ្យាល័យសិល្បៈនាដសាស្ត្រ
(សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ)

**ភ្នំពេញ ២០០២**

**រក្សាសិទ្ធិ**

# *The Famous Playwrights*

collected by

KIM PICHPINUN

Master of Arts

Vice Dean & Professor
Faculty of Choreographic Arts
( Royal University of Fine Arts )

**Phnom Penh 2002**

All rights reserved

## <u>មតិរបស់ឯកឧត្តមសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ</u>

កម្រងឯកសារស្ដីពីជីវប្រវត្តិ វណ្ណកម្ម និង ទស្សនៈអក្សរសិល្ប៍របស់អ្នកនិពន្ធរឿងល្ខោនល្បីៗ ដែលជាការខិតខំប្រឹងប្រែងរបស់លោកសាស្ត្រាចារ្យ **គីម ពីនន់** ព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យសិល្បៈនាដសាស្ត្រនេះ គឺជាស្នាដៃថ្មីមួយថែមទៀត នាដើមឆ្នាំ ២០០២ ឆ្លើយតបទៅតាមតំរូវការចាំបាច់នៃប្រព័ន្ធអប់រំថ្មីរបស់ប្រទេសជាតិ ដែលកំពុងទាមទារ និង ខ្វះចន្លោះ ។

ខ្ញុំយល់ថា សំរាវជ្រាវបែបនេះ មានសារៈសំខាន់ណាស់ សំរាប់ជួយបង្កើន នូវចំណេះដឹងទូលំទូលាយ ដល់សិស្ស និស្សិត នៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ និង គ្រឹះស្ថានសិក្សានានា ដែលកំពុងខ្វះខាតឯកសារជាភាសាជាតិអំពីអក្សរសិល្ប៍ សិល្បៈ ។ ក្នុងបណ្ដាចំណុចធំៗ ដែលលោកសាស្ត្រាចារ្យ **គីម ពីនន់** បានគាស់កកាយពីជើងមេឃលោកខាងលិច មកចងក្រងក្នុងសៀវភៅនេះ អ្វីដែលធ្វើឱ្យខ្ញុំមានចំណាប់អារម្មណ៍យ៉ាងរំភើបនោះគឺ :

- អំពីជីវប្រវត្តិប្លែកៗរបស់អ្នកនិពន្ធរឿងល្ខោនកំពូលៗ និង ល្បីល្បាញនៅលើសកលលោកគួរចងចាំ ។

- អំពីស្នាដៃតែងនិពន្ធ អត្ថបទរឿងល្ខោនរបស់លោកទាំងនោះគឺ : <u>**សិល្បៈ និង ការរស់នៅ**</u> ជារបស់តែមួយ ដែលមិនអាចផ្ដាច់ពីគ្នាបានឡើយ ។

- អំពីទស្សនៈអក្សរសិល្ប៍ ពោរពេញទៅដោយពាក្យពេចន៍ ល្បែងល្បិច គ្រប់សមាសភាពជីវិត ដូចជា រូបភាពរបស់ពាក្យ ព្រលឹងរបស់ពាក្យ តំលៃរបស់ពាក្យ សម្រស់របស់ពាក្យ ។ល។ គឺដូចគ្នាមែន ប៉ុន្តែខុសគ្នា នាំឱ្យអ្នកសិក្សាដក់ចិត្តជិតអារម្មណ៍ក្នុងនាមមនុស្សជាតិ គួរគោរព គួរស្ញើចសរសើរដូចជាលោក **ឌីស្ស៊ែម ស្ពេរស្ពៀរ** លោក **ម៉ូលីយែរ** លោក **ហ្សៀរ ករ័ណឺ** លោក **រ៉ាស៊ីន** និងលោក **អង់តូន ឆេគូស** ជាដើម ជាភ័ស្តុតាងយ៉ាងកក់ក្ដៅបំផុត ។ រាល់វណ្ណកម្មរបស់លោកល្បីៗទាំង ៥ រូបនេះ ត្រូវបានអ្នកសាងល្ខោននាដកម្មទូទៅក្នុងលោកទទួលយកទៅសំដែងផ្សព្វផ្សាយ តាមភាសាជាតិរបស់ខ្លួនយ៉ាងផុលផុស ។ ដោយឡែកសំរាប់ប្រទេសខ្មែរយើងនៅទសវត្ស ទី ៦០ ក៏មានភាពបែបនេះ យ៉ាងរស់រវើក គួរឱ្យមោទនៈក្រៃលែងផងដែរ ។

សំណុំឯកសារទាំងឡាយ ដែលបំរើឱ្យផ្នែកសិល្បៈអក្សរសិល្ប៍របស់លោកសាស្ត្រាចារ្យ **គីម ពីនន់** កន្លងមក និង ថ្មីៗដូចសៀវភៅ **អ្នកនិពន្ធរឿងល្ខោនល្បីៗ** នេះ ពិតជាមានអត្ថប្រយោជន៍យ៉ាងសំខាន់សំរាប់សេចក្ដីស្រេកឃ្លានរបស់យុវសិស្ស និស្សិតទូទៅ ពិសេសគឺសិស្ស និស្សិត នៃមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ ដែលកំពុងទន្ទឹងរង់ចាំយ៉ាងទទូចជាយូរមកហើយ ។

ជាថ្មីម្ដងទៀត ដោយក្ដីអំណរ និង ក្ដីសរសើរដោយស្មោះ ព្រោះទំរាំសំរេចកិច្ចការដុំកំភួននេះបាន លោកសាស្ត្រាចារ្យពិតជាបានរងនូវសម្ពាធពេលវេលាដ៏យូរ និង បានឆ្លងកាត់ទំហំហាត់នឿយច្រើនអន្លើ មិនអាចរកពាក្យណាមកកំណត់ស្មើបាន ។

រាជធានីភ្នំពេញ ថ្ងៃ ទី ៦ ខែ ធ្នូ ឆ្នាំ ២០០១

ទួយ កឿន

# អ្នកនិពន្ធរឿងល្ខោនល្បីៗ

| | | |
|---|---|---|
| អ្នកស្រាវជ្រាវ ប្រែសំរួល និង រៀបរៀង | = | គីម ពេជ្រពីរនន់ |
| រចនាក្របមុខតាមគំនិតអ្នកនិពន្ធ | = | អ៊ី វិសុទ្ធិ |
| វាយកុំព្យូទ័រ | = | គង់ ធុត្តា |
| បោះពុម្ពនៅរោងពុម្ព | = | រោងពុម្ពខ្មែរ |
| ទំហំ | = | ១៤.០៥ X ២០.០៥ |
| បោះពុម្ពលើកទី១ ចំនួន | = | ៥០០ ច្បាប់ |
| ឧបត្ថម្ភបោះពុម្ពដោយ | = | អង្គការយូណេស្កូ |

# សេចក្ដីសម្រេច

## របស់គណៈកម្មការរៀបចំកម្មវិធីសិក្សាអប់រំ

## នៃមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ

ក្រោយពីបានធ្វើការប្រជុំពិភាក្សា រវាងក្រុមសាស្ត្រាចារ្យ ទទួលបន្ទុករៀបចំកម្មវិធីសិក្សាអប់រំ នៃមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ ដោយមានការចូលរួមពីអង្គការ **យូណេស្កូ** ប្រចាំនៅកម្ពុជា គណៈកម្មការរៀបចំកម្មវិធីសិក្សាអប់រំ នៃមហាវិទ្យាល័យសិល្បៈនាដសាស្ត្របានសម្រេចជ្រើសរើសជាលើកដំបូង នូវកម្រងឯកសារសម្រាប់ជាជំនួយក្នុងការបង្រៀន និង រៀន ចំនួន ៤ ដែលមានចំណងជើងដូចខាងក្រោមនេះ :

១ - **សិល្បៈតែងកំណាព្យ** និពន្ធដោយ ឯកឧត្ដម **ពេជ្រ ទុំក្រវិល**

២ - **វិធីនិពន្ធរឿងល្ខោនខ្លីៗ** ដោយ លោកសាស្ត្រាចារ្យ **គីម ពេជ្រពិនុន**

៣ - **គំនិតមាសក្នុងអក្សរសិល្ប៍** ដោយ លោកសាស្ត្រាចារ្យ **គីម ពេជ្រពិនុន**

៤ - **ប្រវត្តិសិល្បៈខ្មែរ** ដោយ លោកសាស្ត្រាចារ្យ **សេង គីមលី**

គណៈកម្មការរៀបចំកម្មវិធីសិក្សាអប់រំ នៃមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ សូម រក្សាសិទ្ធិគ្រប់បែបយ៉ាង ។

**ជ. គណៈកម្មការ**

**ព្រឹទ្ធបុរស**



**ព្រឿង ឈៀង**

# សេចក្ដីផ្ដើម

នៅសម័យមុន អ្នកកសាងរឿងល្ខោននាដកម្ម ទោះទាំងអ្នកនិពន្ធក្ដី អ្នកដឹករឿងក្ដី ត្រូវបានបណ្ដាប្រទេសមួយចំនួន គេចាត់ទុកថា ជាជនក្រៅសង្គម ដោយគេចោទថា ពួកអ្នកទាំងនេះជាអ្នកគ្មានសីលធម៌ ក្បត់សីលធម៌ យកសាច់ឈាម យករូបរាងកាយ យកកេរ្ដិ៍ខ្មាសមនុស្ស យកកិច្ចកលក្នុងសង្គម មកលាតត្រដាង មកសំដិលមកបើកបង្ហាញជាសាធារណៈឱ្យគេឯងគ្រប់គ្នាឃើញ ដឹងលឺ គ្មានសល់ចន្លោះ.... ។

អ្នកដែលមានកេរ្ដិ៍ខ្មាស ប៉ះពាល់ដល់កិត្តិយស ប៉ះពាល់ដល់លាភសក្ការ បាននាំគ្នាបរិហារ ថ្កោលទោសសិល្បករល្ខោននាដកម្មយ៉ាងគ្មានប្រណី ដើម្បីកុំឱ្យពួកល្ខោនដឹកកាប់គាស់ បើកកកាយហែកហួរ លើកយករឿងស្ងាត់កំបាំងរបស់មនុស្ស របស់សង្គម មកសំដែង មកបកស្រាយ នាំឱ្យរាលដាល នាំឱ្យក្លាយជាដំបៅមហារីកបង្កជាបាតុភាពសង្គម ?... តទៅទៀតបាន ។ គេធ្វើយ៉ាងនេះ គ្មានអ្វីក្រៅពីចង់លាក់បិទបាំងនូវអំពើខ្មៅក្រខ្វក់ អំពើពុករលួយ អំពើ

ទុយ៌ស អំពើអយុត្តិធម៌ អំពើពាល កំណាច ឫស្សា ។ល។ និង ។ល។ របស់ពួកគេតែប៉ុណ្ណោះ ។

លោកនីកូស នៅពេលដែលខឹងសម្បារនឹងលោក រ៉ាស៊ីន បាន ធ្វើលិខិតបន្តុះបន្ទាប់ និងជេរប្រមាថមួយច្បាប់ ដែលមានសេចក្តីថា ពួកអ្នកសរសេរប្រលោមលោក និងអត្ថបទល្ខោន សុទ្ធតែជាអ្នក បំពុលមហាជន និង សាសនិកទាំងអស់ ហើយមិនមែនបំពុលតែ ត្រឹមផ្លូវកាយទេ ប៉ុន្តែបំពុលទាំងផ្លូវចិត្តទៀតផង ។

ពេលនោះដោយអត់ទ្រាំទៀតមិនបាន លោករ៉ាស៊ីន ក៏បានសរ សេរសំបុត្រមួយតបទៅវិញ ដែលមានសេចក្តីថា : តើលោកអាច ប្រើពាក្យឱ្យបានគួរសមជាងពាក្យថា បំពុលមហាជនបានទេ ?

លោកនីកូល មិនបានស្ងប់កំហឹងនេះទេ មិនតែប៉ុណ្ណោះ លោក ថែមទាំងបានចោទថា អ្នកនិពន្ធរឿងល្ខោនទាំងឡាយ សុទ្ធតែជា មនុស្សអាក្រក់ ។

តាមពិតទៅ ការផ្សាយចំណេះដឹងតាមរយៈល្ខោនទាដកម្មពិត ជាមធ្យោបាយមួយដ៏ប្រសើរ ធ្វើឱ្យមនុស្សបានយល់ដឹងកាន់តែច្បាស់ អំពីសង្គម និងបានជាជំនួយផ្នែកសតិអារម្មណ៍ បង្កើនបាននូវកំលាំង ប្រាជ្ញា ស្មារតីកាន់តែខ្ពស់ ដើម្បីរស់នៅឱ្យបានប្រសើរក្នុងសង្គម ។

ព្រោះថា តាមរយៈសិល្បៈល្ខោននាដកម្ម មនុស្សនឹងស្គាល់បាននូវតំលៃពិត មានគំនិតទូលាយ មិនចង្អៀតចង្អល់ ផ្តល់នូវសុភវិនិច្ឆ័យមិនលំអៀង ស្គាល់គុណ ស្គាល់ទោស អាក្រក់ល្អ សខ្មៅ... ទប់ស្កាត់បាននូវចិត្តមានះ រឹងត្អឹង ចិត្តព្រហើនកោងកាច ហ៊ានប្រព្រឹត្តបាបកម្ម ឧក្រិដ្ឋកម្មគ្រប់បែបយ៉ាង ដែលគេតែងតែយល់ថា អំពើអាក្រក់ទាំងអស់នោះ ជាអំពើល្អ ជាអំពើត្រូវ ជាផលបុណ្យ ជាសំណាងដែលគេមានឱកាសក្នុងការគ្រប់គ្រង ដើម្បីប្រព្រឹត្តអំពើពុករលួយកេងប្រវ័ញ្ច លួចជាតិ បំផ្លាញជាតិ... ហើយដែលយូរៗទៅ ពិភពនេះនឹងក្លាយទៅជាលោកមួយ ដែលសំបូរតែមនុស្សឥតសីលធម៌រស់នៅទៅវិញ ។

ក្នុងចំណោមអ្នកនិពន្ធរឿងល្ខោនល្បីៗ ដូចជាលោករ៉ាស៊ីន លោកម៉ូលីយែរ ជាដើម លោកសុទ្ធតែបានប្រឆាំងនឹងគំនិតយល់ខុសទាំងប៉ុន្មានខាងលើដែលថា ពួកអ្នកកសាងរឿងល្ខោន គឺជាអ្នកក្បត់សីលធម៌ ។

ជាទូទៅ អ្នកនិពន្ធរឿងល្ខោនទាំងឡាយ មិនបានដាក់ខ្លួនប្រឆាំងនឹងមនុស្សជាតិទេ ផ្ទុយទៅវិញគឺស្រឡាញ់មនុស្ស ដើម្បីធ្វើឱ្យមនុស្សកាន់តែបានប្រសើរឡើង ។ ឧទាហរណ៍លោក ម៉ូលីយែរ ខំ

ប្រឹងតស៊ូពុះពារគ្រប់ឧបសគ្គសព្វបែបយ៉ាង ដើម្បីបំរើល្ខោន ។ លោកបាននៅអែបនឹងស្តេច ដើម្បីឆ្លៀតសរសេររឿងល្ខោន រិះគន់ពួកដៃជើងដែលនៅជុំវិញស្តេច ។ លោករិះគន់អ្នកប្រាជ្ញដែលឡើងជំនោរខុសរបៀប រិះគន់ពួកអាចារ្យផ្ទៃល្វា ដែលស្អាតបរិសុទ្ធតែសំបកក្រៅ តែចិត្តខាងក្នុងជាចោរ រិះគន់អ្នកត្រកូលទាប តូចតាចចង់បានប្រពន្ធត្រកូលខ្ពស់ រិះគន់ជនកំណាញ់ក្រៅតម្រា រិះគន់តាអាចារ្យ ចង់បានប្រពន្ធក្មេង ។ល។ និង ។ល។

អង្គរឿងល្ខោនកំប្លែងរបស់លោក ម៉ូលីយែរ បានឆ្លុះបញ្ចាំងហើយផ្ដិតយកនូវកំហុសឆ្គង ទំនាស់ វិបត្តិទាំងឡាយរបស់មនុស្សរបស់សង្គម ឱ្យអ្នកផងមើលឃើញ ឱ្យសើចសប្បាយ ឱ្យរីករាយនឹងអាកប្បកិរិយាលាក់ពុត ពុករលួយ កេងប្រវ័ញ្ច អំនួតក្អេងក្អាងរបស់មនុស្សខ្លួនឯង ។ អ្នកខ្លះមើលគ្រាន់តែដើម្បីកែកំសាន្ត អ្នកខ្លះសើចដោយមិនបានពិចារណា អ្នកខ្លះយល់ថា រឿងល្ខោនរបស់លោក ម៉ូលីយែរ សុទ្ធតែបានឆ្លុះបញ្ចាំងនូវការពិតក្នុងសង្គមហួសហេតុពេកមើលហើយគួរឱ្យអស់សំណើច សើចទាំងទឹកភ្នែក ព្រោះអាណិតដល់ជីវិតពិតប្រាកដរបស់មនុស្ស ដែលតាមពិតទៅគ្មានអ្វីគួរឱ្យសើចសប្បាយសោះ ។ រីឯមនុស្សខ្លះទៀតយល់ថា រឿងល្ខោនរបស់លោក

ម៉ូលីយែរ គឺធ្វើឱ្យគេសើចសប្បាយយ៉ាងសប្បាយអស្ចារ្យក្រៃលែង ក៏ប៉ុន្តែការសើចសប្បាយរីករាយដ៏ក្រៃលែងនោះ គឺមានរសជាតិល្វីងជូរចត់ជាទីបំផុត ។ បើគេរឹតតែគិត រឹតតែពិចារណាឱ្យបានខ្លាំងក្លាក្នុងឱកាសដែលគេកំពុងទស្សនា និងក្រោយការទស្សនារឿងល្ខោនរបស់លោក ម៉ូលីយែរ នោះ គេក៏រឹតតែដឹងខ្លួនខ្លាំងឡើងៗណាស់ដែរថា លោក ម៉ូលីយែរកំពុងតែ "ខោកក្បាល" ឱ្យពួកគេទេតើ !!!

សរុបមក មិនថាតែរឿងល្ខោនរបស់លោក ម៉ូលីយែរប៉ុណ្ណោះទេ គឺស្ទើរតែគ្រប់ស្នាដៃនិពន្ធរបស់អ្នកនិពន្ធរឿងល្ខោនទាំងអស់សុទ្ធតែមានតំលៃចំពោះមនុស្សជាតិ ឆ្លុះបញ្ចាំងពីបញ្ហាសង្គមមនុស្សបំរើមនុស្ស ធ្វើឱ្យមនុស្សទូទៅមើលឃើញនូវពិភពលោកទាំងមូលដោយឥតប្រកែកបាន ។ អ្នកនិពន្ធរឿងល្ខោនទាំងអស់ សុទ្ធតែបានចំណាយពេលវេលាមិនច្រើនក៏តិច ព្យាយាម តស៊ូយ៉ាងស្វិតស្វាញមោះមុត ស្វះស្វែង ស្រាវជ្រាវ រាវរកនូវរសជាតិថ្មី បច្ចេកទេសថ្មីប្លែក ទាំងការនិពន្ធ ទាំងការដឹករឿង និងទាំងការសំដែង ដើម្បីបំរើជូនទស្សនិកជន ។ អ្នកនិពន្ធរឿងល្ខោនខ្លះបានចំណាយទ្រព្យសម្បត្តិផ្ទាល់ខ្លួនអស់គ្មានសល់ ហើយខ្លះទៀតរហូតដល់ជាប់គុក ដោយជំពាក់ប្រាក់គេ ឬក៏មកពីបញ្ហាផ្សេងៗ ដែលជាដើមហេតុចេញមកពី

"ការពិត" ព្រោះថា អ្នកនិពន្ធរឿងល្ខោនជាអ្នកចូលចិត្តសរសេរពីការពិត និយាយការពិត ហើយការពិត តាមពិតទៅវាតែងតែប៉ះពាល់ដោយចៀសមិនផុត ( La vérité est touche ) ។

អ្នករៀបរៀង

# ជំរាបជូនមិត្តអ្នកអាន....

សៀវភៅ អ្នកនិពន្ធរឿងល្ខោនល្បីៗ នេះ បានប្រមូលផ្តុំនូវជីវប្រវត្តិសង្ខេប របស់អ្នកនិពន្ធរឿងល្ខោនចំនួន ៥៨ រូបនៅលើពិភពលោក ។

ក្នុងចំណោមនេះ ខ្ញុំបានជ្រើសរើសយកតែអ្នកនិពន្ធរឿងល្ខោនចំនួន ៥ រូបប៉ុណ្ណោះ គឺលោក Shakespeare លោក Molière លោក Racine លោក Corneille និងលោក Tchekhov មកធ្វើការបកស្រាយយ៉ាងលំអិតបង្គួរ ទៅលើចំណុចសំខាន់បីធំៗ គឺ : ១-ជីវប្រវត្តិ ២-វណ្ណកម្ម (ស្នាដៃ) និង ៣-ទស្សនៈអក្សរសិល្ប៍ ។

ខ្ញុំសូមក្តីអធ្យាស្រ័យ ខន្តីអភ័យទោស នូវរាល់ចំណុចខ្វះខាតទាំងឡាយ ដែលកើតមានឡើងក្នុងសៀវភៅនេះ ពីសំណាក់មិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន ជាពិសេសលោកគ្រូ អ្នកគ្រូ លោកសាស្ត្រាចារ្យ លោកបណ្ឌិត អ្នកស្រាវជ្រាវ ដែលមានចំណេះដឹងខ្ពស់ លើវិស័យសិល្បៈវប្បធម៌ អក្សរសាស្ត្រជាតិ និងអន្តរជាតិ ។

**គឹម ពេជ្រពីរនន់**

# មាតិកា

ទំព័រ

- អ្នកនិពន្ធរឿងល្ខោនក្នុងប្រវត្តិសាស្ត្រ...... 17

**ក្រិកបុរាណ** ...... 23

-Eschyle...... 24

-Sophocle...... 25

-Euripide...... 26

-Aristophane...... 27

**រ៉ូមបុរាណ**...... 29

- Plautus...... 30

- Térence...... 31

**អេស្ប៉ាញ (យុគមាស)**...... 32

- Calderon...... 33

- Lope de Vege...... 34

**អង់គ្លេស**...... 35

- Christopher Marlowe...... 36

- William Shakespeare...... 37

- Ben Jonson...... 51

**បារាំង**...... 52

- Pierre Corneille...... 53

- Molière...... 76

- Jean Racine...... 95

**អង់គ្លេស ស.វ ទី ១៨**...... 114

- William Wycherley...... 115

- William Congreve...... 116

- Oliver Goldsmith........................................................ 117
- John Gay.................................................................. 118
- Richard Sheridan........................................................ 119

អាល្លឺម៉ង់ ស.វ ទី ១៨........................................................ 120

- Johann Goethe........................................................... 121
- Friedrich Shiller......................................................... 123
- Heinrich von Kleist...................................................... 125

បារាំង ស.វ ទី ១៩............................................................ 126

- Eugène Labiche.......................................................... 127
- Victor Hugo............................................................... 128
- Alfred de Musset......................................................... 131

ស្កង់ឌីណាវីយ៉ា ស.វ ទី ១៩.................................................... 133

- Henrik Ibsen ............................................................. 134
- August Strindburg....................................................... 135

រុស្ស៊ី ស.វ ទី ១៩............................................................. 137

- Nikolai Gogol............................................................. 138
- Ivan Turgenev............................................................ 139
- Anton Tchekhov......................................................... 140
- Maxim Gorki.............................................................. 151

អាល្លឺម៉ង់ ស.វ ទី ១៩........................................................ 152

- Georg Buechner.......................................................... 153
- Friedrich Hebbel......................................................... 154
- Richard Wagner.......................................................... 155
- Gerhart Hauptmann..................................................... 157

ល្ខោនសម័យទំនើប អង់គ្លេស និង អៀរឡង់ដ៍........................................ 158

- Oscar Wilde............................................................... 159
- Georg Bernard Shaw.................................................... 160
- William Butler Yeats.................................................... 161
- Jhon Millington Synge.................................................. 162
- Sean O'Casey............................................................. 163

- John Osborne........................................................................ 164
- Harold Pinter........................................................................ 165
ល្ខោនសម័យទំនើប អាល្លឺម៉ង់ និង ស្វ៊ីតហ្ស៊ែរឡង់............................166
- Frank Wedekind.................................................................... 167
- Bertolt Brecht........................................................................ 168
- Max Frisch............................................................................. 170
- Friedrich Duerrenmatt............................................................171
ល្ខោនសម័យទំនើប អ៊ីតាលី និង អេស្ប៉ាញ.................................... 172
- Luigi Pirandello...................................................................... 173
- Federico Garcia Lorca............................................................ 174
ល្ខោនសម័យទំនើប បារាំង................................................................. 175
- Michel de Ghelderode............................................................ 176
- Jean- Paul Sartre..................................................................... 177
- Samuel Beckette..................................................................... 180
- Jean Genet..............................................................................181
- Jean Anouilh........................................................................... 182
- Eugène Ionesco.......................................................................183
ល្ខោនសម័យទំនើប អាមេរិក.............................................................. 184
- Eugene O’Neill....................................................................... 185
- Thornton Wilder.....................................................................186
- Tennessee Williams................................................................187
- Arthur Miller..........................................................................188

# អ្នកនិពន្ធរឿងល្ខោនក្នុងប្រវត្តិសាស្ត្រ

អ្នកនិពន្ធរឿងល្ខោននាដកម្មជាច្រើនរូបបានឯកភាពគ្នាថាៈ"ភារកិច្ចរបស់អ្នកនិពន្ធរឿងល្ខោន ជានិច្ចជាកាលគឺត្រូវបង្កើតឱ្យមានឡើងនូវនាដកថា ( script ) ។ នេះគឺជាបញ្ហាដ៏ចំបងនៃពាក្យនិយាយដែលតាមរយៈភាសាផ្តល់មកនូវការកំណត់ន័យ និង ចង្វាក់ទាក់ទងទៅនឹងពិភពល្ខោននាដកម្ម ។

ហេតុដូច្នេះហើយ ទើបធម្មជាតិនៃភារកិច្ច និង សារៈសំខាន់នៃតួនាទីរបស់អ្នកនិពន្ធរឿងល្ខោននៅក្នុងល្ខោនមានច្រើនបែបច្រើនយ៉ាង ។

ខាងក្រោមនេះ គឺជាប្រវត្តិនៃការវិវត្តន៍របស់អ្នកនិពន្ធរឿងល្ខោនដែលយើងសូមលើកយកមកសង្ខេបខ្លីៗទៅតាមសម័យកាលនីមួយៗ ៈ

**<u>សម័យក្រិកបុរាណ</u>** ( IN THE CLASSICAL GREECES )

ក្នុងសម័យនេះ អ្នកនិពន្ធរឿងល្ខោនគឺជារូបតំណាងដ៏ចំបងនៅក្នុងវង់ល្ខោន ។ អ្នកនិពន្ធរឿងល្ខោនទាំងឡាយ គេបានសរសេររឿងល្ខោនផងដឹកនាំសិល្បករ អ្នកចំរៀង អ្នករបាំ ហើយនិងរៀបចំចាត់ចែងការងារជាលំអិត ក្នុងការផលិតទស្សនីយភាពផង ដែលកាលនោះសំដែងឡើងនៅពេល

"មហោស្រពឌីយោនីសូស " ( Festivals of Dionysus ) ដែលជាផ្នែកមួយនៃការធ្វើពិធីរបស់ប្រជាពលរដ្ឋ និង សាសនា ។

## សម័យកណ្តាល ( IN THE MIDDLE AGES )

នៅក្នុងសម័យកណ្តាលនេះ ល្ខោនបានដើរតួជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងជីវិតសង្គម ហើយប្រធានរឿងរបស់ល្ខោនគឺបានផ្សាភ្ជាប់ទៅនឹងវិហារសាសនា ។ អ្នកនិពន្ធរឿងល្ខោនទាំងឡាយ គឺជាអ្នកនិពន្ធអានាមិក ។ រឿងល្ខោនទាំងឡាយសរសេរឡើងដោយពួកអ្នកបួសគ្រិស្ត ( clerqy ) ដោយសមាជិកសមាគមអាជីពដ៏ល្បាញល្បីវៃឆ្លាត ដែលជាតំណាងរបស់ពួកគេ ហើយដែលសុទ្ធសឹងតែជាសិល្បករស្រាប់ សំដែងសំរាប់ការអប់រំ និងការកំសាន្តឱ្យបានដល់អ្នកស្តាប់ អ្នកទស្សនា មហាជនដែលមិនចេះអក្សរ ។

## សម័យអេលីហ្សាបេតអង់គ្លេស ( IN ELIZABETHAN ENGLAND )

ក្នុងសម័យនេះ ល្ខោនបានក្លាយមកជាឧបករណ៍ដ៏ធំទូលាយ បំរើឱ្យដោយចំពោះខាងផ្លូវលោក ហើយជាថ្មីម្តងទៀត អ្នកនិពន្ធរឿងល្ខោនម្នាក់ៗក៏សុទ្ធតែជាបុគ្គលដ៏សំខាន់បំផុតនៅក្នុងវង់ល្ខោនផងដែរ ។ ក្រុមសិល្បករបានត្រូវឧបត្ថម្ភឡើងដោយព្រះមហាក្សត្រ ( monarch ) ឬក៏ជន

ដែលមានឥទ្ធិពល និងដ៏ល្បីឈ្មោះណាម្នាក់ ហើយដែលនៅពេលនោះគេឱ្យទៅសំដែងនៅក្នុងរោងល្ខោនផ្ទាល់របស់ពួកអ្នកដែលមានឥទ្ធិពលនោះតែម្តង ។ អ្នកនិពន្ធរឿងល្ខោន គឺជាផ្នែកមួយដ៏សំខាន់របស់បរិស័ទ ( company ) ទាំងនេះ ។ អ្នកនិពន្ធរឿងល្ខោនជួនកាលក៏ជាអ្នកចូលរួមសំដែងផងដែរ ហើយពួកគេទាំងនោះ ច្រើនតែជាអ្នកមានតំណែងកិត្តិយសខ្ពង់ខ្ពស់ និង មានជីវភាពរស់នៅក្នុងព្រះបរមរាជវាំង ។

## សម័យសតវត្សរ៍ ១៧ បារាំង និង អេស្ប៉ាញ

( IN SEVENTEENTH CENTURY FRANCE AND SPAIN )

ក្នុងសម័យស.វទី ១៧ នេះ អ្នកនិពន្ធរឿងល្ខោនមានការឧបត្ថម្ភពីសំណាក់ព្រះរាជា ។ នៅក្នុងឱកាសខ្លះ អ្នកនិពន្ធរឿងល្ខោនបាននាំមុខបរិស័ទផ្ទាល់របស់ខ្លួន ឧទាហរណ៍ដូចជាលោកម៉ូលីយែរ ( Molière ) និងលោក ឡូប៉េ ដឺវេហ្គា ការពីយ៉ូ ( Lope de Vega Carpio ) បានធ្វើតាមបែបនេះ ។ ក៏ប៉ុន្តែភាគច្រើន អ្នកនិពន្ធរឿងល្ខោនតែងតែសរសេរសំរាប់តែសិល្បករ របស់ព្រះរាជវាំង ហើយនិងសរសេរតែរឿងល្ខោនសំរាប់យកទៅសំដែងឱ្យអ្នកទស្សនា ដែលជាពួកអភិជនតែប៉ុណ្ណោះ (aristocratic audiences ) ។

## សម័យធ្វើឱ្យរស់ឡើងវិញ អង់គ្លេស

( IN RESTORATION ENGLAND )

នៅសម័យនេះ ល្ខោនអង់គ្លេសនៅក្រោមរាជស្តេច សា្យល ទី ២ ( CHARLES II-roi d'Espagne et de Sicile 1661-1700 ) គឺបាន បង្កើតឡើងតាមបែបល្ខោនព្រះរាជវាំងរបស់ប្រទេសបារាំង ។ រឿងកំប្លែង ( comedies) ដ៏ឆ្លៀវឆ្លាតតាមបែបកាយវិការ និង រឿងនិទានសោក នាដកម្ម ( tragedies) តាមបែបដើមរឿងបុរាណទាំងឡាយ បានសំដែង ឡើង សំរាប់តែពពួកជនហ៊ុហា-សុភាពស្ត្រី និងសុភាពបុរសរបស់ព្រះរាជ វាំងតែប៉ុណ្ណោះ ( ladies and gentlemen of the courts) កាលនោះអ្នក និពន្ធរឿងល្ខោនបានគោរព និង បានគិតគូរជាបឋមនូវការធ្វើយ៉ាងណាចាត់ ការរកឱ្យបាននូវការកែកំសាន្តសប្បាយសំរាប់ពួកអភិជន ដែលខ្ជិលច្រអូស ទាំងឡាយនោះ ។

## សម័យសតវត្សរ៍ទី ១៨ និង សតវត្សរ៍ទី ១៩

( IN THE EIGTEENTH AND NINETEENTH CENTURIES )

នៅពេលដែលល្ខោនព្រះរាជវាំងកំពុងតែបន្តនូវសកម្មភាពរបស់ខ្លួន នោះ ល្ខោនក៏បានក្លាយមកជាការងារចិញ្ចឹមជីវិត ( bisiness ) យ៉ាងឆាប់ រហ័សបហួសវិស័យនឹងគួរជឿ ។ "ទំនិញក្រុមហ៊ុន" នេះ បានស្ថិតនៅក្រោម ការដឹកនាំរបស់អ្នកចាត់ការសិល្បករ ( actor-manager) ។ ជាមួយគ្នានេះ

ដែរ អ្នកនិពន្ធរឿងល្ខោនក៏បានទទួលនូវកិត្យានុភាពយ៉ាងត្រចះត្រចង់ ហើយលទ្ធផលនេះក៏បានផ្លាស់ប្ដូរតរៀងទៅ តាមរយៈនៃដំណើរការផលិតទៀតផង ។

ដូច្នេះអ្នកនិពន្ធរឿងល្ខោន ក៏បានសរសេររឿងល្ខោនទៅតាមការកំណត់សំរាប់ប្រព័ន្ធពាណិជ្ជកម្ម ចាប់តាំងពីពេលនោះមក ។

## ល្ខោនសម័យទំនើប ( THE MODERN THEATRE )

បច្ចុប្បន្ននេះ ល្ខោនបានក្លាយមកជាល្ខោនបែបសេរី ទូលំទូលាយខ្ពស់ ឆ្ពោះទៅរកចំណុចសរុបបួមដ៏ប្រសើរមួយ ដែលប្រើប្រាស់សុទ្ធតែគ្រឿងភ្លើងអគ្គីសនី ( electric ) នោះវាគឺជាការវិវត្តន៍ដ៏ខ្លាំងក្លាអស្ចារ្យសឹងតែថា ល្ខោនវាគ្មានទម្រង់ ( form ) ឬរចនាបថ ( style ) តែមួយឯកឯងនោះបានសោះឡើយ ។ ហេតុនេះឯង អ្នកនិពន្ធរឿងល្ខោនក៏មានតួនាទីផ្សេងៗគ្នាជាច្រើនផងដែរ ។ នៅក្នុង "ជំនួញល្ខោន"នេះ អ្នកនិពន្ធរឿងល្ខោនបានបែកខ្ញែកគ្នាដោយមកពីទ្រង់ទ្រាយភាគច្រើននៃដំណើរការផលិត ហើយនិងការគិតជាបឋមចំពោះបញ្ហាអ្នកជំនាញខាងសរសេរ ដែលនៅក្នុងល្ខោន "អាវ៉ង់ហ្គាដ " ( avant-garde ) អ្នកនិពរឿងល្ខោនត្រូវធ្វើការយ៉ាងជិតស្និទ្ធបំផុតជាមួយនឹងសិល្បករ ហើយនឹងអ្នកដឹករឿង ។

សព្វថ្ងៃនេះ នៅក្នុងក្រុមល្ខោនជាច្រើនដែលមានបទពិសោធន៍ខ្ពស់ៗ អ្នកនិពន្ធរឿងល្ខោនគេបានសន្មត់ថា ជាតួអង្គអ្នកដឹកនាំមួយរូបដ៏ប្រជាប្រិយបំផុត ដូចដែលគេតែងបានកំណត់ទុកស្មើនឹងអ្នកនិពន្ធរឿងល្ខោនក្នុងសម័យក្រិកបុរាណយ៉ាងដូច្នោះដែរ ។

# ក្រិកបុរាណ

( CLASSICAL GREECE )

- អេស្ស៊ីល ( Eschyle )
- សូហ្វូក្លីល ( Sophocle )
- អឺរ៉ុពីដ ( Euripide )
- អារីស្តូហ្វាន ( Aristophane )



**អេស្គីល** ( Eschyle ឬ Aeschylus )
(Éleusis v-525-Gela,Sicile,456 av.J.C. )

កវីសោកនាដកម្មក្រិក ។ ស្នាដៃទាំងឡាយរបស់គាត់ សុទ្ធសឹងតែយកគំនិតមកពីរឿងព្រេងនិទានរបស់ជនជាតិ Thébes និង រឿងព្រេងនិទាន ពីបុរាណ ដូចជារឿង **ពួកជនដែលអង្វរករ** ( les Suppliantes ) **ពួកសប្តប៉ះនឹងពួកថែប** ( Les Sept contre Thébes ) និង **ឡូរ៉េស្ទី** ( l'Orestie )។ រឿងប្រពៃណីទេវកថា **ប្រូម៉េតេជាប់ច្រវាក់** (Promethée enchaîné) ឬស្នាដៃឯកនៃសង្គ្រាមវិជ្ជាពេទ្យ **ជនជាតិពែរ្ស** ( les Perses ) បានធ្វើឱ្យរូបគាត់ក្លាយទៅជាមាបកជន (créateur) ដ៏ពិតប្រាកដរបស់សោកនាដកម្មបុរាណសម័យ ។



**សូហ្វូគីល** ( Sophocle ឬ Sophocles)
( Colone v.495-Athènes 406 av.J.C )

កវីសោកនាដកម្មក្រិក ។ គាត់បានបន្សល់ទុកនូវរឿងល្ខោនចំនួន ៧ គឺរឿង **អាហ្សាក់** (Ajax) **អង់ទីហ្គោន** (Antigone) **ស្តេចអឺឌីព** ( OEdipe roi ) ; **អេឡិចត្រ៍** ( Électre) ; **ពួកជនត្រាស៊ីនីញេន** ( les Trachiniennes); **ហ្វីឡុកតេត** ( Philoctète ) ; **អឺឌីពនៅកូឡោន** ( OEdipe à Colone ) និងរឿងភាគតិញមួយ ( un fragment des Limiers ) ។

លោកសូហ្វូគីល បានផ្តល់ទៅឱ្យសោកនាដកម្មនូវទម្រង់ដ៏ជាក់ច្បាស់ និងដាច់ស្រេចរបស់គាត់ ដោយបានបន្ថែមសិល្បករទីបីមួយ ( un troisième acteur ) ហើយនិងបង្កើតឱ្យមាននូវសិល្បករចំរៀងចំនួនពី ១២ ទៅ ១៥នាក់ ( choreutes) ។ គាត់បានដាក់ជំនួសនូវចំណងសម្ពន្ធទ្រីឡូហ្ស៊ី ( trilogie liée-បីភាគនៃទេវកថា មានរបៀបតែមួយដូចគ្នា ) និងទ្រីឡូហ្ស៊ីសេរី ( trilogie libre-រឿងល្ខោននីមួយៗជារបស់ស្វយ័ត) ។ លោកសូហ្វូគីល បានកែប្រែអត្ថន័យនៃសោកនាដកម្ម ដោយបានធ្វើវិវត្តតួនិងចរិតលក្ខណៈរបស់តួនូវផ្នែកដ៏សំខាន់មួយនៃការប្រឆាំងនឹងជោគវាសនា និង ឆន្ទៈរបស់ពួកអាទិទេព ។



**អឺរីពីដ** ( Euripides ឬ Euripide )
(Salamine 480-Pella 406.av-J.C )

កវីសោកនាដកម្មក្រិក ។

តាមរយៈរឿងទាំងឡាយដូចជារឿង : Alceste, Médée, Hippolite, Andromaque, Hécube, les Suppliantes, Iphigenie en Tauride, Électre, Hélène, les Phéniciennes, les Bacchantes លោកអឺរីពីដ បានបញ្ចូលរបៀបថ្មីនៃសោកនាដកម្មរបស់គាត់ទៅលើស្នាដៃទាំងនេះនូវ : សារៈសំខាន់នៃការវិភាគតាមបែបចិត្តវិជ្ជា ការធ្វើឱ្យទៅជាថ្មីឡើងវិញ នៃរឿងទេវកថាទាំងឡាយ ឯករាជ្យនៃក្រុមអ្នកចំរៀងចំរុះ ដោយប្រៀបធៀបនឹងសកម្មភាព ។

ស្នាដៃរបស់លោកអឺរីពីដ មានឥទ្ធិពលយ៉ាងជ្រាលជ្រៅទៅលើពួកអ្នកនិពន្ធក្លាស៊ិកបារាំង ( les écrivains classiques français ) ។



## អារីស្តូហ្វាន

( Aristophanes ឬ Aristophane )
(Athènes v.445 -v.386 av.J.C )

កវីហាសនាដកម្មក្រិក ។

រឿងទាំង ១១ ដែលយើងទទួលបានមកពីលោក អារីស្តូហ្វាន គឺបានបង្កើតឡើងនូវការប្រែប្រួលថ្មីនៃកវីនិពន្ធដៀលត្មះទៅលើវិទ្យានិពន្ធបច្ចុប្បន្នភាព និង បានការពារនូវប្រពៃណីផងទាំងឡាយ ប្រឆាំងទល់នឹងគំនិតថ្មី ។ រឿងទាំងនោះមាន :

- **ពួកទាហានម៉ាសេះ** ( les Cavaliers ) ; - **សន្តិភាព** ( la Paix); **លីស៊ីស្ត្រាតា ប្តឹងបរិហារពួកអ្នកប្រជាធិបតេយ្យ ដែលបន្តសង្គ្រាមប្រឆាំងនឹងស្ប៉ាត៍** ( Lysistrata dénoncent les démocrats , qui poursuivent la guerre contre Sparte ) **ពួកឪម៉ាល់ត្រាប់កំប្លែងនូវដំណើរងប់វក់ជក់ចិត្តរឿងក្តីនៃពួកអាថែន** ( les Guêpes parodient la manie procédurière des Athéniens ) **សូក្រាតប្រយុទ្ធតស៊ូក្នុងពពកធំ** ( Socrate est attaqué dans les Nuées ) , **សភាស្ត្រី និងសត្វស្លាប ចំអកឱ្យពួកអ្នកនយោបាយអចិន្តភាព** ( l'Assemblée des

femmes et les Oiseaux raillent les utopies politiques ) ប្លូតុស កំណត់ការឆ្លងរបស់ល្ខោន បញ្ចូលរូបាធិដ្ឋានដល់អ្នកបង្រៀនសីលធម៌ ( Plautos marque le passage du thèâter "engagé" à l'allégorie moralisatrice) ; -les Acharniens, les Thesmophories et les Grenouilles visent Euripide… ។

# រ៉ូមបុរាណ

# ( CLASSICAL ROME )

- ប្លូតុស ( Plautus )
- តេរ៉ង់ស៍ ( TÉRENCE )



**ប៊្លូទុស** ( Plautus ឬ Plaute )
( ឈ្មោះក្នុងភាសាឡាតាំង Maccius ឬ Maccus )
( Sarcina, Ombrie, 254 -Rome 184 av.J.C )
កវីហាសនាដកម្មឡាតាំង ។

លោកប៊្លូទុស បានតែងរឿងល្ខោនកំប្លែងប្រមាណជា ១៣០ ច្បាយរឿង ។ ក៏ប៉ុន្តែនៅពេលដែលគេប្រគល់រឿងរបស់គាត់ទាំង ១៣០ ច្បាយនោះទៅឱ្យលោកវ៉ារ៉ុង ( សូមអានប្រវត្តិសង្ខេបរបស់លោក វ៉ារ៉ុងនៅទំព័រខាងក្រោយបង្អស់ ) លោកវ៉ារ៉ុងទទួលស្គាល់តែ ២១ រឿង ប៉ុណ្ណោះ ដែលមានលក្ខណៈត្រឹមត្រូវពិតប្រាកដតាមច្បាប់ ។

ក្នុងស្នាដៃទាំងឡាយរបស់គាត់ លោកប៊្លូទុសបានយកប្រធានរឿង ( sujet ) មកពីបណ្ដាអ្នកនិពន្ធហាសនាដកម្មទំនើបក្រិក ។ តួអង្គទាំងឡាយរបស់គាត់ បានផ្សាយរួចជាស្រេចនូវគំរូទាំងឡាយនៃ **កំមេឌីយ៉ាដេឡារតេ** ( les types de la commedi dell' arte ) ។

រឿងដែលល្បីល្បាញជាងគេបំផុតនោះគឺ :

- Amphitryon
- Aulularia
- les Ménechmes
- le soldat fanfaron….



**តេរ៉ង់ស៍** ( TÉRENCE )

( ឈ្មោះក្នុងភាសាឡាតាំង Publius Terentius Afer )
( Carthage v.190-159 av.J.C )
កវីហាសនាដកម្មឡាតាំង ។

លោកតេរ៉ង់ស៍ គឺជាទាសករដែលរួចជាអ្នកជា និង ជាសមាជិកសមាគម Scipion Émilien ។ គាត់តែងរឿងហាសនាដកម្ម បានចំនួន ៦ រឿង ដោយគ្រាប់តាមគំរូរបស់ពួកអ្នកនិពន្ធក្រិក និង ឈរលើមូលដ្ឋាននៃការវិភាគចិត្តសាស្ត្រ ។ លោកតេរ៉ង់ស៍ បានក្លាយទៅជាគំរូមួយ ( un modèle ) សំរាប់ពួកអ្នកក្លាស៊ិកបារាំង ដែលមានជាអាទិ៍ដូចជាលោកម៉ូលីយែរជាដើម ។

រឿងកំប្លែងទាំង ៦ របស់គាត់នោះគឺ :

- l' Andrienne
- l' Eunuque
- l' Hécyre
- l' Heautontimoroumenos
- Phormion
- les Adelphes

# អេស្ប៉ាញ ( យុគមាស )

## ( SPANISH Golden Age )

~ កាល់ដឺរ៉ុង (Calderon)

~ ឡុប ដឺ វ៉េហ្គា ( Lope de Vega )



## កាល់ដឺរ៉ុង

Calderon ឬ Calderon de la Barca (Pedro)
( Madrid 1600-id,1681)

កវីល្ខោននាដកម្មអេស្ប៉ាញ៉ុល ។

លោកកាល់ដឺរ៉ុង គឺជាអ្នកនិពន្ធពិធីស្វ័យប្រសិទ្ធី d' autos sacramentales ( Le Grand théâtre du monde ) ហើយនិងរឿងហាសនាដកម្មលើវិទ្យានិពន្ធប្រវត្តិសាស្ត្រ ឬ សាសនា ដូចជារឿង :

- la Dévotion à la Croix ( 1634 )
- La vie est un song ( 1635 )
- le Médecin de son honneur (1635 )
- l'Alcade de Zalamea ( 1642 )



**ឡុប ដឺ វេហ្គា** ( Lope de Vega ឬ Vega Carpio ( félix Lope de ) ( Madrid 1562-id,1635 )

អ្នកនិពន្ធអេស្ប៉ាញ៉ុល ។

លោកឡុប ដឺ វេហ្គា បានសរសេររឿងល្ខោនសាមញ្ញ ( ដែលមិនមែនជារបស់សាសនា ) ចំនួន ១៨០០ រឿង , រឿងល្ខោនវិនាដកម្មទាក់ទងទៅនឹងសាសនាចំនួន ៤០០ រឿង រឿងខ្លីៗសំរាប់ការកំសាន្តចន្លោះរឿងល្ខោន ( intermède ) ជាច្រើនរឿង និងប្រលោមលោកស្តីពីព្រះសង្ឃនាយកកាតូលិកមួយរឿងឈ្មោះ " l'Arcadie " កំណាព្យជាច្រើនដែលនិយាយពីការកាន់សាសនាដ៏តឹងរ៉ឹង ( le Romancero spirituel ) ហើយ និងរឿងបែបក្រមាច់ ។

ទេពកោសល្យល្ខោនរបស់លោក ឡុប ដឺ វេហ្គា បានបណ្តុះនូវគ្រប់ប្រពៃណីប្រវត្តិសាស្ត្រ សាសនា ហើយនិងប្រជាប្រិយនៃប្រទេសអេស្ប៉ាញទាំងមូល ដូចជារឿង :

- l'Alcade de Zalamea ( 1600 )
- Peribánéz et le Commandeur d'Ocaña ( 1614 )
- le Chien du jardinier ( 1618 )
- Fuenteovejuna ( 1618 )
- le Cavalier d'Olmedo ( 1631 )

# អង់គ្លេស

# អេលីហ្សាបេត និង ហ្សាកូប៊ីន

( ELIZABETHAN & JACOBEAN ENGLAND )

~ គ្រីស្តូហ្វើរ ម៉ារលូវ

( Christopher Marlowe )

~ វីលៀម ស្សេកស្ពៀរ

(William Shakespeare )

~ បេន ហ្សុនសុន

( Ben Jonson )



## គ្រីស្តូហ្វើរ ម៉ារលូវ

( Christopher Marlowe )
( Canterbury 1564-Deptford, Londres,1593 )

កវីល្ខោននាដកម្មអង់គ្លេស ។

លោកគ្រីស្តូហ្វើរ ម៉ារលូវ គឺជាអ្នកនិពន្ធរឿង **ប្រវត្តិសោកនាដកម្មរបស់លោកវេជ្ជបណ្ឌិតហ្វូស្ត៍** ( la Tragique Histoire du D$^{r}$ Faust ) ។



## វីលៀម ស្សេកស្ពៀរ

William Shakespeare
(Stratford-on-Avon,
Warwickshire 1564-1616)

កំពូលកវី

បិតាល្ខោនទាដកម្មអង់គ្លេសដ៏មហិមា !

លោកវីលៀម ស្សេកស្ពៀរ បានបន្សល់ទុកឱ្យប្រទេសអង់គ្លេស និងពិភពលោកទាំងមូលនូវបុព្វហេតុវប្បធម៌មួយដ៏សំបើមអស្ចារ្យ ។ បណ្ដាប្រទេសនានាលើពិភពលោកសព្វថ្ងៃនេះ សុទ្ធតែមានច្បាប់បកប្រែវណ្ណកម្មកំណាព្យ និង ស្នាដៃល្ខោនរបស់លោកទាំងអស់ ៖

- មានអត្ថបទវិភាគអក្សរសិល្ប៍មហាវិទ្យាល័យរាប់សែន ស្ដីអំពីស្សេកស្ពៀរ...

- មានវណ្ណកម្មរាប់ពាន់សរសេរអំពីស្សេកស្ពៀរ... ដោយផ្អែកតាមវណ្ណកម្មរបស់លោក ឬមួយក៏ស្ថាបនាវណ្ណកម្មរបស់លោកឡើងវិញ... ទាំងគ្រប់វិស័យនៅលើពិភពលោកទាំងមូល ដូចជានៅក្នុងវិស័យភាពយន្ត ( រហូតមកដល់សព្វថ្ងៃ មានខ្សែភាពយន្ត ៣០០ ស្រង់ចេញពីរឿងល្ខោនរបស់លោក ) វិស័យវិចិត្រកម្ម បទភ្លេង ចម្លាក់... សុទ្ធតែមានយកមូល

បទចេញមកពីវណ្ណកម្មដែលជាស្នាដៃរបស់លោកស្បេកស្ពៀរ និង បង្កើតជាវណ្ណកម្មដ៏ឆ្នើមនានា ។

និយាយរួម ស្ទើរតែរាល់ឆ្នាំ ពិភពលោកទាំងមូលសុទ្ធតែមានគំហើញ និងការច្នៃប្រឌិត គំនិតផ្តួច ផ្តួចបង្កើតថ្មី ស្តីអំពីស្បេកស្ពៀរ បិតានៃល្ខោនកំណាព្យអង់គ្លេស និង ពិភពលោក !!!

## ជីវប្រវត្តិសង្ខេប :

ជីវប្រវត្តិរបស់លោក ស្បេកស្ពៀរ នៅតែមានភាពស្រពិចស្រពិលនៅឡើយ ។ ពតិមានជាក់ច្បាស់ទាំងឡាយស្តីពីជីវិតរបស់លោក ស្បេកស្ពៀរ គេបានដឹងតិចតួចជាងដែលអ្នកខ្លះមិនព្រមទទួលស្គាល់រូបគាត់ថា ជាម្ចាស់នៃស្នាដៃរបស់គាត់ ដើម្បីធ្វើឱ្យរូបគាត់បានឈានទៅសំរេចឈ្មោះដ៏ពិរោះ ជាតួអង្គដ៏ល្បីល្បាញស្មើនឹងលោក Francis Bacon ឬ Comte d'Oxford នោះទៅទៀត ។

លោក វីល្លៀម ស្បេកស្ពៀរ កើតនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៥៦៤ នៅតំបន់ដ៏ស្អាតមួយមានឈ្មោះថា ស្ត្រាតហ្វរដ៍ ។ ឪពុករបស់លោក គឺជាអ្នកប្រកបរបរដេរស្រោមដៃស្បែក និង ជាអ្នកមុខអ្នកការ ( notable ) ម្នាក់ មានជីវភាពធូរធារ ។ ក៏ប៉ុន្តែក្រោយមក មិនដឹងជា

មានហេតុ "ស៊ិយចង្រៃ" អ្វីស្រាប់តែគ្រួសាររបស់លោកធ្លាក់ខ្លួនក្រតោកយ៉ាកយ៉ាងខ្លាំង ។ ពេលនោះលោកស្បេកស្ពៀរដែលទើបតែមានអាយុបាន ១២ឆ្នាំប៉ុណ្ណោះ ក៏បានបង្ខំចិត្តបោះបង់ចោលការសិក្សា ហើយមកជួយធ្វើការរកស៊ីចិញ្ចឹមគ្រួសារវិញ ។

គឺប្រហែលជាមកពីមូលហេតុនេះឯងហើយ ដែលមានឯកសារមួយបានបញ្ជាក់សេចក្តីយ៉ាងច្បាស់ថា លោកស្បេកស្ពៀរ គឺជាមនុស្សម្នាក់រៀនសូត្របានតិច គឺលោករៀនមិនទាន់ចប់បឋមសិក្សានៅឡើយទេ ( តាមការរកឃើញរបស់អ្នកសិក្សាស្រាវជ្រាវជនជាតិបារាំងពីររូប ដែលជាអ្នកជំនាញខាងផ្នែកអក្សរសាស្ត្រអង់គ្លេស គឺអ្នកស្រី Jean-Maric និងលោក Angela Maguin ) ។

លោកស្បេកស្ពៀរ បានរស់នៅជាមួយក្រុមគ្រួសាររបស់លោកនៅក្នុងបណ្តាឆ្នាំដ៏ក្រលំបាក និងដ៏អាប់អួរនាកាលនោះរហូតដល់ឆ្នាំ ១៥៨២ ទើបគ្រួសាររបស់លោកមានជីវភាពរស់នៅគ្រាន់បើបន្តិចឡើងវិញ ។ ក្នុងអំឡុងពេលនោះ លោកស្បេកស្ពៀរបានចាប់ចិត្តស្រឡាញ់នារីម្នាក់ឈ្មោះនាង Anne Hathaway (នាងមានអាយុលើសលោកស្បេកស្ពៀរដល់ទៅ ៨ ឆ្នាំ ) ។ គេបាននិយាយថា លោកស្បេកស្ពៀរបានរៀបអាពាហ៍

ពិពាហ៍ជាមួយនឹងនាងនេះ នៅក្នុងឆ្នាំ ១៥៨២ ពេលដែលលោកមានអាយុ ១៨ ឆ្នាំ ។

គេបាននិយាយទៀតថា ក្នុងរយៈពេល ៣ ឆ្នាំក្រោយពេលរៀបអាពាហ៍ពិពាហ៍ លោកស្បេកស្ពៀរ និងភរិយារបស់លោកមានកូន៣នាក់ គឺកូនស្រីម្នាក់ឈ្មោះ Susanna កើតក្នុងឆ្នាំ ១៥៨៣ ហើយនិងកូនភ្លោះពីរនាក់ទៀត គឺ Judith និង Hamnet កើតនៅក្នុងឆ្នាំ ១៥៨៥ ។ កូនប្រុសដែលឈ្មោះថា Hamnet នេះ បានស្លាប់នៅពេលដែលអាយុបាន ១១ឆ្នាំ ហើយក្រោយមកឈ្មោះនេះក៏បានក្លាយមកជា " Hamlet " ដ៏ល្បីល្បាញនៅក្នុងវណ្ណកម្មដ៏ល្បីឆ្មើមរបស់លោកមួយ គឺរឿង " Hamlet " សរសេរឡើងក្នុងឆ្នាំ ១៦០១ ។

ប្រហែលក្នុងអំឡុងឆ្នាំ ១៥៨៥ ឬ ១៥៨៦ លោកស្បេកស្ពៀរ បានចាកចេញពីស្ត្រាតហ្វរដ៍ ទៅកាន់ទីក្រុងឡុងដ្រ៍ ។ កាលជំនាន់នោះ ទីក្រុងឡុងដ្រ៍ មានប្រជាជនប្រមាណតែពីរសែននាក់ប៉ុណ្ណោះ ។ ពេលទៅដល់មុនដំបូង គេមិនបានដឹងច្បាស់ថា តើលោកស្បេកស្ពៀរប្រកបរបរអ្វីខ្លះទេនៅទីនោះ គឺហាក់ដូចជារបរអ្វីក៏លោកធ្វើដែរ ដូចជាយាមទ្វារ មើលថែទាំសេះ ស៊ីឈ្នួលការងារកំប៉ិកកំប៉ុក បង្ហាត់បង្រៀនក្មេងៗជាដើម... ។ តែបន្ទាប់មក គឺនៅក្នុងឆ្នាំ ១៥៨៨ ( ឆ្នាំបរាជ័យនៃ Invincible Armada )

លោកស្សេកស្ពៀរ បានចូលទៅបំរើក្នុងក្រុមល្ខោនរបស់លោក លរដ៍ ស្រ្តេង ( Lord Strange ) នៅក្នុងទីក្រុងឡុងដ្រ៍ ។ គូបដិបក្សរបស់ក្រុមនេះ គឺក្រុមរបស់អ្នកនិពន្ធរឿងល្ខោនរបស់លោកគ្រីស្តូហ្វើរ ម៉ារលូវ ( Christopher Marlowe ១៥៦៤-៩៣ ) ដ៏មានទេពកោសល្យ ។ ក្នុងអំឡុងពេលនេះ លោកស្សេកស្ពៀរបានសរសេររឿងល្ខោនល្អៗជាច្រើនឲ្យក្រុម Lord Strange ។ រឿងដែលលោកបានទទួលជោគជ័យដ៏ល្បីល្បាញយ៉ាងខ្លាំងនោះគឺរឿង "ហង់រីទី៦" ( Henri VI ) ។ ប៉ុន្តែជាសំណាងអាក្រក់នៅឆ្នាំ ១៥៩២ ក៏ស្រាប់តែកើតមានជំងឺប៉េស ( peste ) យ៉ាងសាហាវនៅក្នុងទីក្រុងឡុងដ្រ៍ ។ រោងមហោស្រព និង រោងល្ខោននានាបានបិទទ្វារទាំងអស់ ។ នៅឆ្នាំ ១៥៩៣ លោកម៉ារលូវ ដែលជាមេគូបដិបក្សរបស់ក្រុមលោកស្សេកស្ពៀរ បានត្រូវស្លាប់ដោយចៃដន្យ ។

ពីរឆ្នាំក្រោយមក គឺនៅឆ្នាំ ១៥៩៤ ( ពេលអស់កើតមានជំងឺប៉េស ) លោកស្សេកស្ពៀរក៏មានឱកាសធ្វើសកម្មភាពជាថ្មីឡើងវិញ ។ មនុស្សម្នាជាច្រើន បានបង្វែរការចាប់អារម្មណ៍មកលើលោកស្សេកស្ពៀរ ហើយពួកគេក៏រកឃើញនូវ " ជនមានទេពកោសល្យដ៏ចំបងម្នាក់ " នោះគឺ "លោកស្សេកស្ពៀរ បិតាល្ខោននាដកម្មអង់គ្លេសដ៏មហិមា ! " ។

នៅក្នុងឆ្នាំ ១៥៩៤ នេះដែរ លោកស្បេកស្ពៀរក៏បានក្លាយទៅជាសិល្បករ និងធ្វើជាអ្នកចូលហ៊ុននៅក្នុងក្រុមល្ខោនរបស់ លរដ៍ ស្ប៉ំបែលឡាំង ( la troupe de Lord Chambellain ) ។ លោកស្បេកស្ពៀរបានយកមូលបទ ដែលអ្នកដទៃសរសេរបរាជ័យ មកសរសេរសាជាថ្មីឡើងវិញតាមរបៀបរបស់លោក ហើយបានទទួលជោគជ័យយ៉ាងធំធេង ។

នៅក្នុងឆ្នាំ ១៥៩៨ លោកស្បេកស្ពៀរបានតាំងលំនៅ នៅក្នុងរោងល្ខោនហ្គលុប ( Théâtre du Globe )។ លោកបានទទួលការនិយមរហូតដល់រោងមហោស្រពនានា យល់ព្រមចែកភាគរយនៃប្រាក់ចំណូលនៅរាល់ពេលសំដែងរឿងល្ខោនរបស់លោក ដោយមិនម៉ៅសងដូចជាអ្នកនិពន្ធរឿងល្ខោនឯទៀតៗឡើយ ។ ប្រការនេះ នាំមកឱ្យលោកស្បេកស្ពៀរនូវប្រភពចំណូលយ៉ាងច្រើន ។

នៅក្នុងឆ្នាំ ១៦០៣ ក្រុមល្ខោនរបស់លោកស្បេកស្ពៀរ បានត្រូវព្រះរាជវាំងអង់គ្លេសតែងតាំងជា " ល្ខោនព្រះរាជទ្រព្យ " ។

លោកស្បេកស្ពៀរ បានត្រឡប់ទៅនៅឯស្ត្រាតហ្វរដ៍វិញ នៅពេលដែលរោងល្ខោន Globe ត្រូវទទួលរងនូវអគ្គីភ័យក្នុងឆ្នាំ ១៦១៣ ។

លោក ស្បេកស្ពៀរ ទទួលមរណភាពនៅឆ្នាំ ១៦១៦ ក្នុងជន្មាយុ ៥២ ឆ្នាំ ។

## វណ្ណកម្មរបស់លោកស្បេកស្ពៀរ

នៅក្នុងល្ខោនរបស់លោកស្បេកស្ពៀរ គេអាចធ្វើការកត់សំគាល់បាននូវប្រវត្តិកាលបួនដូចតទៅ :

**ប្រវត្តិកាលទីមួយ** ( ១៥៩០ - ១៥៩៤ )

សំគាល់បានតាមរយៈនៃការស្រើបរំភើបចិត្តដ៏ខ្លាំងក្លាមួយ ( un enthousiame très élisabethan ) ។ ក្នុងប្រវត្តិកាលទីមួយនេះ រឿងល្ខោនរបស់លោក ស្បេកស្ពៀរមានចំរុះគ្នាជាច្រើនយ៉ាង ដោយរួមមានទាំងរឿងហាសនាដកម្ម រឿងប្រវត្តិសាស្ត្រ ហើយនិងរឿងសោកនាដកម្ម ។

សាច់រឿងទាំងឡាយនៃរឿងល្ខោនទាំងនេះ រក្សាជាប់តាមនូវប្រភពរបស់វាបានយ៉ាងល្អប្រសើរ ជាជាងសាច់រឿងដែលលោកសរសេរក្នុងពេលជាខាងក្រោយៗមកទៀត ។ ហើយសាច់រឿងទាំងនេះក៏មានរក្សានូវឈុតនៃទំនាក់ទំនងភាគ ដែលមិនសូវទៀងទាត់ ដូចជារួបរួមនូវរចនាសម្ព័ន្ធនៃវិនាដកម្មឱ្យបានជិតស្និទ្ធជាអង្គតែមួយផង ។ លើសពីនេះទៀតជាទូទៅ រឿងល្ខោនទាំងអស់នេះ បានគូសបញ្ជាក់នូវព្រឹត្តិការណ៍ច្រើនជាងការរៀបរាប់នូវរូបលក្ខណៈតួអង្គ ។

នៅក្នុងប្រវត្តិកាលទីមួយនេះ ការប្រើប្រាស់ភាសារបស់លោកស្បេកស្ពៀរ បានបង្ហាញថា លោកនៅមិនទាន់បានព្យាយាមប្រឹងប្រែងធ្វើឱ្យរចនាបថកំណាព្យរបស់លោកផ្ទាល់ វិវត្តទៅរកភាពចួនវណ្ណ៍ និង ពិរោះស្រទន់នៅឡើយទេ ។ ជាឧទាហរណ៍ កំណាព្យពិពណ៌នារបស់លោកនៅក្នុងប្រវត្តិកាលនេះ គឺសមគួរនឹងក្លាយទៅជាមានរបៀបរៀបរយ ដូចជាការធ្វើឱ្យមានទំនាក់ទំនងយ៉ាងត្រឹមត្រូវ ឆ្ពោះទៅរកការវិវត្តន៍នៃចរិតលក្ខណៈតួអង្គ ឬក៏អង្គរឿង ។

<u>រឿងទាំងនោះរួមមាន</u> :

- The Comedy of Errors ( comedy-1592 )
- Henry VI ( history 1589-92 )
- Richard III ( history-1592-93 )
- The Taming of the Shrew ( comedy-1593 )
- Tilus Andronicus ( tragedy-1593-94 )
- The Two Gentlemen of Verona ( comedy-1594 )
- King John ( history-1594 )

## <u>ប្រវត្តិកាលទីពីរ</u> ( ១៥៩៥ - ១៦០០ )

ក្នុងអំឡុងប្រវត្តិកាលទីពីរនេះ លោកស្បេកស្ពៀរ បាននាំមកនូវវិនាដកម្មប្រវត្តិសាស្ត្រ ហើយនិងហាស្យនាដកម្មអំណែតអណ្តូង ស្រើបរំភើបដ៏ខ្លាំងក្លាមួយ ឱ្យខិតចូលទៅជិតភាពសមល្អត្រឹមត្រូវឥតខ្ចោះ ។ ដោយ

ឡែកនៅក្នុងរឿងបែបប្រវត្តិសាស្ត្រ និង រឿងហាសនាដកម្មទាំងឡាយរបស់លោកក្នុងប្រវត្តិកាលនេះ លោកស្សេកស្ពៀរ បានបង្ហាញឱ្យឃើញនូវទេពកោសល្យ ប្រកបដោយបញ្ញាដ៏មហាខ្ពស់លើសលប់របស់លោក ចំពោះការបង្កើតទម្រង់សកម្មភាពវិនាដកម្មដ៏សំបូរបែបផ្សេងៗគ្នា ក្នុងសាច់រឿងតែមួយ ដូចជាការសរសេរឈុតមួយនៃភាគដែលមានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ។

ដោយទូទៅ ប្រវត្តិកាលទីពីរនេះ គឺជាដំណាក់កាលដែលលោកស្សេកស្ពៀរបានចលនាទីកន្លែង ឆ្ពោះទៅកាន់បញ្ញាដ៏កំពូលរកទីប្រដូចមិនបាន សំរាប់ការសំដែងនូវគុណលក្ខណៈពិសេសនៃគ្រឿងសំគាល់របស់**មហាសោកនាដកម្មដ៏កំពូល** ដែលលោកផលិតនៅក្នុងដើមឆ្នាំ ១៦០០ ។

<u>ក្នុងប្រវត្តិកាលទីពីរនេះរួមមាន</u> :

- A Midsummer Night's Dream ( comedy-1595)
- Richard II ( history-1595)
- Love's Labour's Lost ( comedy-1596)
- Romeo and Juliet ( tragedy-1596)
- The Merchant of Venice ( comedy-1597)
- Henry IV ( history-1597)
- As You Like It ( comedy-1599)
- Henry V ( history-1599)
- Julius Caesar ( tragedy-1599)

- Much Ado About Nothing ( comedy-1599)
- Twelfth Night ( comedy-1600)
- The Merry Wives of Windsor ( comedy-1600)

## ប្រវត្តិកាលទីបី ( ១៦០១ ‐ ១៦០៨ )

លោកស្បេកស្ពៀរ បានសរសេរ " មហាសោកនាដកម្មដ៏កំពូល " របស់លោក នៅក្នុងអំឡុងប្រវត្តិកាលទីបីនៃការវិវត្តនីរកចំរើនផ្នែកសិល្បៈ របស់លោក ។ លើកលែងតែរឿង " Pericles " មួយចេញ គឺគ្រប់តែរឿងល្ខោនទាំងអស់នៃដំណាក់កាលនេះ សុទ្ធសឹងបង្ហាញនូវភាពដែលមានសម្បជញ្ញៈរបស់លោកស្បេកស្ពៀរ ក្នុងផ្នែកសោកនាដកម្មនៃជីវិត ។ សូម្បីតែនៅក្នុងប្រវត្តិកាលនេះ មានរឿងហាសនាដកម្មដល់ទៅពីរទៀតក៏ដោយ ( All's Well That Ends Well និង Measure for Measure ) ក៏វាបានធ្វើឱ្យកើតទុក្ខច្រើនជាងសំណើចរីករាយផងដែរ ។ ក្នុងន័យនេះ ជានិច្ចកាល គេតែងតែហៅថា ហាសនាដកម្ម "បញ្ហា " ឬ ហាសនាដកម្ម "ជូរចត់ " ។

រឿង Pericles គឺជារឿងមួយដែលបង្ហាញពីប្រលោមលោកទីមួយរបស់លោកស្បេកស្ពៀរ -គឺជាវិនាដកម្មមួយដែលជាទូទៅម៉ឺងម៉ាត់ម៉ត់ចត់នៅក្នុងសូរសំលេង ក៏ប៉ុន្តែមានក្តីរីករាយសប្បាយនៅទីបញ្ចប់ ។

ក្នុងអំឡុងប្រវត្តិកាលនេះ ភាសារបស់លោកស្បេកស្ពៀរ បានបង្ហាញនូវបែបផ្សេងៗ និងភាពទន់ភ្លន់គួរឱ្យកត់សំគាល់ ចលនាការបញ្ចេញបញ្ចូលរវាងបទកាព្យ និងពាក្យរាយបានយ៉ាងងាយស្រួល ។ ភាសារបស់លោកបានប្រសូតចេញមកពីគ្រឿងឧបករណ៍វិនាដកម្មចំរុះរួមមួយ ដែលធ្វើឱ្យមានលំអាចដល់រូបភាពជំនាញចិត្តសាស្ត្រដ៏ប៉ិនប្រសប់មួយ ដែលគួរឱ្យកត់សំគាល់បាននៅក្នុងដំណាក់កាលនេះ ។

រឿងទាំងអស់នោះមានដូចជា ៖

- Hamlet ( tragedy-1601)
- Troilus and Cressida ( tragedy-1602 )
- All's Well That Ends Well ( comedy-1603 )
- Measure for Measure ( comedy-1604 )
- Othello ( tragedy-1604 )
- King Lear ( tragedy-1605 )
- Macbeth ( tragedy-1606 )
- Timon of Athens ( tragedy-1607 )
- Pericles ( roman-1607 )
- Antony and Cleopatra ( tragedy-1607 )
- Coriolanus ( tragedy-1608 )

**<u>ប្រវត្តិកាលទីបួន</u> ( ១៦០៩ ~ ១៦១៣ )**

ក្នុងប្រវត្តិកាលចុងក្រោយនេះ លោកស្បេកស្ពៀរបានសរសេររឿងល្ខោនចំនួនបួន គឺរឿងហាសនាដកម្ម ៣ រឿងប្រវត្តិសាស្ត្រ ១ ។ អ្នកធ្វើ

ការសិក្សាជាច្រើន បានចាត់ទុករឿងហាស្យនាដកម្មទាំង ៣ ហើយនិងរឿង Pericles ជាប្រលោមលោករបស់លោក ស្សេកស្ពៀរ ។ លោកស្សេកស្ពៀរទំនងជាបានសរសេររឿងប្រវត្តិសាស្ត្រ ដែលមានចំណងជើងថា " Henry VIII " នេះ ជាមួយនិងលោក John Fletcher ។

ប្រលោមលោកទាំងបីនេះ គឺជារឿងដែលបានបង្កើតឡើងប្រកបដោយសោភ័ណយ៉ាងប្រណីត ហើយកំណាព្យកាព្យឃ្លោងរបស់វា បានចាត់ចូលទៅក្នុងកិច្ចសរសេរដ៏សំរាំងសំរិតឥតខ្ចោះបំផុតរបស់លោក ស្សេកស្ពៀរ ។ ក៏ប៉ុន្តែវាមិនដូចទៅនឹងមហារឿងដ៏កំពូលៗទាំងឡាយនៃប្រវត្តិកាលទីបីនោះទេ រឿងប្រលោមលោកទាំងនេះហាក់ដូចជាបានញែកចេញពីប្រាកដភាពតែប៉ុណ្ណោះ ។ អ្នកសិក្សាទាំងឡាយ មិនយល់ស្របទៅនឹងគំនិតស្តីអំពីការផ្លាស់ប្តូរនេះនៅក្នុងស្នាដៃរបស់លោក ស្សេកស្ពៀរផងទេ ។ អ្នកខ្លះបានអះអាងថា លោកស្សេកស្ពៀរ បានសំឡឹងមើលក្រោយ ដោយស្ងៀមស្ងាត់ទៅលើខ្សែជីវិតរបស់លោក ហើយបូកសរុបលទ្ធផលនៃការត្រិះរិះពិចារណាលើវិជ្ជាជីវៈរបស់លោក ។ អ្នកសិក្សាដទៃទៀតបានជឿជាក់ថា លោកស្សេកស្ពៀរបានសរសេររឿងប្រលោមលោកទាំងនេះ ដើម្បីធ្វើឱ្យពេញចិត្តដល់ការផ្លាស់ប្តូរចម្ងាញ់របស់អ្នកស្តាប់ ឬអ្នកទស្សនារបស់លោក ។

ពួកគេបានចាប់អារម្មណ៍ថា វិនាដកម្មទាំងអស់នេះបានចាំងត្រឡប់នូវការដុះលូតលាស់នៃប្រជាប្រិយភាពនៃរឿងល្ខោនទាំងឡាយ ដែលមានចំរុះទៅដោយរឿងកំប្លែង ហើយនិងគុណភាពដ៏ប្រាកដប្រជាពិតៗ ។ ប្រលោមលោកទាំងនេះ ទំនងជាបានបង្ហាញខ្លួនទាំងការផ្លាស់ប្តូរមួយនៅក្នុងអាកប្បកិរិយារបស់លោកស្សេកស្ពៀរ ឆ្ពោះទៅកាន់ជីវិត ហើយនិងការខិតខំប្រឹងប្រែងព្យាយាមមួយដើម្បីធ្វើតាមបែបល្ខោន ។

វណ្ណកម្មក្នុងប្រវត្តិកាលចុងក្រោយនេះមាន :

- Cymbeline ( roman-1609 )
- The Winter's Tale ( roman-1610 )
- The Tempest ( roman-1611 )
- Henry VIII ( history-1613 )

ក្រៅពីនេះ វណ្ណកម្មរបស់លោកស្សេកស្ពៀរ មានរួមបញ្ចូលនូវកំណាព្យរឿង ( The narrative poems ) ហើយនិងកម្រងអត្ថបទសោណេ្ណ ( The sonnets ) ដ៏ល្បីល្បាញថែមទៀត ដែលសុទ្ធសឹងតែចាត់ទុកបានថា ជាកំពូលស្នាដៃឯករបស់លោកស្សេកស្ពៀរ ។

... ការដែលសរសេរដើម្បីសាធារណជន ដែលមានមនុស្សភាគច្រើនជាប្រជារាស្ត្រ ហើយនិងពួកអភិជននោះ ល្ខោនរបស់លោកស្សេកស្ពៀរ បានធ្វើឱ្យមានការងឿងឆ្ងល់ដល់គេគ្រប់គ្នាតាមរយៈភាពផ្សេងគ្នា

ហើយនិងពលសម្បទនៃរចនាបថ ( la viguer du style ) តាមរយៈនៃការមានជាតិយោគ្យភាពនៃតួអង្គទាំងឡាយ និងភាពផ្សេងគ្នានៃសង្គម និងនៃចិត្តវិជ្ជារបស់ពួកគេទាំងនោះ តាមរយៈនៃភាពជាម្ចាស់លើខ្លួនឯងនៃការតាក់តែង ស្ថាបនាល្ខោននាដកម្ម...។



**បេន ហ្សុនសុន** Ben Jonson
( Westminster 1573 – Londres 1637 )

អ្នកនិពន្ធល្ខោននាដកម្មអង់គ្លេស ។

បេន ហ្សុនសុន គឺជាមិត្តសំលាញ់ និង ជាគូប្រជែងរបស់លោក ស្សេកស្ពៀរ ។ ជាអ្នកនិពន្ធ ដែលបង្ហាញពីលក្ខណៈនៃរឿងល្ខោនសោកនាដកម្ម និង ហាសនាដកម្ម ដូចជារឿង : " វ៉ុលប៉ូន ឬ សត្វកញ្ជ្រោងឈ្មោល " Volpone ou le Renard ( ១៦០៦ ) ។

# បារាំង

## ( NEOCLASSIC FRANCE )

- ពៀរ កក៌ណៃ ( Pierre Corneille )
- ម៉ូលីយែរ ( Molière )
- ហ្សង់ រ៉ាស៊ីន ( Jean Racine )



## ព្យែរ គ័រណី

PIERRE CORNEILLE
(Rouen 1606 – Paris 1684 )

កវីល្ខោននាដកម្មបារាំង - បិតានៃសោកនាដកម្មមួយរូបដ៏ល្បាញល្បីនៃសតវត្សទី ១៧ និងជាស្មាក្តី ( avocat ) លោកមានទេពកោសល្យជាពិសេស ខាងតាក់តែងរឿងល្ខោនជាពាក្យកាព្យ ។

### ជីវប្រវត្តិសង្ខេប :

លោកព្យែរ គ័រណី កើតនៅទីក្រុងរូអេ្យង ( Rouen ) ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ១៦០៦ ក្នុងគ្រួសារមធ្យមមួយ ។ ឪពុករបស់លោកមានមុខរបរជាស្មាក្តីពិសេសនៃក្រុមគង្គា និងរុក្ខា ។ លោកគ័រណីមានប្អូន ៦នាក់ ដែលក្នុងនោះមានម្នាក់ឈ្មោះ ថូម៉ា ជាអ្នកនិពន្ធរឿងសោកនាដកម្មដ៏ល្បីម្នាក់ដែរ នៅសតវត្សទី ១៧ និងប្អូនស្រីរបស់លោកម្នាក់ទៀត ដែលត្រូវជាម្ដាយរបស់លោកហ្វុងតឺណែល ( ក្មួយប្រុសរបស់លោកគ័រណី ) ជាអ្នក

និពន្ធបារាំងនៅសតវត្សទី ១៨ ( Bernard Le Bovier de Fontenelle ( 1657-1757 ) ។

កាលនៅជាកុមារ លោកគ័រណី បានចូលទៅសិក្សានៅអនុវិទ្យាល័យនៃគ្រិស្តបរិស័ទ ( Collège des Jésuites ) នៅក្នុងទីក្រុងរូអៀង ។ លោក ព្យែរ គ័រណី បានសិក្សាផ្នែកសាសនា និងភាសាឡាតាំង ( latin ) ប្រកបដោយជោគជ័យ ។ នៅក្នុងឆ្នាំ ១៦២៤ ក្រោយពីបានសិក្សាខាងច្បាប់ចប់ហើយ លោក ព្យែរ គ័រណី បានបើកមន្ទីរស្មាក្តីមួយ ក៏ប៉ុន្តែក្នុងវិជ្ជាជីវៈនេះ លោកពុំបានជួបប្រទះនូវជោគជ័យទេ ព្រោះអីលោកពុំដែលបានកូនក្តីណាមកពឹងពាក់លោកសោះ ។ ដូច្នេះក្រោយមក លោកក៏បោះបង់មុខរបរនេះ ហើយតាំងចិត្តថានឹងងាកទៅបំរើក្នុងវិស័យសិល្បៈ និង អក្សរសាស្ត្រវិញ ។

នៅឆ្នាំ ១៦២៥ លោក គ័រណី បានចាប់ផ្តើមសរសេរសៀវភៅមួយជាពាក្យកាព្យខ្លីៗ ចំរុះទៅដោយបែបបទផ្សេងៗផង ។ កិច្ចការនិពន្ធរបស់លោក គ័រណី ចេះតែប្រព្រឹត្តទៅដោយសុវត្ថិភាព ។ មហាជនបារាំងសែសចាប់ផ្តើមស្គាល់លោក គ័រណី នៅពេលដែលលោកបានសរសេររឿងមួយឈ្មោះ មេលីត ( Mélite ) ។ រឿងនេះគឺជារឿងកំប្លែងលើកទី ១ របស់លោកដែលបាននិពន្ធឡើងក្នុងឆ្នាំ ១៦២៩ បន្ទាប់ពីបានចាប់ចិត្តស្រលាញ់

កូនក្រមុំអ្នកស្រុករួអៀងម្នាក់ ។ ស្នាដៃនេះត្រូវបានវង់ល្ខោនរបស់លោក ម៉ុនដូរី ( ក្រោយមកក្រុមល្ខោននេះបានប្ដូរឈ្មោះទៅជា " ឡាទ្រុប ឌឺ ម៉ារ៉េ " ) យកទៅសំដែងឯទីក្រុង ប៉ារីស ដោយទទួលបានជោគជ័យដ៏អស្ចារ្យ ។ នៅពេលនោះមានមន្ត្រីសង្ឃជាន់ខ្ពស់កាតូលិកម្នាក់ បានទទួលយល់ព្រមអនុញ្ញាតឱ្យលោកគ័រណី ចូលរួបរួមក្នុងក្រុមអ្នកនិពន្ធរបស់លោក ។ ប៉ុន្តែក្រោយមក រូបលោកត្រូវគេបណ្ដេញឱ្យចេញវិញ ដោយហេតុថា លោកជាមនុស្សមានះ ហើយមិនសូវសុខចិត្តស្ដាប់បង្គាប់នរណាផង ។

ជោគជ័យដ៏ត្រចះត្រចង់ក្នុងរឿង មេលីត បានជំរុញទឹកចិត្តរបស់លោកគ័រណី ឱ្យតែងនិពន្ធរឿងផ្សេងៗទៀត ។ ប៉ុន្តែរឿងដែលគាត់តែងបន្ទាប់ពីរឿង មេលីត ច្រើនតែជារឿងសោកនាដកម្ម ។

នៅឆ្នាំ ១៦៣៥ លោកគ័រណី បានចូលជាសមាជិកនៃ " ក្រុមអ្នកនិពន្ធ ៥ នាក់ " ដែលដឹកនាំដោយលោក រីស៊េលីយើ ( Richelieu, prélat et homme d'État français, 1585-1642 ) ។

នៅក្នុងឆ្នាំ ១៦៣៦ លោក គ័រណី បានចេញផ្សាយនូវរឿងសោកនាដកម្មដ៏ល្បីល្បាញមួយ ដែលមានឈ្មោះថា " ឡឺស៊ីដ " ( le Cid ) ។ រឿងនេះត្រូវបានក្រុមល្ខោនម៉ារ៉េដដែល យកទៅសំដែងនៅទីក្រុងប៉ារីស

ហើយទទួលជោគជ័យដ៏ធំសំបើមអស្ចារ្យ រហូតដល់ទទួលបាននូវការសរសើរជាពិសេស ពីសំណាក់ស្តេចល្វីស ទី ១៣ ( Louis XIII, roi de France, 1601-1643 ) ។ ក៏ប៉ុន្តែជាមួយនឹងជោគជ័យនេះ រឿង "ឡឺស៊ីដ" ក៏ត្រូវបានអ្នកនិពន្ធ ដែលប្រឆាំងនិងច្រណែននឹងរូបលោក ធ្វើការទិតៀនជាខ្លាំងណាស់ដែរ ។ ការរិះគន់នេះ ចេះតែប្រព្រឹត្តទៅរហូតដល់ក្រោយមកក្លាយជាជម្លោះដ៏ធំមួយ ដែលគេឱ្យឈ្មោះថា "ជម្លោះឡឺស៊ីដ" ។ ជំលោះនេះកាន់តែរីកធំឡើងៗ រហូតដល់មានកើតជាសង្គ្រាមប៉ាក្កា ប្រឆាំងគ្នាទៅវិញទៅមក ។ ព្រឹត្តិហេតុនេះបានតំរូវឱ្យលោក រីស៊េលីយើ យករឿង " ឡឺស៊ីដ " ទៅដាក់ឱ្យបណ្ឌិតសភាអក្សរសាស្ត្រធ្វើការវិនិច្ឆ័យ ហើយដែលពេលនោះបណ្ឌិតសភាបានទិតៀនក្រោមលេសថា " មិនបានប្រតិបត្តិតាមវិធានទាំងឡាយរបស់សោកនាដកម្ម " ។

ដោយនឿយណាយនឹងជម្លោះ ព្រមទាំងមានការតូចចិត្តផងនោះ លោកគរ័ណើ ក៏ដកខ្លួនថយពីកិច្ចការនិពន្ធ ហើយត្រឡប់ទៅនៅឯស្រុកកំណើតវិញ ។

លោក គរ័ណើ បានរៀបការជាមួយនឹងនាង ម៉ារី ដឺ ឡាំប៉េរីយែរ ( នាងមានអាយុតិចជាងរូបលោក ១១ ឆ្នាំ ) ។ អាពាហ៍ពិពាហ៍នេះបានប្រព្រឹត្តឡើងក្រោយមរណភាពរបស់ឪពុកលោកមួយឆ្នាំ ។

គ្រួសាររបស់លោក ក័រណី រស់នៅក្នុងទីក្រុងរូអៀង ជាសុខសាន្ត រហូតមក ។ ប៉ុន្តែ លោកក៏ឧស្សាហ៍មកទីក្រុងប៉ារីសញឹកញាប់ដែរ ។

នៅក្នុងឆ្នាំ ១៦៤០ លោកក័រណី បានចូលប្រលូកជាថ្មីម្តងទៀត លើវេទិកាអក្សរសិល្ប៍ ។ ស្នាដៃឯកជាបន្តបន្ទាប់មកទៀតរបស់លោកមានជាអាទិ៍គឺ : Horace, Cinna, Polyeucte, Nicoméde, la Mort de Pompée ។ លោកក័រណី ក៏បាននិពន្ធរឿងកំប្លែងមួយទៀតផងដែរ គឺ រឿង " អ្នកភូតកុហក " le Menteur ។

គួរកត់សំគាល់ថា រឿង " ឡឺស៊ីដ " និងរឿង " អ្នកភូតកុហក " ជាអត្ថបទដែលដកស្រង់ពីរឿងល្ខោន អេស្ប៉ាញ៉ុល ។

លោក ព្យែរ ក័រណី បានចូលជាសមាជិកបណ្ឌិតសភាបារាំងផ្នែកអក្សរសាស្ត្រនៅថ្ងៃ ទី ២២ ខែ មេសា ឆ្នាំ ១៦៤៧ ។

## បុគ្គលិកលក្ខណៈរបស់លោក ក័រណី

លោក ក័រណី មានលក្ខណៈជាមនុស្សសាមញ្ញបំផុត ព្រមទាំងមានចរិយាសុភាពរាបសារទៀតផង ។ លោកជាមនុស្សទុយមុយ មិនសូវនិយាយស្តី សំលេងគ្រោតគ្រាតពុំពិរោះ គ្មានវិធីកោសល្យ និងគ្មានសណ្តាប់ធ្នាប់ក្នុងការស្លៀកពាក់ ។ លោកគ្មានវោហារទេ សូម្បីតែអត្ថបទល្ខោន

ដែលលោកសរសេរខ្លួនឯង ក៏លោកអានមិនបានហួរហែក្បោះក្បាយដែរ បើសំលឹងមើលលក្ខណៈក្រៅ លោកគរ័ណើ មិនសមអីជាអ្នកនិពន្ធរឿងសោកនាដកម្មដ៏ល្បីល្បាញសោះ ។ លោកជាសុភាពបុរស មាឌធំ ហើយខ្ពស់ កែវភ្នែកមុតថ្លា ច្រមុះធំកោង ដែលជាការបញ្ជាក់ឱ្យឃើញនូវទឹកចិត្តមានះ និង អំណត់របស់លោក ។

លោកគ័រណើ ជាគ្រិស្តបរិស័ទមួយរូប ដែលមានចិត្តភក្តីបំផុត រហូតអាចដល់បូជាជីវិតដើម្បីសាសនា ។ លោកមានការគោរពសាសនាយ៉ាងស្មោះស្ម័គ្រ ហើយនិយមធម៌ចាស់ផង ឆ្លៀតពេលទំនេរពីការនិពន្ធរឿងល្ខោន លោកតែងបកប្រែ និង និពន្ធអត្ថបទខ្លះៗ ដែលទាក់ទងនឹងគ្រិស្តសាសនា ដូចជាអត្ថបទដែលមានចំណងជើងថា : l' Imitation de Jésus Christ ។ អត្ថបទនេះបានទទួលជោគជ័យយ៉ាងខ្លាំងណាស់ដែរ អំពីសំណាក់បរិស័ទ ដែលមានជំនឿខ្លាំងលើគ្រិស្តសាសនា ។ ក្រៅពីនេះ លោកបានសរសេររឿងមួយឈ្មោះ ប៉ូលីយើក ( Polyeucte ) ដែលបង្ហាញឱ្យឃើញច្បាស់ នូវមនោសញ្ចេតនាផ្ទាល់ខ្លួនរបស់លោក ចំពោះសាសនា ។

លោក គ័រណី ធ្លាប់មានទំនាស់ជាមួយនឹងអ្នកនិពន្ធល្បីខ្លះៗដែរ ដូចជានៅក្នុងឆ្នាំ ១៦៦២ មានទំនាស់ជាមួយលោក ម៉ូលីយែរ ឆ្នាំ ១៦៧០ ជាមួយលោក រ៉ាស៊ីន ។

## ស្ថានភាពគ្រួសាររបស់លោក គ័រណី

ក្រៅអំពីនាទីជាអ្នកនិពន្ធ លោកគ័រណី គឺជាមេគ្រួសារដែលមានកូន ៧នាក់ នៅក្នុងបន្ទុក ( ស្រីបី ប្រុសបួន ) ការរស់នៅក្នុងជីវិតគ្រួសារពុំបានផ្តល់នូវសុភមង្គលពេញលេញដល់រូបលោកទេ ។ លោកគ័រណី ជួបតែការឈឺចាប់ និង ភាពទីទ័លក្រ ។ ប្អូនពៅបង្អស់របស់លោក បួសជាសង្ឃ ចំណែកកូនប្រុសទីពីររបស់លោក ត្រូវគេប្រហារជីវិតក្នុងឆ្នាំ ១៦៧៤ ។

## ជីវិតចុងក្រោយរបស់លោក គ័រណី

បន្ទាប់ពីបានទទួលបរាជ័យរឿង ស៊ុយរេណា ក្នុងឆ្នាំ ១៦៧៤ មក លោក គ័រណី ក៏បោះបង់ឈប់និពន្ធអ្វីទាំងអស់ ។

រឿងល្ខោនទាំងឡាយរបស់លោក គ័រណី សុទ្ធសឹងជារឿងដែលច្រៀងរៀបរាប់អំពីសេចក្តីស្នេហាខ្ពង់ខ្ពស់ ប្រកបដោយកិត្តិយស ។ លុះក្រោយមក មហាជនក៏បែរជាមកចូលចិត្តរឿងទាំងឡាយ ដែលនិយាយពី

សេចក្តីស្នេហាប្រកបទៅដោយតណ្ហាវិញ ។ ដូច្នេះប្រជាប្រិយភាពនៃរឿងល្ខោនរបស់លោកគរ័ណេី ក៏កាន់តែអន់ថយបន្តិចម្តងៗទៅតាមចង្វាក់ភ្លើតភ្លើន ចំពោះតណ្ហានៃមនុស្សជាតិ ។

លោក ពៀរ គរ័ណេី ទទួលមរណភាពនៅថ្ងៃ ទី ១ ខែ តុលា ឆ្នាំ ១៦៨៤ ក្នុងទីក្រុងប៉ារីស ក្នុងជន្មាយុ ៧៨ ឆ្នាំ ។

## វណ្ណកម្មរបស់លោក គរ៉ណី

តួអង្គនៅក្នុងវណ្ណកម្មទាំងឡាយរបស់លោក ព្យែរ គរ៉ណី សុទ្ធសឹងជាកំពូលមនុស្សអង់អាចក្លាហាន មោះមុត សុខចិត្តយកជីវិតទៅប្តូរនឹងកិត្តិយស មានចិត្តស្មោះត្រង់នឹងករណីយកិច្ច ហើយទាត់ចោលយ៉ាងឥតស្តាយស្រណោះនូវគំនិតគ្រួសារនិយម និង តណ្ហានិយម... ។

វណ្ណកម្មរបស់លោក គរ៉ណី ចែកចេញជា ៥ ផ្នែកដូចតទៅ :

### ១_ផ្នែក ហាស្យនាដកម្ម :

- Mélite ( 1629 )
- la Veuve
- la Galerie du palais ( 1631-32 )
- la Suivante
- l' Illution comique ( 1635-36 )
- le Menteur ( 1643 )
- la Suite de Menteur
- Don Sanche d'aragon ( 1650 )
- Tite et Bérénice ( 1670 )
- Pulchérie

### ២_ ផ្នែក សោក_ហាស្យនាដកម្ម :

- Clitandre
- le Cide ( 1636 – 37 )

## ៣~ ផ្នែក សោកនាដកម្ម :

- Médée ( 1635 )
- Horace ( 1640 )
- Cinna ou la Clémence d'Augustes ( 1640-41 )
- Polyeucte ( 1641-42 )
- la Mort de Pompée ( 1643 )
- Rodogune( 1644-45 )
- Théodore
- Vierge et Martyre
- Héraclius
- Andromède ( 1650 )
- Nicoméde ( 1651 )
- Pertharite ( 1651 )
- OEdipe ( 1659 )
- la Toison d'or
- Sertoirius ( 1662 )
- Othon
- Agésilas
- Attila ( 1667 )
- Psyché ( tragi-comédie-ballet de Molière (1671),écrite en collaboration avec Corneille et Quinault; musique de Lully; chorégraphie de Beauchamp )
- Suréna

## ៤~ ផ្នែក សាសនា :

- Imitation de Jésus-Christ ( 1651-56 )
- Stances á Marquise du parc

- Office de la vierge

៥- <u>ផ្នែក ទ្រឹស្តី</u> :

- អារម្ភកថា ( Préface )
- សេចក្តីឧទ្ទេស ( dédicaces )
- ការត្រួតពិនិត្យឃុតរឿងល្ខោន ( Examens des pièces )
- សុន្ទរកថាទាំងបីស្តីអំពីសិល្បៈនាដកម្ម ( Trois Discours sur l'art dramatique, 1660 )

ក៏ប៉ុន្តែក្នុងចំណោមស្នាដៃដ៏ច្រើនសន្ធឹកសន្ធាប់នេះ មានតែរឿងចំនួន ៤ ប៉ុណ្ណោះ ដែលគេចាត់ទុកជាស្នាដៃឯកពិតៗ ( vrais chefs-d'oeuvres ) របស់លោក ព្យែរ ក័រណី គឺ :

១- **ឡឺស៊ីដ** ( le Cid, 1636-37 ) និយាយអំពីទំនាស់វិបត្តិរវាងកិត្តិយស និង សេចក្តីស្នេហា... រ៉ូឌ្រិកមានកាតព្វកិច្ច ត្រូវតែសំលាប់គរម៉ាស់ ឪពុកនាងស៊ីម៉ែន ដែលជាសង្សារបណ្តូលចិត្ត ដើម្បីសងសឹក ស្តារកិត្តិយសជូនលោកឪពុកបង្កើតរបស់ខ្លួនឈ្មោះ ដុងយ៉ែក ពីការទះកំផ្លៀងប្រមាថមើលងាយ ។ សាច់រឿងមានសភាពតានតឹង និង ស្មុគស្មាញ :

ព្រះរាជបុត្រី ដុណ្ណា អ៊ុយរ៉ាក់ ជំពាក់ស្នេហ៍ទៅលើរ៉ូឌ្រិក តែស៊ីម៉ែនឯណេះវិញទេ គឺជាសង្សាររបស់រ៉ូឌ្រិក "ស្នេហារវាងបុរសម្នាក់ ស្រីពីរ ? " ។

ចំណែកឯរ៉ូឌ្រិកវិញត្រូវធ្វើការជ្រើសរើស : តើត្រូវសំលាប់សងសឹកជូនឪពុក ឬមួយត្រូវជ្រើសយកស្នេហា ? ទីបំផុត រ៉ូឌ្រិកបានជ្រើសរើសយកកិត្តិយសជាធំ !

២- **អូរ៉ាស់** ( Horace, 1640 ) និយាយអំពីករណីយកិច្ចចំពោះប្រទេសជាតិ ។ រឿងនេះបានបង្ហាញឱ្យឃើញពីសេចក្ដីស្នេហាជាតិមាតុភូមិរបស់លោកតា អូរ៉ាស់ ហើយនិងកូនប្រុសរបស់គាត់ ។ លោកតវ័ណីបានដាក់ប្រឈមមុខនូវសេចក្ដីក្លាហានដ៏ខ្ពង់ខ្ពស់ របស់គូរីយ៉ាស់ ( Curiace ) ហើយនិងសេចក្ដីស្នេហាដាច់ខាតរបស់កាមីយ ( Camille ) ប្អូនស្រីរបស់គូរីយ៉ាស់ ។

៣- **ស៊ីណា** (Cinna ou la Clémence d'Auguste 1640-41 ) ក្នុងរឿង ស៊ីណា ឬ ការអត់ឱនរបស់ព្រះចៅ អូហ្គូស្ដ៍នេះនិយាយអំពីសេចក្ដីអត់ឱនដ៏អស្ចារ្យមួយ ។ ដោយការអភ័យទោសចំពោះស៊ីណា ហើយនិងអេមីលី ( Émilie ) ដែលរួមគំនិតក្បត់ក្នុងការប៉ងធ្វើឃាតលើរូបព្រះអង្គនោះ ព្រះចៅអូហ្គូស្ដ៍ក៏បានរកឃើញនូវសេចក្ដីត្រេកត្រអាល នៃអំណាចផ្ដាច់ការស្ថិតនៅក្នុងការបដិសេធ នៃការហាត់ (exercice) របស់ព្រះអង្គ ។

៤- Polyeucte ( 1641-42 ) និយាយអំពីសេចក្ដីស្នេហាចំពោះអាទិទេព ។ រឿងនេះលោកគរ័ណេី បានដកស្រង់គំនិតប្រឌិតចេញមកពីប្រវត្តិពិតរបស់លោក សាំងត៍ ប៉ូលីយើក ( Saint Polyeucte (m. à Mélitène, Arménie,v.250 ) នាយទាហានរ៉ូមាំង និងជាទុក្ករបុគ្គល ( martyr) ...ដោយមិត្តរបស់គាត់ឈ្មោះណេអាក ( Néarque ) បញ្ចុះបញ្ចូលឱ្យផ្លាស់ប្តូរគំនិត (សាសនា ) គាត់ក៏ធ្វើទុក្ករកម្ម ដើម្បីបានផ្លាស់ប្តូរនូវគោរពរូបទាំងទុក្ខាយ ( les idoles ) នៅក្នុងថ្ងៃបុណ្យមួយ ។

## គរ័ណេី និង ឧត្តមភាពអក្សរសិល្ប៍

ដើម្បីទាក់ទាញទឹកចិត្ត និងអង្រួនអារម្មណ៍អ្នកអាន និងទស្សនិកជនរបស់ខ្លួនឱ្យកំរើករំជួយ លោកគរ័ណេីមិនបានពឹងផ្អែកទៅលើ " ការអាណិតអាសូរ " ឬ " ការឃោរឃៅ" ឡើយ ។ លោកមិនបានបង្កើតឱ្យមានជាតួកំសត់ ក្រលំបាកតោកយ៉ាក ដើរត្រាច់រង្កាត់ លេចវាលចូលព្រៃ ឬក៏បង្កើតឱ្យមានឡើងនូវទារុណកម្មវាយដំច្រំធាក់ អំពីតួអង្គមួយទៅលើតួអង្គមួយទៀតនោះទេ ។ ដើម្បីធ្វើឱ្យអ្នកអាន អ្នកទស្សនាបានរំភើបញាប់ញ័រអារម្មណ៍នោះ លោកបានបង្កើតឱ្យមាននៅក្នុងវណ្ណកម្មរបស់ខ្លួននូវ "រសជាតិ " ប្លែកពីរបែបគឺ :

១- ភាពរំភើបចិត្ត ( la Pathétique )

២- សេចក្ដីស្ងើចសរសើរ ( l'Admiration )

រសជាតិទាំងពីរនេះ ជាវត្ថុធាតុថ្មីស្រឡាង ដែលលោកគរ័ណេយនាំចូលមកក្នុងវង់ល្ខោនបារាំងនាសតវត្ស ទី ១៧ ហេតុដូច្នេះហើយបានជាគេឱ្យឈ្មោះលោកគរ័ណេយថាជា " បិតានៃសោកនាដកម្ម " ។

## លក្ខណៈទូទៅនៃរឿងសោកនាដកម្មរបស់លោកគរ័ណេយ

សោកនាដកម្ម ជារឿងដែលប្រកបដោយការតានតឹង សន្ទឹះសង្ស័យ និងទុក្ខភ័យ ។ សោកនាដកម្មដែលគេនិពន្ធឡើងសំរាប់លេងល្ខោននៅស.វ ទី ១៧ គេឱ្យឈ្មោះថា សោកនាដកម្មគន្ថិ ( tragédie classique ) ។ គេអាចសំគាល់រឿងមួយថា ជាសោកនាដកម្មគន្ថិ អាស្រ័យដោយមានលក្ខណៈសំខាន់ពីរដូចតទៅ :

### ១_ លក្ខណៈក្រៅ

- ដំណើររឿង សុទ្ធតែដកស្រង់ចេញពី ប្រវត្តិសាស្ត្រ ឬទេពនិទាន ។

- តួអង្គសុទ្ធសឹងតែជាស្ដេចផែនដី ឬ ឥស្សរជន

- សកម្មភាពរបស់តួអង្គ តែងតែមានករិតតានតឹងជានិច្ច លាយឡំដោយកិត្តិគុណ ហើយតែងតែវិវត្តបន្តិចម្ដងៗ ឆ្ពោះទៅកាន់ការដោះស្រាយ

បញ្ហា ដែលពោរពេញទៅដោយការធ្វើពលិកម្ម រហូតដល់ទីបញ្ចប់មានតួអង្គខ្លះស្លាប់ ។

## ២. លក្ខណៈខាងក្នុង

សោកនាដកម្មតន្តិក្នុងស.វទី ១៧ ត្រូវតែអនុវត្តនូវវិធីដែលគេឱ្យឈ្មោះថា " វិធីសមត្រៃ " ដែលមានដូចតទៅ ៖

- **សមកាល** : សកម្មភាពរឿងត្រូវតែកុំឱ្យហួសពី ២៤ម៉ោង ព្រោះកុំឱ្យឃ្លាតពីការពិត ។

- **សមដ្ឋាន** : សកម្មភាពរឿងត្រូវតែស្ថិតនៅកន្លែងដដែលគ្មានផ្លាស់ប្តូរ គឺថាសកម្មភាពគ្រប់ឈុត គ្រប់ឆាក ត្រូវស្ថិតនៅក្នុងកន្លែងតុបតែងតែមួយ ។

- **សមកម្ម** : សកម្មភាពរឿង ត្រូវតែវិលជុំវិញបញ្ហាសំខាន់តែមួយ ។ ពោលគឺទាក់អារម្មណ៍អ្នកអាន អ្នកទស្សនា ឱ្យផ្តោតអារម្មណ៍តែទៅលើមូលបញ្ហាចោទរបស់រឿង ។

ដើម្បីឱ្យបានស្គាល់ពីគំនិត និងទឹកចិត្តផ្សេងៗរបស់តួអង្គ អ្នកនិពន្ធរឿងល្ខោនសោកនាដកម្មត្រូវប្រើ " ឯកវាទ " និង " សំវាទ " ៖

- ឯកវាទ ៖ គឺការដែលតួអង្គម្នាក់ និយាយតែម្នាក់ឯង ។

- សំវាទ : គឺការដែលតួអង្គទាំងឡាយ និយាយឆ្លើយឆ្លងគ្នា ។

រឿងល្ខោនសោកនាដកម្ម ត្រូវតែជៀសវាងនូវការវាយតប់បង្ហូរឈាមគ្នា នៅលើឆាកជាដាច់ខាត ។ ក៏ប៉ុន្តែដើម្បីធ្វើឱ្យអ្នកទស្សនាបានដឹងអំពីហេតុភេទទាំងនេះ គេត្រូវតែបង្កើតឱ្យមានតួអង្គសំរាប់និទានរឿងប្រាប់ ។

## គំនិតធំៗរបស់លោកគរ័ណេ

តាមរយៈនៃការសិក្សានូវបណ្តាស្នាដៃទាំងឡាយរបស់លោក ព្យែរ គរ័ណេ គេអាចធ្វើការកត់សំគាល់បាននូវគោលគំនិតធំ៧ដូចតទៅ :

### ១. វីរនិយម :

តួឯកទាំងឡាយនៅក្នុងរឿងរបស់លោក គរ័ណេ សុទ្ធសឹងជាវីរបុរសដែលកម្ររកបាន ជាជនដែលប្រកបទៅដោយទឹកចិត្តក្លាហាន មោះមុតហ៊ានធ្វើពលិកម្មគ្រប់សព្វបែបយ៉ាង ដើម្បីបំរើឧត្តមគតិដ៏ខ្ពង់ខ្ពស់មួយរបស់ខ្លួន ។ តួអង្គក្នុងអត្ថបទដែលជាស្នាដៃរបស់លោកគរ័ណេ សុទ្ធសឹងជាវីរជនពិសេស ដែលស្ថិតនៅក្នុងព្រឹត្តិការណ៍ ឬស្ថានភាពពិសេស ជាជនដែលមិនចេះចុះញ៉មនឹងឥទ្ធិពល " ទឹកចិត្ត " និង " ចំណងតណ្ហា " ជាជនដែលតស៊ូក្រាញនឿយយ៉ាងប្តូរផ្តាច់ ឆ្លងកាត់ឧបសគ្គធំៗទាំងឡាយ ដោយគ្មាន

តក់ស្លុត ឬរន្ធត់ញាប់ញ័រ ជាបុគ្គលប្រកបដោយ " គុណធម៌ " "ឆន្ទៈសេរី " និងជាចៅហ្វាយលើទឹកចិត្តខ្លួនឯងផ្ទាល់ ។

ក្នុងការបំពេញករណីយកិច្ចផ្សេងៗ វីរជនរបស់លោកគរ័ណី តែង បង្ហាញឱ្យឃើញនូវកំលាំងឆន្ទៈដ៏ពុះពោរ និង ឋាមពលខាងផ្លូវចិត្ត ក៏ដូចជា ខាងផ្លូវកាយ ដែលពុំអាចរកវត្ថុអ្វីមកបង្ក្រាបបានឡើយ ។ មនោសញ្ចេតនា ផ្ទាល់ខ្លួន ពុំមាននាទីសំខាន់ក្នុងដួងចិត្តរបស់វីរជន លោក គរ័ណីទេ ផ្ទុយទៅ វិញ គេជាអ្នកឈ្នះលើមនោសញ្ចេតនា និងចំណងតណ្ហាទាំងអស់ ។

នៅក្នុងរឿង " ឡឺស៊ីដ " កំលោះរ៉ូឌ្រិក ហ៊ានសំលាប់ឪពុករបស់ កញ្ញាស៊ីម៉ែន ដែលត្រូវជាអនាគតឪពុកក្មេករបស់ខ្លួន ដោយគ្មានញញើតដៃ ព្រោះតែលោកតានេះ បង្អាប់កិត្តិយសគ្រួសាររបស់ខ្លួន ។ ថ្វីបើ រ៉ូឌ្រិក ស្រឡាញ់នាងស៊ីម៉ែន ដែលជាសង្សារស្ទើរលេបយ៉ាងណាក៏ដោយ ក៏រ៉ូឌ្រិក កំលោះដើមទ្រូងប្រាំហត្ថ មិនបានយកសេចក្តីស្នេហារបស់ខ្លួនជាធំដែរ ។ ទី បំផុតគេឃើញរ៉ូឌ្រិកលើកដាវប្រហារលោកតា ដុងគរ័ម៉ាស់ ដែលជាឪពុក របស់នាង ស៊ីម៉ែន យ៉ាងអង់អាចបំផុត ។

នៅក្នុងរឿង អូរ៉ាស់ ( Horace ) គេឃើញបងប្អូនឯងប្រហារគ្នា ទៅវិញទៅមក ព្រោះតែស្រលាញ់ជាតិ ។ គេឃើញអូរ៉ាស់ហ៊ានសំលាប់ប្អូន ស្រីឯងបង្កើត ឈ្មោះនាង កាមីយ ព្រោះតែនាងបានប្រមាថក្រុងរ៉ូម ។

នៅក្នុងរឿង " ស៊ីណា " ( Cinna ) ព្រះចៅអូហ្គុស សុខចិត្តអត់ទោសឱ្យពួកក្បត់ដែលមានបំណងប្រហារព្រះអង្គ ។ នៅក្នុងរឿងរបស់លោក គរ័ណី គេឃើញតួអង្គទាំងឡាយច្រើនតែបំពេញនូវ " វីរសកម្ម " ក្នុងទឹកចិត្តហានក្លា និងឆន្ទៈដ៏សែនមោះមុត ។ ហើយឆន្ទៈនេះ គឺប្រាកដជាឆន្ទៈពិសេសដែលមានកិរិតខ្ពស់ក្រៃលែង ព្រមទាំងជាឆន្ទៈដែលឈ្នះលើចិត្តខ្លួនឯងផង ។

" វីរជន " របស់លោក គរ័ណី មានការម៉ឺងម៉ាត់ណាស់ចំពោះខ្លួនឯង ចំពោះគ្រួសារ ចំពោះមិត្តភក្តិ ចំពោះសង្សារ ។ វត្ថុទាំងឡាយនេះ គេអាចទាត់ចោលបាននៅពេលណា ដែលគេមានករណីយកិច្ចដ៏សំខាន់ណាមួយត្រូវបំពេញ ។ គេធ្វើអ្វីៗត្រូវតែឱ្យបានសំរេច គេមិនខ្វីរវល់ដល់សេចក្តីទន់ខ្សោយរបស់នរណាឡើយ ។

រូឌ្រិក បន្ទាប់ពីបានសំលាប់ឪពុកនាងស៊ីម៉ែន ដើម្បីសងសឹកឱ្យគ្រួសារខ្លួនឯងរួចហើយ គេគ្មានវិប្បដិសារីអ្វីទាំងអស់ ។ គេនិយាយថា : "អំពើដដែលនេះ ខ្ញុំអាចធ្វើវាទៀត ប្រសិនបើខ្ញុំមានការចាំបាច់ត្រូវធ្វើ " ។

**២. កិត្តិយសនិយម :**

រឿងរបស់លោក គរ័ណី សុទ្ធសឹងតែបង្ហាញឱ្យឃើញនូវតំលៃដ៏ខ្ពង់

ខ្ពស់របស់ " កិត្តិយស " ។ វីរសកម្មទាំងឡាយក្នុងដំណើររឿង តែងជាប់ទាក់ទងជានិច្ចជាមួយ " ការដោះស្រាយ " និង " ការលើកតម្កើងកិត្តិយស" នេះ ។ ហើយជាធម្មតា បញ្ហាកិត្តិយសតែងជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងបញ្ហាករណីយកិច្ច ។ ដើម្បីបំផុសបញ្ហាទាំងពីរនេះឱ្យលេចត្រដែតឡើង អ្នកនិពន្ធតែងយកតួអង្គក្នុងរឿងទៅដាក់ក្នុងបរិយាកាសទំនាស់វិបត្តិផ្សេងៗជានិច្ច បន្ទាប់មកអ្នកនិពន្ធបានតម្រូវឱ្យតួអង្គនោះធ្វើការជ្រើសរើស ។ ក្នុងរឿង "ឡឺស៊ីដ" រ៉ូឌ្រិកត្រូវជ្រើសរើសយកស្នេហា ឬមួយយកកិត្តិយស ។ តើរ៉ូឌ្រិកត្រូវការពារកិត្តិយសរបស់ឪពុកខ្លួន ឬមួយក៏ត្រូវលុតជង្គង់ចំពោះមុខសេចក្តីស្នេហា គឺរូបនាងស៊ីម៉ែន កំពូលស្នេហ៍ ?

នៅក្នុងរឿង " អូរ៉ាស់ " លោកគ័រណី ក៏បានតម្រូវឱ្យតួអង្គធ្វើការជ្រើសរើសដូច្នោះដែរ គឺជ្រើសរើសយកសេចក្តីស្នេហាចំពោះគ្រួសារ ឬយកករណីយកិច្ចចំពោះប្រទេសជាតិ ។

តាមការសង្កេត គឺនៅពេលណាក៏ដោយ លោកគ័រណី តែងតែឱ្យតួអង្គរបស់ខ្លួនជ្រើសរើសយកករណីយកិច្ច និង កិត្តយសជានិច្ច ។

## ៣. មាតុភូមិនិយម :

លោកគ័រណី ជាអ្នកយកចិត្តទុកដាក់នឹងបញ្ហាប្រទេសជាតិណាស់ ។

ផ្ទុយអំពីអ្នកនិពន្ធខ្លះ ដែលតែងតែងុបងុលនឹងបញ្ហាស្នេហា បញ្ហាគ្រួសារ បញ្ហាលុយកាក់នោះ លោកគរ័ណី តែងបានលើកយកនូវបញ្ហាស្នេហភាពទឹកដី និង សន្តិភាពប្រទេសជាតិមកលាតត្រដាងយ៉ាងច្បាស់លាស់ ។

វីរសកម្មគ្រប់យ៉ាងនៃតួអង្គក្នុងរឿងរបស់លោកគរ័ណី មិនមែនសុទ្ធតែមានទិសដៅ ឆ្ពោះទៅរកតែការការពារកិត្តិយសគ្រួសារផ្ទាល់ខ្លួននោះទេ ហួសពីនេះគឺឆ្ពោះទៅរកការការពារប្រទេសជាតិទាំងមូលផង ។ លោកគរ័ណីយល់ថា បើគ្មានប្រទេសជាតិ-គ្រួសារក៏គ្មានដែរ ។ ការតស៊ូដើម្បីសេចក្តីគង់វង់នៃទឹកដីក៏មានន័យថា តស៊ូដើម្បីវត្តមាននៃគ្រួសារដូច្នោះដែរ ។ ក្នុងរឿងអូរ៉ាស់ លោកគរ័ណី មិនបានធ្វើឱ្យតួអង្គសំខាន់ណាមួយស្លាប់ដោយឥតប្រយោជន៍ ឬស្លាប់ដោយមិនបានបំពេញវីរសកម្មចំពោះជាតិមាតុភូមិទេ ។ បើតួអង្គនោះត្រូវស្លាប់ អ្នកនិពន្ធតែងឱ្យតួនោះទៅជាទាហាន ហើយស្លាប់ក្នុងន័យការពារជាតិវិញ ដូចជា " សេវែរ " ក្នុងរឿង ប៉ូលីយើក ជាដើម ។

នៅក្នុងរឿង អូរ៉ាស់ គេឃើញថា គូរីយ៉ាស់ ដែលមានស្រុកកំណើតនៅអាល់ប៊ី បានមកស្រលាញ់ កាមុីយ ប្អូនស្រីបង្កើតរបស់អូរ៉ាស់ ។ ចំណែកអូរ៉ាស់ ដែលមានស្រុកកំណើតនៅរ៉ូម បានមករៀបការជាមួយនាង "សាប៊ីន" ដែលជាប្អូនស្រីបង្កើតរបស់គូរីយ៉ាស់ ។ សម័យថ្ងៃមួយប្រទេស

ទាំងពីរគឺរ៉ូម និងអាល់ប៉ កើតសង្គ្រាមនឹងគ្នា ។ ពេលនោះនាង " គួរីយ៉ាស់" ត្រូវទៅបំពេញករណីយកិច្ចរបស់ខ្លួនក្នុងឋានៈជាពលរដ្ឋអាល់ប៉ ។ ចំណែកខាង "អូរ៉ាស់" ក៏មានការចាំបាច់ត្រូវចេញការពារទឹកដី ក្នុងឋានៈខ្លួនជាពលរដ្ឋក្នុងក្រុង "រ៉ូម" ដែរ ។

ដូច្នេះសោកនាដកម្មគ្រួសារទាំងពីរត្រូវកើតឡើង ចំណែកអាពាហ៍ពិពាហ៍ ចំណងភាតរភាព ចំណងគ្រួសារត្រូវកាត់ផ្ដាច់មួយអន្លើសិន ។ គួរីយ៉ាស់ និងអូរ៉ាស់ ត្រូវកាន់អាវុធបង្ហូរឈាមគ្នា ។ គេត្រូវប្រយុទ្ធគ្នាយកស្លាប់រស់ដើម្បីការពារមាតុភូមិរៀងៗខ្លួន ។

ពេលនោះ ឆន្ទៈស្នេហាជាតិរបស់គេឡើងខ្ពស់ដល់កំរិត ។ គេគ្មានគិតអ្វីក្រៅពីការតស៊ូ ដើម្បីឱ្យជាតិរស់ប៉ុណ្ណោះ ។ អូរ៉ាស់បានលើកអាវុធសំលាប់ប្អូនស្រីឯងបង្កើត ព្រោះតែនាងស្រលាញ់ គួរីយ៉ាស់ ហើយបានតិះដៀលដល់ក្រុងរ៉ូម ដែលបានបំបែកស្នេហានាង ។

**<u>បញ្ហាស្នេហា</u>** :

ស្នេហាក្នុងរឿងរបស់លោក គរ៉ណី ក៏ច្រើនតែជា " វីរស្នេហា " ដែរ ហើយច្រើនតែមានលក្ខណៈជាតុរង្វាន់ចុងក្រោយ ឬជាគ្រឿងលើកទឹកចិត្តដល់តួអង្គវីរបុរសណា ដែលបានបំពេញនូវវីរសកម្ម ។

ឧទាហរណ៍ នាងស៊ីម៉ែន ដែលទីបំផុតបានក្លាយជាភរិយារបស់រ៉ូឌ្រិក នោះ ក៏មិនមែនក្នុងឋានៈ រ៉ូឌ្រិក ជាអតីតសង្សាររបស់នាងទេ ប៉ុន្តែក្នុងឋានៈគេជាវីរបុរសមួយរូប ដែលបានច្បាំងឈ្នះពួក " Maures " ដែលជាទមិឡ ចូលមកឈ្លានពាននគររបស់ខ្លួន ។

ស្នេហាធុនថោក ស្នេហាជាន់ទាបទាំងឡាយ គេហាក់ដូចជាពុំបានជួបប្រទះសោះទេក្នុងស្នាដៃរបស់លោកគរ័ណី ។ លោក គរ័ណី ពុំបានយកស្នេហាជាធំទេ ។ ក្នុងផ្ទៃរឿងរបស់គាត់គ្មានទេ " ការស្លាប់ " ព្រោះស្នេហា ។

នៅក្នុងរឿង ឡឺស៊ីដ លោកគរ័ណី បានសរសេរថា :" សេចក្ដីស្នេហាគ្រាន់តែជាការសប្បាយប៉ុណ្ណោះ ចំណែកឯកិត្តិយស គឺជាករណីយកិច្ច " L'amour n' est qu' un plaisir l'honneur est un devoir ស្នេហាដែលល្អប្រសើរនោះ គឺស្នេហាប្រកបទៅដោយកិត្តិយស ។

## យោបល់រឿង

លោកគរ័ណី អាចចាត់ទុកថា ជាបិតានៃសោកនាដកម្មមួយរូបនាសតវត្សទី ១៧ បាន ព្រោះលោកបានចំណាយពេលវេលាស្ទើរជាងពាក់កណ្ដាលជីវិតរបស់លោក សំរាប់ប្រឡូកក្នុងសង្វៀនអក្សរសិល្ប៍ ព្រមទាំងបាននាំមកនូវវត្ថុធាតុថ្មីៗជាច្រើន សំរាប់សិល្បៈល្ខោនសោកនាដកម្មសម័យ

នោះផង តែតែងឱ្យតំលៃទៅលើរឿងល្ខោនរបស់លោកថាជាសាលាជាន់ខ្ពស់ខាងគំនិត ។ សោតឯតួអង្គក្នុងរឿងរបស់លោកគរ័ណី សុទ្ធតែជាកំពូលបុរស ដែលធ្វើសកម្មភាពសំរាប់តែបង្ហាញនូវទស្សនវិជ្ជាមួយបែបគឺ :

- ភាពថ្លៃថ្នូរនៃចរិតលក្ខណៈ
- ករណីយកិច្ចឈ្នះតណ្ហា

ប៉ុន្តែបើតាមសង្កេតអ្វីៗដែលជាទស្សនៈ ជាទ្រឹស្តី ជាគោលគំនិតរបស់លោក ច្រើនតែមានលក្ខណៈខ្ពស់ហួសពេក ។

មនុស្សបថុជ្ជនធម្មតាពិបាកនឹងអនុវត្តគោលគំនិតទាំងនោះណាស់ ។ មនុស្សតែងតែមិនអាចយកឈ្នះលើទឹកចិត្តខ្លួនឯងបានសោះ ជាពិសេសក្នុងសតវត្សនេះ ដែលមនុស្សក្លាយជាកញ្ជះតណ្ហាទៅហើយនោះ ។



## ម៉ូលីយែរ

Molière ( dit Jean - Baptiste Poquelin )
( Paris 1622 - id.1673 )

អ្នកនិពន្ធល្ខោននាដកម្មបារាំង ។ បិតាហាសនាដកម្មប្រចាំស.វទី១៧ ! លោកម៉ូលីយែរ គឺជាសិល្បករល្ខោននាដកម្ម និង ជាអ្នកនិពន្ធរឿងល្ខោនដ៏ល្បីឆ្នើម មានទេពកោសល្យខ្ពស់បំផុតខាងតាក់តែងរឿងប្រលោមលោក និងរឿងល្ខោនបែបកំប្លែង ។ ស្នាដៃទាំងឡាយរបស់លោក គឺសុទ្ធសឹងតែជារឿងល្ខោនដែលប្រយុទ្ធប្រឆាំងនឹងអំពើបាប ខិលខូច ដែលមាននៅក្នុងគំនិត ឬនៅក្នុងសង្គម... បោះជំរំតួអង្គយ៉ាងសឿងខ្ចង់ សង្ហា ដោយឧបមាយកជាការគំរូ... ជាមនុស្សម្នាក់ដែលធ្វើឱ្យពិភពអ្នកអក្សរសិល្ប៍និយម អស់សំណើចរាប់សតវត្សមកហើយ... ។

**<u>ជីវប្រវត្តិសង្ខេប</u> :**

លោកម៉ូលីយែរ មានឈ្មោះពិតប្រាកដថា ហ្សង់ បាប់ទីស្ត៍ ប៉ូគើឡាំង ។លោកកើតនៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៦២២ ក្នុងទីក្រុងប៉ារីស ។ ឪពុកលោកឈ្មោះ ហ្សង់ ប៉ូគើឡាំង ជាអ្នកលក់គ្រឿងសំអាងសំរាប់ស្តេច ។ លោកម៉ូលីយែរត្រូវកំព្រាម្តាយនៅអាយុ ១៣ឆ្នាំ ។ ពេលម្តាយលោកទទួល

មរណភាពទៅ ឪពុកលោកក៏រៀបការនឹងស្រីម្នាក់ទៀត ក៏ប៉ុន្តែជាអកុសល ក្រោយពីបានរួមរស់នៅជាមួយគ្នាបានបីឆ្នាំកន្លងមក ម្ដាយចុងរបស់លោក ក៏ទទួលអនិច្ចកម្មទៅទៀត ។

លោក ម៉ូលីយែរ បានចូលទៅសិក្សានៅអនុវិទ្យាល័យ ក្លែរម៉ុង ក្រោមការឧបត្ថម្ភពីជីតារបស់លោក ល្វី ក្រេស្សេ ។ នៅក្រៅអនុវិទ្យាល័យ លោកម៉ូលីយែរ បានឆ្លៀតសិក្សាទស្សនវិជ្ជាយ៉ាងព្យាយាមបំផុតជាមួយនឹង ទស្សនវិទូម្នាក់ឈ្មោះហ្គាស្សង់ឌី ( Gassendi, philosophe français (1592-1655) ។ លោក ហ្គាស្សង់ឌី បានខិតខំអប់រំលោកមូលីយែរ ឱ្យស្អប់ ហើយឱ្យប្រឆាំងជានិច្ចនឹងទស្សនវិជ្ជារបស់លោក អារីស្តូត ( Aristote, philosophe grec ( 384-322 av.J-C ) ។ ទស្សនវិជ្ជារបស់លោក ហ្គាស្សង់ឌី បានជ្រួតជ្រាបយ៉ាងខ្លាំងទៅក្នុងចិត្តថ្លើមរបស់លោក មូលីយែរ ។

លោកម៉ូលីយែរ បានប្រលងជាប់បរិញ្ញាបត្រច្បាប់ នៅអឡេអង់ ។ ចំណេះវិជ្ជាខាងច្បាប់នេះ គេឃើញលេចឡើងយ៉ាងច្បាស់នៅក្នុងវណ្ណកម្មដ៏ច្រើនរបស់លោក តែច្បាប់ទាំងនេះមានលក្ខណៈគ្រាន់តែជាច្បាប់អនុវត្ត ប៉ុណ្ណោះ ។

ក្រោយមក នៅពេលដែលឪពុករបស់លោកមានវ័យជរាណាស់ទៅហើយ លោកម៉ូលីយែរក៏បានទទួលកាន់កាប់មុខតំណែងជំនួស ហើយប្រកបអាជីវកម្មនេះបន្តពីឪពុករបស់លោករហូតរៀងមក ។

## ជីវិតក្នុងវង់ល្ខោន

នៅក្នុងឆ្នាំ ១៦៤៣ គេឃើញលោក ម៉ូលីយែរ ឡើងលើឆាកសំដែងជាលើកដំបូងបង្អស់ ក្នុងវង់ល្ខោនមួយដែលមានឈ្មោះថា "លីលុយស្រ្ត តេអាត្រ៍ " ( l' Illustre-Théâtre ) ។ វង់ល្ខោននេះជារបស់លោកផ្ទាល់ តែមានចូលហ៊ុនខ្លះដែរ ជាមួយនឹងគ្រួសារបេហ្សារត៍ ( Béjart ) ។

បានជាលោកម៉ូលីយែរ មានចិត្តជិតជាប់នឹងវិស័យល្ខោនបែបនេះ ព្រោះកាលពីក្មេង លោកតា ល្វី ក្រែស្សេ ចូលចិត្តនាំចៅគាត់ទៅទស្សនាល្ខោនជាញឹកញាប់ដងណាស់ ។ វង់ល្ខោនដែលលោកម៉ូលីយែរធ្លាប់បានទៅទស្សនាកំសាន្តច្រើនជាងគេ គឺវង់ល្ខោនម៉ារេ និង ល្ខោនដែលគេលេងនៅសណ្ឋាគារ ប៊ួរហ្គោញ ។ ហើយកាលពីលោកនៅក្នុងវ័យសិក្សានាអនុវិទ្យាល័យ ក្លែរម៉ុងនោះ លោកម៉ូលីយែរធ្លាប់បានឃើញកូនសិស្សគ្នាឯងសំដែងរឿងខ្លីៗក្នុងរាត្រីសិល្បៈជាច្រើនដងណាស់ដែរ ។

នៅក្នុងឆ្នាំ ១៦៤៤ វង់ល្ខោន l' Illustre-Théâtre ចាប់ផ្តើមធ្វើសកម្មភាពយ៉ាងពេញទំហឹង ។ ដំណើរក្នុងវង់ល្ខោនចេះតែប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាពយ៉ាងក្រៃលែង ។ ក៏ប៉ុន្តែចាប់តាំងពីពេលដែលមានលោកហ្គាស្តុង ដ័រលេអ៊ែនស៍ ( Gaston d' Orléans ) ចូលមកជ្រៀតជ្រែកកាលណា កិច្ចការល្ខោនដើរបែបមិនសូវស្រួលសោះ ប្រការនេះបណ្តាលឱ្យលោក ម៉ូលីយែរ មានជំពាក់ប្រាក់គេយ៉ាងច្រើន រហូតដល់ត្រូវគេចាប់ឃុំខ្លួន ។ រហូតមកដល់ខែសីហា ឆ្នាំ ១៦៤៥ លោកម៉ូលីយែរ បានទទួលការធានា ហើយក៏បានត្រូវគេដោះលែងឱ្យមានសេរីភាពមកវិញ ។ ចេញអំពីទីឃុំឃាំងកាលណា លោកម៉ូលីយែរក៏ចាប់ផ្តើមលេងល្ខោនបន្តទៅទៀត ។ ម្តងនេះ ក្រុមល្ខោនរបស់លោក ម៉ូលីយែរបានចូលសមាគមជាមួយក្រុម Du Fresne ដោយមានលោក Duc d' Epéron ប្រមុខក្រុង Guyenne ជាគោលបង្អែកផង ។

ចាប់តាំងពីឆ្នាំ ១៦៤៥ ដល់ឆ្នាំ ១៦៥០ វង់ល្ខោនរបស់លោកម៉ូលីយែរ បានលើកទៅលេងនៅគ្រប់ខេត្ត ដូចជាខេត្ត: Toulouse, Nantes, Narbonne, Albi, Carcassonne, Agen… ។ល។ និង ។ល។

ពីឆ្នាំ ១៦៥០ ដល់ឆ្នាំ ១៦៥៨ ក្រុមនេះបានលើកទៅសំដែងនៅ Lyon, Languedoc, Montpellier, Narbonne, Avignon, Grenoble, Béziers, … ។

នៅក្នុងអំឡុងពេលនេះ ពោលគឺនៅក្នុងឆ្នាំ ១៦៥៥ លោកម៉ូលីយែរ បានសំដែងរឿងមួយឈ្មោះ l' Étourdi នៅទីក្រុង Lyon ។ ហើយឆ្នាំ ១៦៥៦ លោកបានសំដែងរឿងមួយទៀតឈ្មោះ le Dépit amoureux នៅ Avignon ។

ឆ្នាំ ១៦៥៨ លោកម៉ូលីយែរ បានលើកវង់ល្ខោនមកសំដែងនៅទីក្រុង Rouen ។

លោកម៉ូលីយែរ បានដើរតួជាអ្នកសំដែងផង ហើយឆ្លៀតតាក់តែងរឿងល្ខោនផង ដែលរឿងទាំងអស់នោះច្រើនតែជារឿង "ហាសនាដកម្ម និងរឿង " ក្រម៉ាច់ " ។

## ជីវិតស្នេហារបស់លោក ម៉ូលីយែរ

លោកម៉ូលីយែរ ក៏ធ្លាប់ធ្លាក់ខ្លួនជាទាសៈនៃសេចក្តីស្នេហាដូចជាបុរសទាំងឡាយក្នុងលោកដែរ ។ លោកបានលួចស្រឡាញ់កូនក្រមុំគេម្នាក់នៃត្រកូលបេហ្សារត៍ ឈ្មោះនាងម៉ាដឺឡែន ( Madeleine ) ។ នាងមានរូបឆោមលោមពណ៌ល្អណាស់ ហើយថែមទាំងមានចំណេះដឹង និងប្រាជ្ញា

ឈ្លាសវៃណាស់ផង ។ លោកម៉ូលីយែរ ដែលក្លាយជាហាសនាដករដ៏ល្បីឆ្នើមនេះ ក៏ដោយសារតែគាត់មានសេចក្ដីស្នេហាលើរូបនាងម៉ាដឺឡែននេះឯង ។

តែមកដល់ឆ្នាំ ១៦៦២ មិនដឹងជាដោយសាររឿងអ្វី ស្រាប់តែគេឃើញលោក ម៉ូលីយែរ បែរជាទៅរៀបការជាមួយនឹងនាង អារម៉ង់បេហ្សារត៍ ( Armande) ទៅវិញ ។

## ជោគជ័យធំៗរបស់លោក ម៉ូលីយែរ

ក្នុងអំឡុងឆ្នាំ ១៦៥៨ វង់ល្ខោនរបស់លោកម៉ូលីយែរ បានវិលត្រឡប់មកកាន់ទីក្រុងប៉ារីសវិញ ។ កិត្តិស័ព្ទរបស់ l' Illustre Théâtre នាសម័យនោះ បានល្បីរន្ទឺ និងសាយភាយរហូតទៅដល់សំណាក់ព្រះរាជា ។

នៅពេលមួយនោះ ត្រូវនឹងថ្ងៃទី ២៤ តុលា ឆ្នាំ ១៦៥៨ វង់ល្ខោននេះត្រូវបានទទួលកិត្តិយសមកសំដែងថ្វាយស្ដេចទត ពេលនោះលោកម៉ូលីយែរ បានសំដែងរឿង Nicomède ដែលជាវណ្ណកម្មដ៏ឆ្នើមរបស់កវីគរ័ណៃ និងរឿងមួយទៀតឈ្មោះ le Docteur amoureux ។ គឺពេលនេះហើយដែលលោក ម៉ូលីយែរ បានទទួលកិត្តិស័ព្ទល្បីសុសសាយរហូតដល់

ស្តេចបើកអំណាចឱ្យវង់ល្ខោននេះ ចូលសំដែងបាននៅក្នុងវាំង នៅក្នុងបន្ទប់មួយឈ្មោះ Petit Bourdon ។

ក៏ប៉ុន្តែទោះជាដូច្នេះក្តី ក៏កេរ្តិ៍ឈ្មោះដ៏ល្បីរបស់លោក ម៉ូលីយែរ ពេលសំដែងថ្វាយស្តេចនាពេលនោះ នៅអន់ជាងកិត្តិនាមដែលលោកបានទទួលនៅពេលដែលលោកសំដែងរឿងមួយទៀតឈ្មោះ l' École des femmes ។ រឿងនេះ លោកម៉ូលីយែរ បានប្រឌិតឡើងតាមមនោគតិប្រាកដនិយមរបស់លោក និងជារឿងផ្ទាល់ខ្លួនរបស់ភរិយារបស់លោកទៀតផង ។ នាង អារម៉ង់ ភរិយារបស់លោក ម៉ូលីយែរ ជានារីដែលចូលចិត្តការតុបតែងខ្លួនខ្លាំងពេក ព្រមទាំងមានគំនិត "ថ្លៃថ្នូរនិយមហួសហេតុ" ផងដែលធ្វើឱ្យលោក ម៉ូលីយែរ អត់ទ្រាំទៀតមិនបាន លោកក៏តាក់តែងរឿង l' École des femmes នេះឡើង ។

នៅឆ្នាំ ១៦៧០ លោកម៉ូលីយែរ សំដែងរឿង le Bourgeois gentilhomme ។ លុះដល់ឆ្នាំ ១៦៧២ លោកបានសំដែងរឿង les Femmes savants ។ រឿងទាំងនេះសុទ្ធតែបានទទួលជោគជ័យយ៉ាងសំបើមក្រៃលែង ។

## អវសានកាលរបស់លោក ម៉ូលីយែរ :

លោកម៉ូលីយែរ គឺជាបុគ្គលមួយរូប ដែលបានបូជាកំលាំងកាយ កំលាំងចិត្ត និង កំលាំងប្រាជ្ញាស្ទើរតែទាំងអស់ក្នុងជីវិតរបស់លោកសំរាប់វិស័យសិល្បៈ ។ ការខិតខំព្យាយាមដ៏មោះមុត និងឱ្យហាតនេះ បានបណ្តាលឱ្យលោកធ្លាក់ខ្លួនមានជំងឺឈឺទ្រូង តាំងពីឆ្នាំ ១៦៦៥ មក ។ តែទោះបីជាជំងឺបានចូលមករាតត្បាតក្នុងសរីរាង្គកាយរបស់លោកយ៉ាងណាក៏ដោយ ក៏លោកម៉ូលីយែរនៅតែតស៊ូជានិច្ច គឺតស៊ូរហូតដល់ដង្ហើមចុងក្រោយ ។

ប្រវត្តិដែលគួរឱ្យរំភើប និង គួរឱ្យសោកសៅក្នុងមួយជីវិតសិល្បៈរបស់លោក ម៉ូលីយែរ ដែលអ្នកផងចងចាំមិនភ្លេចនោះ គឺនៅពេលចុងក្រោយបំផុតនៃការសំដែងរឿង le Malade imaginaire ស្រាប់តែលោក ម៉ូលីយែរ ដួលគ្រិបនៅលើឆាក ធ្វើឱ្យផ្អើលទស្សនិកជន... ។ ក្រោយពីពេលដែលគេបានដឹករូបលោកមកដល់លំនៅឋានបានបន្តិច លោកម៉ូលីយែរ ក៏ទទួលមរណភាពទៅ ។ ទុក្ខសោកវិយោគដែលផ្តើមចេញពីមរណភាពដ៏គួរឱ្យរំភើបហួសប្រមាណ នៃហាសនាដករដ៏មហាល្បីផ្អើមនេះ បានធ្វើឱ្យអ្នកដែលធ្លាប់បានទស្សនារឿងល្ខោនរបស់លោក មានការសោក

ស្លាយគ្រប់១ថ្នា ។ គេបានបញ្ចុះសពលោកនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៦៧៣ នៅវេលាម៉ោង ៩ យប់ ។

លោក ម៉ូលីយែរ បានលាចាកពីពិភពសោកសៅសំដៅទៅកាន់សុគតិភពក្នុងជន្មាយុ ៥១ ឆ្នាំ ។

## ចណ្ណកម្មនាំឲ្យខ្លាយរបស់លោក ម៉ូលីយែរ

គេអាចចែកស្នាដៃនិពន្ធរបស់លោកម៉ូលីយែរជាពីរផ្នែកដូចតទៅ :

១- **ផ្នែករឿងកំប្លែង** ( រឿងកំប្លែងខ្លីៗ )

- Le Docteur amoureux
- les Trois docteurs rivaux
- le Maître d' école
- Gros René
- Gorgions dans le sac
- le Fagoteux (Fagotier)
- Sganarelle
- la Jalousie de Barbouille
- le Médecin malgré lui ( 1666 ) រឿងក្រមាច់ដែលទទួលជោគជ័យដ៏ត្រចះត្រចង់ ។

## ២. ផ្នែកហាស្យនាដកម្ម

- l' Étourdie ( 1655 )
- le Dépit amoureux ( 1656 )
- l' Impromptu de Versailles
- Don Garcie de Naivarre
- les Précieuses ridicules ( 1659 ) ចំអកឱ្យពួកស្រីៗ ដែលចូលចិត្តអួតខ្លួនថាជាអ្នកចេះដឹង ។
- les Facheux ( 1661 )
- l' Écoles des maris ( 1661 )
- l' École des femmes (1662 )
- Critique de l' École des femmes
- Dom Juan (1665 )
- l' Amour médecin ( 1665 ) ចំអកឱ្យពួកពេទ្យនៅក្នុងវាំង ។
- le Misanthrope ( 1666 ) ចំអកដល់សង្គមមនុស្ស ដែលពោរពេញទៅដោយការបោកបញ្ឆោត ភូតភរ ក្រឡិចក្រឡុច បញ្ឆោរ បញ្ជើចបញ្ជើរ ។

- Malicerte
- Amphitryon ( 1668 )
- la Princesse d' Élide ( ទទួលប្រតិកម្មពីព្រះសង្ឃកាតូលិក )
- George Dandin (1668 )
- l' Avare ( 1668 ) ចំអកដល់ភាពកំណាញ់ស្វិតដែលធ្វើឱ្យមនុស្សលែងស្គាល់អ្វីក្រៅពីលុយ ។
- le Mariage forcé
- le Sicilien ou l' Amour peintre
- Panulphe l' imposteur
- Tartuffe ( 1669 ) ទទួលប្រតិកម្មពីព្រះសង្ឃកាតូលិក ។
- les Amants magnifiques
- Monsieur de Pourceaugnac ( 1669 )
- le Bourgeois gentilhomme ( 1670 ) ចំអកឱ្យអភិជនកំឡៅ ។
- Hypocondre
- la Comtesse d' Escarbagnas ( 1671 )

- les Fourberies de Scapin ( 1671 )
- les Femmes savantes ( 1672 ) ចំអកចំពោះភាពក្រអឺតក្រទមនៃស្ត្រី ។
- le Malade imaginaire ( 1673 )

## ឧត្តមគតិ
## និង ទស្សនៈអក្សរសិល្ប៍របស់លោក ម៉ូលីយែរ

ទស្សនៈនិយមដែលនាំឱ្យលោក ម៉ូលីយែរ ទទួលបាននូវជោគជ័យដ៏ខ្ពង់ខ្ពស់ត្រដែតត្រដឹមក្នុងផ្នែកអក្សរសិល្ប៍នោះ គឺស្ថិតនៅត្រង់គំនិត តថនិយម និង ប្រាកដនិយមរបស់លោក ។

វណ្ណកម្មទាំងឡាយរបស់លោក ម៉ូលីយែរ សុទ្ធតែបានបង្ហាញឱ្យឃើញនូវគុណសម្បត្តិ និងគុណវិបត្តិរបស់មនុស្សគ្រប់សង្គម ( សង្គមបារាំងសែស ) គ្រប់កាលសម័យ ។ ដោយសារស្នាដៃរបស់លោក មហាជនអាចស្គាល់នូវមុខមាត់ពិតប្រាកដនៃសង្គមបារាំងសែសនាស.វទី ១៧ នោះបានយ៉ាងច្បាស់ ។ លោកម៉ូលីយែរ ចូលចិត្តអ្វីៗដែលមានភាពជាក់ច្បាស់ និង

រឿងរ៉ាវបែបតថៈ ហើយដែលធ្លាប់កើតមានពិតប្រាកដក្នុងជីវភាពមនុស្សលោកផង ។

ទោះបីរឿងរបស់លោកជារឿងកំប្លែងក្តី ក៏ការកំប្លែងនោះស្ថិតនៅក្នុងក្របខ័ណ្ឌនៃការពិតជាដរាប ។ លោកយល់ថា ការពិត និង ការសប្បាយត្រូវតែធ្វើដំណើរទៅជាមួយគ្នាក្នុងដំណើររឿង ។ រឿងកំប្លែងមួយដែលបានធ្វើឱ្យអ្នកអាន អ្នកទស្សនាបានសើច បានសប្បាយ តែបើសើចបើសប្បាយទាំងគ្មានន័យនោះ រឿងនោះក៏ប្រាកដជាគ្មានតំលៃអ្វីក្នុងវិស័យអក្សរសិល្ប៍ និង សិល្បៈទេ ។

លក្ខណៈមួយទៀត ដែលគួរឱ្យកត់សំគាល់នៅក្នុងស្នាដៃរបស់លោក ម៉ូលីយែរនោះ គឺការអប់រំ ។ លោក ម៉ូលីយែរ មិនដែលភ្លេចនឹងបញ្ចូលទៅក្នុងផ្ទៃរឿងនូវការអប់រំដ៏ប្រពៃទាំងឡាយសោះឡើយ ហើយការអប់រំទាំងនោះគឺសុទ្ធតែមានទិសដៅឆ្ពោះទៅរកការកែប្រែ នូវទស្សនៈនិយមដ៏ចាស់គំរិលផ្សេងៗ ព្រមទាំងកែប្រែជំនឿ និង ទំនៀមទំលាប់ទាំងឡាយណាដែលលោកយល់ថា ជាការមិនគប្បី ។ ការអប់រំរបស់លោក ម៉ូលីយែរ សឹងប្រកបទៅដោយលក្ខណៈមនុស្សនិយម ហើយសាមញ្ញជាទីបំផុត ដែលមានប្រយោជន៍យ៉ាងពិសេសសំរាប់មនុស្សយើង ។ លោកម៉ូលីយែរ ពុំបានអប់រំមនុស្សដោយបញ្ចូលទ្រឹស្តីសាសនា ឬវាយអែបស៊ីអបនឹងគោលលទ្ធិណា

មួយឡើយ ព្រោះថា លោកម៉ូលីយែរពុំមែនជាអ្នកឱ្យតំលៃដល់សាសនាណាមួយទេ ។ ដូច្នេះហើយបានជាកាលពីឆ្នាំ ១៦៦៤ នៅពេលដែលលោកម៉ូលីយែរ សំដែងរឿង Tartuffe និង រឿង la Princesse d' Élide នោះ ព្រះសង្ឃកាតូលិកនៅប៉ារីសបានបញ្ចេញប្រតិកម្មយ៉ាងខ្លាំង ប្រឆាំងនឹងរូបលោក រីឯស្តេចទៀតសោត ក៏ឃាត់ឃាំងមិនឱ្យលោក ម៉ូលីយែរ សំដែងជាសាធារណៈដែរ មិនតែប៉ុណ្ណោះ លោកអាចារ្យ រូយ៉េ ចង់សុំយកលោក ម៉ូលីយែរ ទៅដុតចោលទាំងរស់ទៀតផង ។ រឿងហេតុទាំងអស់នេះបានលេចឡើងយ៉ាងជាក់ស្តែងនៅពេលដែលលោក ម៉ូលីយែរជិតស្លាប់ គឺគ្មានបព្វជិតអង្គណាមកឱ្យធម៌ដល់រូបលោកសោះទេ ។ ហើយដោយសារតែមិនបានទទួលធម៌អាថ៌នេះហើយ ដែលសពរបស់លោក ម៉ូលីយែរ ត្រូវបានអ្នកបួសក្នុងសាសនាកាតូលិក ហាមឃាត់មិនឱ្យយកទៅបញ្ចុះ ។ តែបន្ទាប់ពីមានការតវ៉ាដ៏មុឹងម៉ាត់មក ព្រះសង្ឃរាជក៏អនុញ្ញាតទាំងទើសទាល់ឱ្យបញ្ចុះទៅ ក៏ប៉ុន្តែមិនឱ្យមានភ្លេងភ្លាត់អ្វីទេ ថែមទាំងឱ្យគេយកសពរបស់លោកទៅបញ្ចុះនៅពេលយប់ទៀតផង ។ ហេតុការណ៍ទាំងអស់នេះ គឺបណ្តាលមកតែពីគំនិតពុំស្របស្រួលជាមួយនឹងសាសនារបស់លោកម៉ូលីយែរនេះឯង ។

នៅក្នុងស្នាដៃដ៏ច្រើនសន្ធឹកសន្ធាប់របស់លោកម៉ូលីយែរ គេពុំឃើញមានទាល់តែសោះនូវស្នារតីពលីកម្ម ឬការតស៊ូបូរផ្តាច់ក្នុងការការពារឧត្តមគតិណាមួយដូចក្នុងរឿងរបស់លោក ព្យែរ គរ៍ណើ ឡើយ ។ តួអង្គក្នុងរឿងរបស់លោក ម៉ូលីយែរ មានតាំងតែពី អភិជន មហាសេដ្ឋី អ្នកមានសម្បត្តិហូរហៀរ អ្នកក្រីក្រ រហូតដល់ខ្ញុំកញ្ជះគេ ។ លោកម៉ូលីយែរចូលចិត្តទិតៀនពួកអ្នកថ្លៃថ្នូរនិយមណាស់ ហើយក៏ចូលចិត្ត " ត្បក " ឱ្យពួកអភិជនកំឡោទាំងនោះខ្លាំងណាស់ដែរ ។ ពួកនេះបើបានទស្សនារឿងរបស់លោក ម៉ូលីយែរម្តងៗ ពួកគេនឹងបានសើចសប្បាយ គឺបានសើចសប្បាយយ៉ាងសប្បាយអស្ចារ្យក្រៃលែង ក៏ប៉ុន្តែការសើចសប្បាយរីករាយដ៏ក្រៃលែងនោះ គឺមានរសជាតិល្វីងជូរចត់ជាទីបំផុត ។ ហើយបើពួកនេះរឹតតែគិត រឹតតែពិចារណាឱ្យបានខ្លាំងក្លាក្នុងឱកាស ដែលខ្លួនកំពុងទស្សនា និង ក្រោយការទស្សនារឿងល្ខោនរបស់លោកម៉ូលីយែរនោះ ពួកគេក៏រឹតតែដឹងខ្លួនខ្លាំងឡើងណាស់ដែរថា លោកម៉ូលីយែរកំពុងតែ " ខោកក្បាល ", ឱ្យពួកគេទេតើ !!!

## ទស្សនៈចំពោះស្នេហា និង តណ្ហារបស់លោក ម៉ូលីយែរ

ចំពោះស្នេហា លោកម៉ូលីយែរ ក៏យល់ដូចគេឯងដែរថា វាត្រូវឱ្យបានផុសចេញមកពីដួងចិត្តដ៏បរិសុទ្ធនៃមនុស្សម្នាក់ៗ ។ គេត្រូវជៀសវាង

នូវសេចក្តីស្នេហាណាដែលបង្ខិតបង្ខំជាដាច់ខាត ។ ចំណងអាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រីជាភារៈមួយដែលបរិសុទ្ធ និង ពិសិដ្ឋក្រៃលែង ។ ដើម្បីឱ្យមង្គលការស្ថិតនៅក្នុងសុភមង្គលអស់កាលជានិច្ចនោះ គួរតែគូស្នេហ៍ទាំងសងខាងស្គាល់ ហើយយល់ចិត្តថ្លើមគ្នាទៅវិញទៅមក ព្រមទាំងមានអាយុស្របាល១គ្នាផង ។ កុំធ្វើដូចជាកញ្ជាស់ឈ្មោះ Harpagon នៅក្នុងរឿង l' Avare ដែលចង់រៀបការនឹងនារីក្មេងនោះ វាមិនល្អមើលទាល់តែសោះ ។

លោកម៉ូលីយែរ មានបំណងចង់ឱ្យមនុស្សអនុវត្តអ្វី១តាមធម្មជាតិ។ ប៉ុន្តែការអនុលោមតាមធម្មជាតិនេះ ត្រូវតែឱ្យមានលាយឡំជាមួយផងដែរនូវវិចារណញ្ញាណ និង សុភវិនិច្ឆ័យ គេមិនត្រូវបណ្តែតបណ្តោយទាំងងងឹតងងល់ ឱ្យអ្វី១ប្រព្រឹត្តទៅតាមតែការចាត់ចែងរបស់ធម្មជាតិនោះឡើយ ។ លោកម៉ូលីយែរ ពុំមានគំនិតទុទិដ្ឋិនិយមពេកទេចំពោះតណ្ហា ព្រោះអីតណ្ហាមិនមែនសុទ្ធតែជាប្រភពនៃសេចក្តីទុក្ខសោកទាំងអស់ទេ ព្រោះជួនកាលវាក៏ផ្តល់មកឱ្យមនុស្សនូវសេចក្តីចំរើនផងដែរ ។

## លក្ខណៈនៃរឿងកំប្លែងរបស់លោក ម៉ូលីយែរ

រឿងកំប្លែងទាំងឡាយរបស់លោកម៉ូលីយែរ ប្រកបដោយលក្ខណៈ

បីយ៉ាងដូចៗគ្នាទាំងអស់ ។ លក្ខណៈទាំងបីយ៉ាងនោះមានដូចតទៅ :

១- កំប្លែងតាមផ្លូវសំដី វោហារ ពាក្យពេចន៍លែបខាយ

២- កំប្លែងតាមកាយវិការ ឫកពា ចរិយារបស់តួអង្គ

៣- កំប្លែងក្នុងដំណើររឿង

ស្នាដៃរបស់លោក ម៉ូលីយែរ មានលក្ខណៈជាការពិនិត្យសង្កេត "ចរិតធម្មជាតិ" និងការឆ្កាំឆ្កងទាំងឡាយរបស់មនុស្ស ( les travers humains ) ។ លោក ម៉ូលីយែរ ជាអ្នកមានការសង្កេតត្រិះរិះល្អិតល្អន់ណាស់នូវជំរៅចិត្តរបស់មនុស្ស ។ គឺដោយសារទេពកោសល្យនេះហើយដែលជាហេតុនាំឱ្យលោកអាចសរសេររឿងបានល្អៗណាស់ ជាពិសេសរឿងដែលមានលក្ខណៈជា " ការធ្វើវិភាគនូវអាកប្បកិរិយារបស់មនុស្ស ( analyse des caractères humains ) ។

តួអង្គទាំងឡាយរបស់លោកម៉ូលីយែរ សុទ្ធសឹងជាតួអង្គគំរូតំណាងនូវទស្សនៈ លក្ខណៈចិត្តថ្លើមរបស់មនុស្សគ្រប់សម័យកាល និង គ្រប់ទីកន្លែង ។ លោកម៉ូលីយែរ ចូលចិត្តបើកកកាយឱ្យទស្សនិកជន និងអ្នកផងទាំងឡាយរបស់លោក បានឃើញនូវគុណវិបត្តិផ្សេងៗរបស់មនុស្សដូចជា :

- ចរិតក្រឡិចក្រឡុច ឧបាយកល ( intrigue )

- ភាពកំណាញ់ស្វិត (avarice )
- ការវាយឫក ឬ អំនួតចំណេះ ( pédantisme )
- អំនួតក្អេងក្អាង ( vanité )

រឿង " le Misanthrope " ជារឿងដែលគេចាត់ទុកថាជារឿងមួយដ៏ល្អផ្ដាច់គេ ក្នុងចំណោមស្នាដៃទិតៀន " លក្ខណៈបុគ្គល " ។ ក្រោយពេលដែលលោក ម៉ូលីយែរ យករឿងនេះទៅសំដែងលើឆាក មានសារពត៌មានមួយបានសរសេរសរសើរថា : **រឿង *le Misanthrope* នេះ គឺជាវណ្ណកម្មដ៏អស្ចារ្យ សឹងតែថារកអ្នកនិពន្ធណាមួយមកប្រៀបផ្ទឹមពុំបានផង** ។

## អវសានបទ

លោកម៉ូលីយែរ ពុំមែនគ្រាន់តែជា " បិតាហាសនាដកម្ម " ប៉ុណ្ណោះទេ តាមការពិតគេសង្កេតឃើញថា លោកម៉ូលីយែរគឺជាអ្នកនិពន្ធដ៏ឆើតមួយរូប ដែលប្រកបទៅដោយទស្សនៈយ៉ាងប្រសើរ ស្ដីពីការវិវត្តន៍ចិត្តរបស់មនុស្ស ។ មួយចំណែកទៀត លោកបានលាតត្រដាងនូវការពិតរបស់មនុស្ស ដែលទាក់ទងជាពិសេសទៅលើគោលគំនិត ទស្សនៈ និង លក្ខណៈទូទៅដោយឥតរើសមុខ ។

លោកម៉ូលីយែរ ជាអ្នកប៉ិនប្រសប់ក្នុងការសង្កេតពិនិត្យនូវទឹកចិត្តមនុស្សទូទៅនៅក្នុងសង្គមរបស់លោក ។ ព្រោះថាតួអង្គដែលលោកបានបង្កើតឡើងនៅក្នុងរឿងនិពន្ធរបស់លោក សុទ្ធសឹងតែជាតួអង្គគំរូ ជាតួអង្គដែលតំណាងនូវការវិយោគនៃទឹកចិត្តរបស់មនុស្ស និង លក្ខណៈនៃមនុស្សទូទៅផ្សេងៗពីគ្នា ។

ទស្សនៈនេះ បានឆ្លុះឱ្យឃើញនូវការពិតជារៀងរហូត មកដល់បច្ចុប្បន្នយើងនេះ ។

គឺដោយសារទេពកោសល្យដ៏ល្បីឆ្មើមអស្ចារ្យរបស់លោក ម៉ូលីយែរនេះឯងហើយ ដែលនាំឱ្យស្ដេចល្វីសទី ១៤ ( Louis XIV ( 1638-1715 ) អត់មិនបាន ព្រះអង្គក៏ត្រាស់សួរទៅអ្នកនិពន្ធ ប៊ិរឡូថា : " តើសតវត្សយើងនេះ លោកណាដែលល្បីល្បាញជាងគេ ? "

ពេលនោះលោក ប៊ិរឡូ ក៏បានឆ្លើយឡើងថា : **គឺលោក ម៉ូលីយែរនេះឯង** ។



## ហ្សង់ រ៉ាស៊ីន

JEAN RACINE
( La Ferté-Milon 1639-Paris 1699 )

កវីល្ខោននាដកម្មបារាំង ។ អ្នកនិពន្ធដែលស្ថិតនៅក្រោមឥទ្ធិពលនៃតណ្ហា ។ នៅក្នុងស្នាដៃទាំងឡាយរបស់លោក លោករ៉ាស៊ីន សុទ្ធតែបានបង្ហាញនូវសកម្មភាពមួយយ៉ាងសាមញ្ញ ជាក់លាក់ ដែលឧប្បត្តិហេតុទាំងឡាយ ( les péripéties ) កើតឡើងពីតណ្ហាដូចគ្នាទៅនឹងតួអង្គ ដោយបានធ្វើការវិភាគនូវគំនិតនៃសោកនាដកម្មបុរាណ បានសមល្អឥតខ្ចោះ ។

### ជីវប្រវត្តិសង្ខេប :

លោក ហ្សង់រ៉ាស៊ីន កើតនៅថ្ងៃទី ២២ ធ្នូ ឆ្នាំ ១៦៣៩ នៅក្រុងហ្វារតេ-មីឡុង ក្នុងភូមិភាគ សំប៉ាញ ( Champagne ) ។ ឪពុករបស់លោក ជាអភិបាលជង្រុកអំបិលនៅមីឡុង ម្ដាយរបស់លោកជាបុត្រីរបស់លោក ព្យែរ ស្គណាំង ដែលជាព្រះរាជអាជ្ញាក្រសួងគង្គារក្ខា ។ គ្រួសាររបស់លោកហ្សង់ រាស៊ីន មានឋានៈជាអភិជន ហើយជាអ្នកប្រកាន់ជឿស៊ប់ទៅលើលទ្ធិសាសនា ហ្សង់សេនីស ( Jansénisme ) ។

ប៉ុន្តែជាអភ័ព្វ លោកប៉ាស៊ីនត្រូវកំព្រាឪពុកម្ដាយតាំងពីនៅតូចម្ល៉េះ ។ ម្ដាយរបស់លោកស្លាប់នៅថ្ងៃទី ២៨ ខែមករា ឆ្នាំ ១៦៤១ បន្ទាប់ពីឆ្លងទន្លេបានកូនស្រីមួយ ចំណែកឯឪពុករបស់លោកក៏ទៅរៀបការនឹងស្រីថ្មីទៀត ។ ហើយក្រោយមក មិនបានប៉ុន្មានឆ្នាំផង ឪពុករបស់លោកប៉ាស៊ីនក៏ទទួលអនិច្ចកម្មទៅ ដោយបន្សល់ទុកនូវបំណុលជាច្រើន ។

ចាប់តាំងពីពេលដែលមាតាបិតាទទួលអនិច្ចកម្មអស់ទៅ លោកប៉ាស៊ីន និងប្អូនស្រីរបស់លោកឈ្មោះ ម៉ារី ក៏បានទៅរស់នៅជាមួយនឹងជីដូនជីតាទាំងសងខាង ។ កុមារី ម៉ារី ត្រូវបានគ្រួសារខាងឪពុកយកទៅចិញ្ចឹម ។ បងប្អូនកំព្រាទាំងពីរនាក់នេះ ត្រូវឃ្លាតចេញពីគ្នា ហើយដាច់ការទាក់ទងគ្នាជារៀងរហូត ។

ជីដូនដែលចិញ្ចឹមលោក ប៉ាស៊ីន មានឈ្មោះថា ម៉ារីដឺមូឡាំង ។ ជីដូននេះពេលក្រោយមកក៏ធ្លាក់ខ្លួនក្រីក្រតោកយ៉ាកយ៉ាងខ្លាំង ។ ហេតុដូច្នេះបន្ទាប់មកគាត់ក៏នាំលោក ប៉ាស៊ីនទៅរស់នៅឯ ពរ័-រ៉ូយ៉ាល់ វិញ ។

ក្នុងពេលអាយុ ១៦ ឆ្នាំ លោកប៉ាស៊ីន បានចូលទៅសិក្សានៅក្នុងសាលាមួយឈ្មោះ Granges ដែលស្ថិតនៅក្បែរ ពរ័-រ៉ូយ៉ាល់ ។ សាស្ត្រាចារ្យសំខាន់ៗ ដែលបានអប់រំបង្ហាត់បង្រៀនលោកប៉ាស៊ីន មានបួននាក់គឺ :

- លោក ឡង់ សឺឡូ ( LANCELOT ( dom Claude ), l'un des Messieurs de Port-Royal ( Paris.v.1615-Quimperlé 1695 ). Il contribua a la fondation des Petites Écoles de Port-Royal et écrivit une " Grammaire générale et raisonnée " dite " Grammaire de Port-Royal " )

- លោក ឡឺម៉ែស្រ្ត ( LEMAISTRE (Isaac), dit LEMAISTRE DE SACY, écrivain français ( Paris 1613-Pomponne 1684 ) . Il fut le directeur spirituel des religieuses de Port-Royal.Sa traduction française de la Vulgate eut un grand succes jusqu' au XIX$^{e}$ s )

- លោក នីកូល ( NICOLE (Pierre), éerivain francais ( Chartres 1625-Paris 1695 ) jansénist et professeur à Port-Royal, auteur " d' Essais de morale ( 1671-1678 ) )

- លោក ហាម៉ុង ជាសាស្រ្តាចារ្យមួយរូប ដែលលោករ៉ាស៊ីន ស្រឡាញ់ និង គោរពជាងគេ ។ សាស្រ្តាចារ្យទាំងនេះ សុទ្ធតែជាអ្នកប្រដៅ សាសនា " ហ្សង់សេនីស " ដ៏ល្បីល្បាញក្នុងសម័យនោះ ។ លោក ហ្សង់ រ៉ាស៊ីន បានទទួលឥទ្ធិពលដ៏ខ្លាំងក្លាអំពីសំណាក់អស់លោកទាំងនេះ ។ ក្រៅ ពីបានអប់រំ លោករ៉ាស៊ីន ឱ្យគោរព និង មានជំនឿយ៉ាងស្មោះស្ម័គ្រលើលទ្ធិ ហ្សង់សេនីស " សាស្រ្តាចារ្យទាំងនោះក៏បានបង្រៀនលោក រ៉ាស៊ីន ឱ្យ

ចេះនូវមុខវិជ្ជាអក្សរសាស្ត្រដែរ ។ គេបាននាំលោក រ៉ាស៊ីន ឱ្យអានវណ្ណកម្ម របស់អ្នកនិពន្ធជាតិ ហុល្លង់ដ៏ ( hollandais ) ដ៏ល្បីៗទាំងឡាយ ។

នៅពេលអាយុ ១៩ ឆ្នាំ លោករ៉ាស៊ីនបានចេញទៅបន្តការសិក្សាផ្នែកទស្សនវិជ្ជានៅឯទីក្រុងបារីសទៀត ។

នៅឆ្នាំ ១៦៥៤-១៦៥៥ លោករ៉ាស៊ីនបានសិក្សានៅអនុវិទ្យាល័យ បូវៃ ដែលជាមជ្ឈមណ្ឌលមួយ ស្ថិតនៅក្រោមឥទ្ធិពលនៃពួកអ្នកកាន់សាសនា ប្រូតេស្តង់ ( protestant ) ។

លោក រ៉ាស៊ីន ធ្លាប់បានសិក្សាភាសាក្រិក អំពីភាសាវិទូម្នាក់ឈ្មោះ ឡង់ ស៊ីឡូ ។ រៀនភាសានេះបានប្រហែល១ឆ្នាំ លោកក៏អាចអានអត្ថបទល្ខោនទារុណកថារបស់លោក សូហ្វូកឹល និងលោក អឺរីពីដ បានយ៉ាងធូរ ( Sophocle & Euripide-លោកទាំងពីរនេះ គឺជាកវីសោកនាដកម្មក្រិកបុរាណ ) ។

នៅទីក្រុងប៉ារីស លោករ៉ាស៊ីនបានស្គាល់អ្នកនិពន្ធល្បីៗជាច្រើនដូចជាកវី ឡាម៉ាទីន ( Alphonse de LAMARTINE, poète et homme politique français ១៨៦៩ ) ។ ក្រៅពីនេះ លោករ៉ាស៊ីន

បានចងមិត្តជាមួយ លោក ប៊ិរឡូ មូលីយែរ ដែលសុទ្ធតែជាអ្នកនិពន្ធដ៏ឆ្នើមប្រចាំសតវត្សនោះ ។

ថ្ងៃមួយ នៅក្នុងវាំងមានប្រារព្ធធ្វើពិធីបុណ្យរាជាភិសេក ។ ឆ្លៀតឱកាសនោះ លោករ៉ាស៊ីនបានតែងពាក្យកាព្យយ៉ាងវែងមួយឈ្មោះ " វុក្ខទេវីនៃជលសីមាសែន " ( la Nymphe de la Seine ) យកទៅប្រលង ហើយបានប្រាក់រង្វាន់ចំនួនមួយរយល្វី ( louis-ancienne monnaie d' or française )។ ជោគជ័យនេះបាននាំមកនូវកិត្តិយសយ៉ាងច្រើនដល់លោករ៉ាស៊ីន ។

ប៉ុន្តែជោគជ័យនេះ ពុំបានធ្វើឱ្យញាតិមិត្ត ព្រមទាំងសាស្ត្រាចារ្យទាំងឡាយរបស់លោកសប្បាយចិត្តសោះឡើយ ។ ពួកនេះខិតខំរកមធ្យោបាយ ដើម្បីអូសទាញរូបលោកឱ្យចេញផុតពីរង្វង់អក្សរសិល្ប៍វិញ។ ពួកគេគ្មានបំណងចង់ឱ្យលោករ៉ាស៊ីនក្លាយជាកវីនិពន្ធទេ ប៉ុន្តែគេចង់ឱ្យលោកក្លាយទៅជាអ្នកមានភក្តីភាពចំពោះសាសនាវិញ ។ ចំណែកឯលោករ៉ាស៊ីនខ្លួនឯង បានប្រឹងប្រែងគ្រប់មធ្យោបាយដែរ ដើម្បីឱ្យបានរស់នៅក្នុងក្រុងប៉ារីស ហើយដើម្បីធ្វើការទាក់ទងជាមួយនឹងអ្នកនិពន្ធល្បីៗទាំងឡាយ ។

លោករ៉ាស៊ីន បានប្ដេជ្ញាចិត្តហើយថា ទោះបីមានឧបស័គ្គរាំងរាយ៉ាងណាក៏ដោយ ក៏រូបលោកនៅតែខំប្រឹងប្រែងធ្វើការបំរើសិល្បៈ និង អក្សរសិល្ប៍ឱ្យខាងតែបាន ។

លោករ៉ាស៊ីន បាននិពន្ធជាលើកដំបូងនូវរឿងល្ខោនពីរគឺ : ឡាតេបែដ ( la Thébäde ) និង អាឡេចសង់ដ្រឺ ឡឺ ហ្គ្រង់ ( Alexandre le Grand ) ដែលបានទទួលជោគជ័យដ៏ល្បីខ្ចរខ្ចារ ។ ប៉ុន្តែផ្ទុយទៅវិញ ពួកអ្នកស្រុក ពរ័-រ៉ូយ៉ាល់ លែងរាប់អានលោករ៉ាស៊ីនទៀតហើយ ។ ពួកគេគ្មានភ្ញាក់ផ្អើលអ្វីនឹងជោគជ័យរបស់លោកទេ ។ ចំណែកឯសាស្ត្រាចារ្យទាំងឡាយរបស់លោកវិញ ក៏បាននាំគ្នាជៀលគ្នះដល់រូបលោកដែរ ។ លោកសាស្ត្រាចារ្យនីកូល បានផ្ញើលិខិតមួយច្បាប់មកលោករ៉ាស៊ីន ដែលក្នុងនោះសុទ្ធតែជាពាក្យបន្ដុះបង្អាប់ និង ជេរប្រមាថ ។ មិនតែប៉ុណ្ណោះ លោកសាស្ត្រាចារ្យនីកូល ថែមទាំងបានចោទថា : " អ្នកនិពន្ធរឿងល្ខោនទាំងឡាយសុទ្ធតែជាមនុស្សឆ្កួត " ។

លោកនីកូលបានសរសេរទៀតថា : " ពួកអ្នកសរសេរប្រលោមលោក និងអត្ថបទល្ខោន សុទ្ធតែជាអ្នកបំពុលមហាជន និងសាសនិកទាំងអស់ ហើយមិនមែនបំពុលតែត្រឹមផ្លូវកាយទេ-ប៉ុន្តែបំពុលទាំងផ្លូវចិត្តទៀតផង " ។

ពេលនោះ ដោយអត់ទ្រាំមិនបាន លោកវ៉ាស៊ីនក៏បានសរសេរសំបុត្រមួយតបទៅវិញដោយក្តីមួរហ្មង ដែលមានសេចក្តីជាអាទិ៍ថា : " តើលោកអាចប្រើពាក្យឱ្យបានស្រាល ហើយឱ្យបានគួរសមជាងពាក្យថា " បំពុលមហាជន " បានទេ ? "

ប៉ុន្មានឆ្នាំក្រោយមក បន្ទាប់ពី " វិបត្តិជោគជ័យ " របស់លោកបានស្ងប់បន្តិចហើយ គេឃើញលោកវ៉ាស៊ីន បានទៅទាក់ទងខាងផ្លូវស្នេហាយ៉ាងសំងាត់ជាមួយតួឯកស្រីដ៏ស្អាតម្នាក់ឈ្មោះនាង ថេរែស ដុយប៉ាក ។ លោកវ៉ាស៊ីន ទំនងជាបានរៀបការជាមួយនាងនេះផងក៏មិនដឹង ។ ក៏ប៉ុន្តែក្រោយមកមិនដឹងជាអកុសលអ្វី ស្រាប់តែសង្សាររបស់លោកវ៉ាស៊ីននេះ ធ្វើមរណកាលទៅក្នុងសភាពជាអាថិកំបាំងយ៉ាងក្រៃលែង ។ ម្តាយរបស់នាងស្រីនេះបានចោទប្រកាន់យ៉ាងចេញមុខថា គឺរូបលោកវ៉ាស៊ីននេះឯងជាអ្នកសំលាប់កូនស្រីរបស់គាត់ ។

បន្ទាប់ពីមានការចោទប្រកាន់នេះមក ស្រាប់តែមានដីកាចាប់ខ្លួនលោកវ៉ាស៊ីនមួយចេញមក ដោយមានចារថា ចាប់ខ្លួនពីបទមនុស្សឃាត ។ ក៏ប៉ុន្តែពេលនោះជាសំណាងល្អ លោកវ៉ាស៊ីន ត្រូវបានរួចខ្លួនវិញ ព្រោះតែមានការជួយធ្វើអន្តរាគមន៍អំពីមន្ត្រីជាន់ខ្ពស់ម្នាក់ ។

នៅក្នុងឆ្នាំ ១៦៥៧ លោករ៉ាស៊ីន បានអនុញ្ញាតឱ្យគេយកអត្ថបទល្ខោនទារុណកថាជាច្រើនទៅសំដែងនៅឯសណ្ឋាគារ ហើយដែលភាគច្រើនរឿងទាំងអស់នេះសុទ្ធតែទទួលបានជោគជ័យ ។

នៅឆ្នាំ ១៦៧០ លោករ៉ាស៊ីន មានទំនាស់មួយយ៉ាងធំជាមួយលោក ព្យែរ គ័រណី និងលោក ហ្កុងតឺណែល ។ ទំនាស់នេះ មានប្រភពពីរឿងល្ខោននេះឯង ។ ក្រោយមកលោករ៉ាស៊ីន បានទាស់ជាមួយលោកម៉ូលីយែរ ព្រោះតែរឿងស្រីរបាំម្នាក់ ។ ក្នុងរឿងនេះ អ្នកផងបាននិយាយថា លោករ៉ាស៊ីន មិនគួរទាស់ជាមួយលោកម៉ូលីយែរសោះ ព្រោះថាគឺលោកម៉ូលីយែរនេះឯងហើយ ដែលជាអ្នកជួយផ្តួងផ្តើមខ្លួនឱ្យមានការល្បួតលាស់នៅក្នុងកិច្ចការនិពន្ធផ្សេងៗ ។

នៅក្នុងឆ្នាំ ១៦៧០ លោករ៉ាស៊ីន ត្រូវបានចូលជាសមាជិកនៃបណ្ឌិតសភាអក្សរសាស្ត្របារាំង ។ ហើយនៅឆ្នាំ ១៦៧៤ លោកត្រូវបានគេតែងតាំងជាទីប្រឹក្សាពិសេសនៃព្រះមហាក្សត្រ ។

គួរកត់សំគាល់ថា នៅពេលមួយនោះ គឺត្រូវនឹងថ្ងៃទី០១ មករា ឆ្នាំ ១៦៧៧ ពេលដែលកិត្តិយសរបស់លោក កំពុងតែល្បីរន្ទឺសុះសាយនោះស្រាប់តែលោករ៉ាស៊ីនបោះបង់កិច្ចការនិពន្ធ និងវង់ល្ខោនទាំងអស់ ។ ការបាត់ខ្លួនរបស់លោករ៉ាស៊ីនពីពិភពអ្នកអក្សរសិល្ប៍បែបនេះ នាំឱ្យមានការ

បកស្រាយផ្សេងៗជាច្រើនបែបច្រើនយ៉ាងអំពីសំណាក់មហាជន ។ អ្នកខ្លះនិយាយថា មកពីលោកតូចចិត្តនឹងការបរាជ័យនៃរឿងរបស់លោកមួយឈ្មោះ " ផែដ្រឹ " ( Phèdre ) ទើបបានជាលោករ៉ាស៊ីនរត់ដូច្នេះ ។

ប៉ុន្តែការពិតវិញ លោករ៉ាស៊ីន មិនមែនតូចចិត្តក្នុងកិច្ចការនិពន្ធទាំងឡាយរបស់គាត់ឡើយ ។ ការបាត់ខ្លួននេះ បណ្ដាលមកពីលោករ៉ាស៊ីន នឹកឃើញទៅដល់សាស្ត្រាចារ្យទាំងឡាយ ដល់អ្នកស្រុក ពរ័-រ៉ូយ៉ាល់ទាំងមូល និងជាពិសេសគឺនឹកទៅដល់សាសនាហ្សង់សេនីស ។ លោកបោះបង់ការនិពន្ធក្នុងពេលនេះ ក៏ដើម្បីឱ្យអ្នកស្រុក ពរ័-រ៉ូយ៉ាល់ ទុកចិត្តមកលើរូបលោកតែប៉ុណ្ណោះ ។

ម្ដងនេះ លោករ៉ាស៊ីនបានតាំងចិត្តថា នឹងស្មោះត្រង់ជានិច្ចចំពោះលទ្ធិហ្សង់សេនីស ។ លុះមកដល់ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៦៩៩ លោករ៉ាស៊ីនក៏បានទទួលមរណភាពទៅ ។ មុនពេលនឹងស្លាប់ លោករ៉ាស៊ីនបានផ្ដែផ្ដាំថា : " នៅពេលខ្ញុំស្លាប់ទៅ សូមមេត្តាយកសពខ្ញុំទៅកប់នៅចុងជើងនៃសពរបស់លោកហាម៉ុង នៅឯពរ័-រ៉ូយ៉ាល់ " ។

លុះដល់មកឆ្នាំ ១៧១១ ពរ័-រ៉ូយ៉ាល់ បានត្រូវគេរុះរើចោល ។ ចំណែកឯអដ្ឋិធាតុរបស់លោក រ៉ាស៊ីន ក៏ត្រូវបានគេយកមកតម្កល់ជិតអដ្ឋិ

ធាតុរបស់លោកប៉ាស្កាល់ ( PASCAL ) នោះឯ " សាំង អេដែន ឌុយម៉ុង" វិញ ។

## វណ្ណកម្មរបស់លោករ៉ាស៊ីន

ស្នាដៃនិពន្ធរបស់លោក រ៉ាស៊ីន មិនសំបូរស្មើនឹងស្នាដៃរបស់លោក ពៀរ គរ័ណី ឬក៏លោកម៉ូលីយែរទេ ។ ស្នាដៃរឿងល្ខោនរបស់លោករ៉ាស៊ីន ភាគច្រើនសុទ្ធតែបានពិពណ៌នានូវតណ្ហាដ៏ពុះពោរ ហើយក៏គឺតណ្ហានេះឯង ហើយ ដែលជាកំលាំងដ៏ចង្រៃមួយ ដែលបំផ្លាញជនណាដែលឈ្លក់វង្វេងនឹងវា ។

វណ្ណកម្មរបស់លោក រ៉ាស៊ីន ចែកចេញជា ៥ ផ្នែកដូចតទៅ :

១~ **អត្ថបទនាដ្យោសោកនាដ្យ** :

- la Thébaïde ou les Frères ennemies
- Alexandre le Grand
- Andromaque ( tragédie, 1667 )
- Britannicus ( tragédie, 1669 )
- Bérénice ( tragédie, 1670 )
- Bajazet ( tragédie, 1672 )
- Mithridate ( tragédie, 1673 )

- Phèdre ( tragédie, 1677 )

## ២. ទារុណកថាបែបសាសនា :

- Esther ( tragédie en 3 actes en vers, avec choeurs, 1ère representation, 1689 )
- Athalie ( tragédie avec choeurs ( 1691 ) )

## ៣. ហាសកថា :

- les Plaideurs ( comédie en trois actes et en vers (1668 ) )

## ៤. អត្ថបទកំណាព្យ :

- la Nymphe de la Seine
- la Renommée aux muses
- Onze hymnes traduites du Bréviaire romain
- Quatre Cantiques spirituels

## ៥. អត្ថបទបកប្រែ :

- l' Odyssée
- Eschyle
- Sophocle
- Euripide
- la Poètique d'Aristote

- le Banguet de Platon

ក្រៅអំពីនេះ គេសង្កេតឃើញមានស្នាដៃផ្សេងៗដទៃទៀតជាច្រើន ដែលជាស្នាដៃសង្គ្រាមប៉ាក្កា ស្នាដៃប្រវត្តិសាស្ត្រ និង លិខិតផ្សេងៗផង ។

# ឧត្តមភាពអក្សរសិល្ប៍ និងគោលគំនិតសំខាន់ៗរបស់លោករ៉ាស៊ីន

រឿងសោកនាដកម្មរបស់លោក រ៉ាស៊ីន ទាំងអស់ ច្រើនតែមានសកម្មភាពយ៉ាងងាយបំផុត ចំណែកឯពាក្យពេចន៍វិញ ក៏ពីរោះចាប់ចិត្តរណ្ដំហើយងាយយល់ទៀតផង ។

ក្នុងការនិពន្ធ លោករ៉ាស៊ីន តែងគោរពឥតខ្ចោះនូវគោលការណ៍សមត្រៃ ។ ឧទាហរណ៍រឿង អង់ដ្រូម៉ាក ( Andromaque ) មានថេរៈវេលាត្រឹមតែ ២៤ ម៉ោង ទីកន្លែងតែមួយ ( ក្នុងវាំងស្ដេច ) សកម្មភាពរឿងវិលវង់ជុំវិញតែបញ្ហាមួយ ។

តាមការសង្កេត រឿងទាំងឡាយរបស់លោករ៉ាស៊ីន ច្រើនតែនិយាយពីរឿងស្នេហា ។ រីឯតួអង្គទៀតសោតក៏មានសភាពកាចយង់ឃ្នងគួរឱ្យភ័យខ្លាច រហូតដល់ធ្វើឱ្យអ្នកស្ដាប់អ្នកទស្សនា មានការអាណិតទៅដល់តួអង្គ ដែលទទួលរងគ្រោះដោយសារអំពើឃោរឃៅនោះទៀតផង ។ ឧទាហរណ៍ដូចជាក្នុងរឿង អង់ដ្រូម៉ាក គេឃើញតួភីរុស គំរាមកំហែងនាងអង់ដ្រូម៉ាក ដោយសំឡុតថា បើសិននាងមិនស្រលាញ់រូបគេទេ ខ្លួនគេនឹងសំលាប់ អាស្ទីយ៉ាណាស ជាកូនរបស់នាងចោល ។

# ប្រភពនៃរឿងសោកនាដកម្មរបស់លោករ៉ាស៊ីន

ប្រធានរឿងដែលលោក រ៉ាស៊ីន លើកយកមកដាក់នៅក្នុងស្នាដៃរបស់លោក គឺច្រើនតែដកស្រង់មកអំពីរឿងប្រវត្តិសាស្ត្ររ៉ូម៉ាំង និងក្នុងរឿងព្រេងនិទានក្រិក ដែលសុទ្ធសឹងជាស្នាដៃពិសេសរបស់អស់លោកអ្នកនិពន្ធ ល្បីៗនាជំនាន់ដើមដូចជាលោក ៖

- តាស៊ីត ប្រវត្តិវិទូ ជាតិឡាតាំង ( Tacité, v-55-v.420 )
- តាំង-គុស ប្រវត្តិវិទូជាតិឡាតាំង ( Quinte-Curce, Ier s. apr.J-C . ) អ្នកនិពន្ធ " ប្រវត្តិអាឡេចសង់ដ្រ៍ "
- សេណែក អ្នកនិពន្ធជាតិឡាតាំង ( Sénèque, v.39 apr. J-C )
- អូមែរ កវីនៃវីរកថាជនជាតិក្រិកបុរាណ ( Homère,IXe-VIIIe s.av.J-C. )
- វីរហ្ស៊ីល កវីជាតិឡាតាំង ( Virgile , v.70-v.19 av.J.C)

 ។ល។ និង ។ល។

លោក ហ្សង់ រ៉ាស៊ីន មានទេពកោសល្យល្អណាស់ក្នុងការយករឿងរបស់អ្នកនិពន្ធទាំងអស់នេះ មកច្នៃបញ្ចូលនូវតថនិយម ប្រាកដនិយម និងកែប្រែឱ្យទាន់សម័យផង ។

វត្ថុដ៏សំខាន់ដែលលោក រ៉ាស៊ីន ច្រើននិយមលើកយកមកចោទជាបញ្ហានោះ គឺសេចក្តីស្នេហា ។ ដោយសារសេចក្តីស្នេហាដែលលោករ៉ាស៊ីនលើកយកមកជាគោលសំខាន់នេះឯងហើយ ដែលនាំឱ្យអ្នកអាន អ្នកទស្សនា អាចជួបប្រទះនូវមនោសញ្ចេតនាផ្សេងៗ ដូចជា ការគិតតែប្រយោជន៍ផ្ទាល់ខ្លួន មហិច្ឆិតាដ៏ងងឹតងងល់... ។

លោករ៉ាស៊ីន តែងតែធ្វើវិភាគយ៉ាងល្អិតល្អន់ល្អណាស់ នូវទឹកចិត្តមនោសញ្ចេតនា និងលក្ខណៈចិត្តសាស្ត្រនៃតួអង្គនីមួយៗ ។ ស្នេហាមិនគ្រាន់តែជាគ្រឿងអលង្ការសំរាប់លំអសាច់រឿងដូចជាក្នុងស្នាដៃរបស់លោកគ័រណីទេ ហួសពីនេះ លោករ៉ាស៊ីនបានយកស្នេហាមកធ្វើជាគោលការណ៍សំខាន់សំរាប់សោកនាដកម្មរបស់ខ្លួនផង ។ សំរាប់លោករ៉ាស៊ីន សេចក្តីស្នេហាជាប្រភពធំនៃរឿងវិបត្តិភាគច្រើនរបស់មនុស្សជាតិ ។

" ស្នេហាជាប្រភពនៃតណ្ហា និងសេចក្តីលោភលន់របស់មនុស្ស ។ វាបានបង្កើតឱ្យមានការច្រណែនប្រច័ណ្ឌទាំងឡាយ ដែលអាចនឹងរុញច្រានមនុស្សទំលាក់ទៅក្នុងជម្រៅនៃសេចក្តីអស់សង្ឃឹម ព្រមទាំងអាចក្រឡៃមនុស្សឱ្យឆ្កួតវង្វេងទៀតផង " ។ ( L'amour est une source de toutes les passions humaines et il crée la jalousie qui peut pousser l'être humain au désespoir à la folie extrême . )

គឺដោយសារតែសេចក្ដីស្នេហានេះហើយដែលនាង អេមីញ៉ៀន នៅក្នុងរឿងអង់ដ្រូម៉ាក បានធ្លាក់ទៅក្នុង " នរកនៃតណ្ហា " និងក្នុងសេចក្ដីប្រច័ណ្ឌដ៏លិចលង់បំផុត ។

ស្នេហាដែលលោក រ៉ាស៊ីន បានលើកយកមកបង្ហាញនៅក្នុងស្នាដៃរបស់លោក ច្រើនតែស្របទៅនឹងគំនិតរបស់លោក ឡាប្រុយយែ ( Jean de LA BRUYÈRE ) ។ ឧទាហរណ៍ដូចជារឿង អង់ដ្រូម៉ាក នាងអេមីញ៉ៀនមានសេចក្ដីស្នេហាចំពោះភីរុសយ៉ាងខ្លាំងក្លាបំផុត ។ តែក្រោយមកស្នេហាដ៏ធំធេងនេះ អាចក្លាយទៅជា " មហាកំហឹង " មួយដែលគ្មានអ្វីទប់បាន ។ បានសេចក្ដីថា មុនដំបូងស្នេហាមានសភាពជាការប្រច័ណ្ឌសិន តែបើការប្រច័ណ្ឌនេះរីកទំហំកាន់តែធំឡើង ហើយបើមានលាយទៅដោយការអស់សង្ឃឹមខ្លះផង ស្នេហានោះប្រាកដជាក្លាយទៅជាព្យុះសង្ឃរា ដែលបោកបក់យ៉ាងសាហាវ បណ្ដាលឱ្យអ្វី១ជួបនឹងគ្រោះអាសន្នទាំងអស់ ។

ឧទាហរណ៍ ផែដ្រ៍ នៅក្នុងរឿងផែដ្រ៍ ( Phèdre ) ដែលស្រលាញ់បួនថ្លៃឯងឈ្មោះអ៊ីប៉ូលីត ខ្លាំងពេកទៅ លុះក្រោយមក ដោយដឹងថាអ៊ីប៉ូលីត ប្រែរជាទៅស្រលាញ់មនុស្សម្នាក់ផ្សេងទៀត ក៏កើតចិត្តច្រណែនរហូតដល់ដុះគំនិតសងសឹកយកស្លាប់រស់... ។

ជាសេចក្ដីសន្និដ្ឋាន " ស្នេហាតណ្ហា " គឺជា " កំលាំងនាដកម្ម " ដែលមានទម្ងន់ដ៏អស្ចារ្យនៅក្នុងរឿង សោកនាដកម្ម របស់លោករ៉ាស៊ីន ។ នេះបានសេចក្ដីថា " កាលណាគេស្រឡាញ់ គេត្រូវតែឈឺចាប់ ហើយនៅក្នុងការឈឺចាប់នោះ វាមានទាំងសេចក្ដីសង្ឃឹមផង និងមានទាំងការតានតឹងចិត្តផង " ។

## វីរជនរបស់លោករ៉ាស៊ីន

ផ្ទុយពីវីរជនរបស់លោក គរ៉ណី ដែលសុទ្ធតែជាចៅហ្វាយនៃសេចក្ដីស្នេហានោះ វីរជនរបស់លោក ហ្សង់ រ៉ាស៊ីន បានបង្ហាញឱ្យឃើញនូវទឹកចិត្តចុះញ៉មចំពោះសេចក្ដីស្នេហា ។

តួអង្គទាំងឡាយនៅក្នុងរឿងរបស់លោក រ៉ាស៊ីន សុទ្ធតែជាវីរជនដែលត្រូវតណ្ហាដឹកនាំ ។ លោករ៉ាស៊ីនគ្មានត្រូវការអប់រំមនុស្សឱ្យមានថាមពលខ្លាំងក្លាខាងផ្លូវចិត្តឡើយ ប៉ុន្តែលោករ៉ាស៊ីនបែរជាបង្ហាញនូវភាពទន់ខ្សោយរបស់មនុស្សជាតិទៅវិញ ។ វីរជនរបស់លោករ៉ាស៊ីន សុទ្ធសឹងជាទុទិដ្ឋិនិយមបុគ្គល ដែលមិនព្រមតស៊ូដើម្បីផ្ចាញ់នូវវាសនាអាក្រក់របស់ខ្លួនទេ តែបែរជាសុខចិត្តបណ្ដោយអាត្មាទៅតាមយថាកម្មទៅវិញ ។ មិនតែ

ប៉ុណ្ណោះ លោកវ៉ាស៊ីន បានអប់រំតួអង្គរបស់ខ្លួនឱ្យចេះអត់ធ្មត់ អត់ធន់នឹងសម្ពាធអាក្រក់គ្រប់យ៉ាង ដូចជាការឈឺចាប់ ឬ អយុត្តិធម៌ជាដើម ។

អេមីញ៉ែន និង អូរេស សុទ្ធតែជាកញ្ចះដាច់ថ្លៃនៃតណ្ហា ។ គេរស់ដើម្បីតែស្នេហា ហើយគេស្លាប់ទៅវិញដ៏ដើម្បីសេចក្តីស្នេហាដែរ ។ អូរេសដែលក្លាយជាមនុស្សក្បត់ ជាឧក្រិដ្ឋជនក៏ព្រោះតែស្នេហា និង តណ្ហាដែរ ។

ណេរុង និង ណារស៊ីស ដែលមានអាកប្បកិរិយា សាហាវយង់ឃ្នងក៏ ព្រោះតែតណ្ហា ។

អាគ្រីពីន ដែលជាមនុស្សលោភលន់ ប្រាថ្នាធំ និងគិតតែប្រយោជន៍ផ្ទាល់ខ្លួនពេកទៅ ទីបំផុតក៏ហ៊ានប្រព្រឹត្តនូវឧក្រិដ្ឋកម្មមួយដ៏គួរឱ្យខ្លាច ។

ផែដ្រឺ នារីអភ័ព្វស្នេហ៍ បានប្រព្រឹត្តអំពើដ៏សាហាវរហូតដល់ទីបំផុតយកសេចក្តីស្លាប់ជាតុលាការសំរាប់កាត់ទោសឱ្យខ្លួនឯង ។

ទោះជាវីរជនរបស់លោក វ៉ាស៊ីន មានលក្ខណៈពុំល្អក៏ដោយ ក៏វាជាតំណាងនូវជីវភាពមួយភាគធំរបស់មនុស្សលោកដែរ ។ ក្នុងឆាកជីវិតរបស់ខ្លួន មនុស្សតែងចៀសវាងពុំរួចទេនូវរឿងរ៉ាវទាំងអស់នេះ ។ រឿងស្នេហារឿងតណ្ហា សេចក្តីឈឺចាប់ ការបង្ហូរទឹកភ្នែក និងអកុសលកម្មផ្សេងៗ សុទ្ធតែជារឿងរបស់មនុស្ស ។

ដូច្នេះលោករ៉ាស៊ីន គឺជាបុគ្គលប្រាកដនិយមមួយរូប ដែលយកតែវិបត្តិ និង ចំរៀងទឹកភ្នែករបស់មិត្តមនុស្សជាតិ មកច្រៀងរៀបរាប់ត្អូញត្អែរប្រាប់អ្នកអាន អ្នកទស្សនារបស់លោក ។

# អង់គ្លេស ស.វ ទី ១៨

( RESTORATION AND EIGHTEENTH-CENTURY ENGLAND )

- វីលៀម វីឈើរលេយ៍ ( William Wycherley )
- វីលៀម កុងគ្រេវ ( William Congreve )
- អូលីវើរ ហ្គូលដ៍ស្មីត ( Oliver Goldsmith )
- ជ្យន ហ្គេយ ( John Gay )
- រីឆាដ សេរីដាន់ ( Richard Sheridan )



## វីល្លៀម វីឈើរលេយ៍

William Wycherley

( Clive 1640 - Londres 1715 )

អ្នកនិពន្ធអង់គ្លេស ។

ជាអ្នកនិពន្ធរឿងល្ខោននាដកម្ម ដៀវលត្ថុះ ( យកគំនិតមកពីលោក ម៉ូលីយែរ ) រឿងរបស់គាត់មានដូចជា :

- la Provinciale
- l' Homme sans détours



## វីលៀម កុងគ្រេវ

William Congreve
( Bardsey, près de Leeds,1670-
Londres 1729 )

អ្នកនិពន្ធអង់គ្លេស ។

ជាអ្នកនិពន្ធវិនាដកម្មវីរជន និង ជាអ្នកនិពន្ធរឿងល្ខោនហាសនាដកម្ម ដូចជា : Ainsi va le monde ដែលប្រឆាំងតបនឹងភាពតឹងរ៉ឹងនៃពួកពូរីតាំង ( puritain –សមាជិកគណៈមួយនៃសាសនាគ្រិស្ត ដែលកាន់តាមគម្ពីរយ៉ាងតឹងរ៉ឹង ) ។



## អូលីវើរ ហ្គូលដ៍ស្មីត

Oliver Goldsmith
( Pallasmore, Irland 1728-Londres 1774 )

អ្នកនិពន្ធអង់គ្លេស ។

ជាអ្នកនិពន្ធរឿងប្រលោមលោកដូចជា :

- le Vicaire de Wakefield ( 1766 )

ជាអ្នកនិពន្ធកំណាព្យមនោសញ្ចេតនា ដូចជា :

- le Village abondonné

ហើយនិងជាអ្នកនិពន្ធរឿងល្ខោនដូចជារឿង :

- Elle s' abaisse pour triompher… ។



**ជ្យន ហ្គេយ**

John Gay
( Barnstaphe 1685 - Londres 1732 )

អ្នកនិពន្ធអង់គ្លេស ។

ជាអ្នកនិពន្ធ : l' Opéra du gueux ( 1728 )… ។



## រីឆាដ សេរ៉ីដាន់

Richard Sheridan ( R.Brinsley )
( Dublin 1751 - Londres 1816 )

អ្នកនិពន្ធរឿងល្ខោននាដកម្ម និង ជាអ្នកនយោបាយអង់គ្លេស ។ ជាអ្នកនិពន្ធរឿងល្ខោន ហាសនាដកម្ម ដូចជា :

- les Rivaux
- l' École de la médisane

រីឆាដ សេរ៉ីដាន់ បានបោះបង់អក្សរសាស្ត្រ ដើម្បីចូលរួមប្រលូកក្នុងឆាកនយោបាយ ហើយបានឡើងកាន់មុខតំណែងមួយ នៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រីអស់រយៈពេលជាយូរឆ្នាំ ។

# អាល្លឺម៉ង់ ស.វ ទី ១៨

( EIGHTEENTH-CENTURY GERMANY )

- ហ្សូហាន ហ្គេតេ ( Johann Goethe )
- ហ្វ្រីអ៊ីដ្រិច ស៊្សីល័ែរ ( Friedrich Shiller )
- ហេនរិច វ៉ុន ក្លេអ៊ីស្ត ( Heinrich von Kleist )



## ហ្សូហាន ហ្គេតេ

Johann Goethe ( Johann Wolfgang von )
( Francfort –sur-le-Main 1749-Weimar 1832 )

អ្នកនិពន្ធអាល្លឺម៉ង់ ។

ជាប្រមុខម្នាក់នៃ " Sturm und Drang " ជាមួយនិងប្រលោមលោករបស់គាត់ឈ្មោះ les Suffrances du jeune Werther ហើយនិង រឿងល្ខោននាដកម្មរបស់គាត់ គឺរឿង Götz von Berlichingen ( 1774 ) ។ គាត់បានធ្វើការវិវត្តន៍ ដោយឆ្លងកាត់តាមរយៈបទពិសោធន៍របស់ខ្លួនមកពីប្រទេសអ៊ីតាលី ( Torquato Tasso, 1789 ) ពីបដិវត្តបារាំង និងពីនយោបាយ ( គាត់បានធ្វើជារដ្ឋមន្ត្រីនៃហ្គ្រង់-ឌុច ( Grand-duc នៃរដ្ឋ វ៉េយម៉ា ពីមិត្តភាពរបស់គាត់ជាមួយនឹងលោក Shiller ( Xénis, 1796 ) ហើយនិងពីការស្រាវជ្រាវវិទ្យាសាស្ត្រទាំងឡាយរបស់គាត់ ( la Métamorphose des plantes, (1790 ), la Théorie des Couleurs, 1810 ) តាមរយៈសិល្បៈមួយដែលមានលក្ខណៈបុរមបុរាណមានជាអាទិ៍ : Wilhelm Meister; Hermann et Dorothée; les

Affinités électives; 1809 ដែលទទួលយកនូវទម្រង់បែបស្វ័យជីវប្រវត្តិមួយ : Poésie et vérité, 1811-1833 ហើយនិងបែបនិមិត្តរូប : Divan occidental et Oriental, 1819; Faust ។



## ហ្វ្រីអ៊ីដ្រិច ស៊ីល្លែរ

Friedrich Shiller ( Friedrich von )
( Marbach 1759 - Weimar 1805 )

អ្នកនិពន្ធអាល្លឺម៉ង់ ។

ជាអ្នកនិពន្ធរឿងល្ខោននាដកម្មប្រវត្តិសាស្ត្រ ដូចជា :

- les Brigands ( 1782 )
- la Conjuration de Fiesque ( 1783 )
- Don Carlos ( 1787 )
- Wallenstein ( 1798-99 )
- Marie Stuart ( 1800 )
- la Pucelle d' Orléans ( 1801 )
- la Financée de Messine ( 1803 )
- Guillaume Tell ( 1804 )
- d' une Histoire de la guerre de trente Ans ( 1791-1793) ហើយនិងកំណាព្យអំណែតអណ្តូងដូចជា : l' Hymme á la joie ( 1785 ); Ballades ( 1798 ) ។

រឿងល្ខោននាដកម្មទាំងឡាយរបស់លោកស៊ីរ៉ែរ ស្តែងចេញឡើងដូចជាការសម្រុះសម្រួលមួយរវាងសោកនាដកម្មបុរាណ ហើយនិងវិនាដកម្មរបស់លោក សេ្សកស្ពៀរ ។ ពួកអ្នកនិពន្ធរឿងប្រលោមលោកជនជាតិបារាំងទាំងឡាយ បានទទួលយកឥទ្ធិពល នៃទ្រឹស្តីល្ខោននាដកម្មរបស់គាត់នេះ ។



## ហេនរិច ហ្វ៊ុន ក្លេអ៊ីស្ត៍

Heinrich von Kleist
( Francfort -sur- l'Oder 1777- Wannsee 1811 )

អ្នកនិពន្ធអាល្លឺម៉ង់ ។

ជាអ្នកនិពន្ធរឿងល្ខោនបាសនាដកម្ម ដូចជា :

- la Cruche cassée ( 1808 ) ហើយនិងរឿងល្ខោននាដកម្មប្រវត្តិសាស្ត្រ ដូចជា :

- le Prince de Hombourg ( 1810 ) ។

ក្លេអ៊ីស្ត៍ បានធ្វើអត្តឃាត ជាមួយនឹងមិត្តស្រីរបស់គាត់ឈ្មោះ Henriette Vogel ( តែគេមិនបានយល់ពីមូលហេតុនៃអត្តឃាតកម្មនេះផងទេ ) ។

# បារាំង ស.វ ទី ១៩

( NINETEENTH-CENTURY FRANCE )

- អឺហ្សែន ឡាប៊ីច ( Eugène Labiche )
- វិចទ័រ យូហ្គោ ( Victor Hugo )
- អាល់ហ្វ្រេដ ដឺ មូសេ ( Alfred de Musset )



**អឺហ្សែន ឡាប៊ីច**

Eugène Labiche

( Paris 1815 -id. 1888 )

អ្នកនិពន្ធល្ខោននាដកម្មបារាំង ។

ជាអ្នកនិពន្ធរឿងល្ខោនហាសនាដកម្មអាចារៈ និង ចំរៀងសប្បាយ ( ជំនាន់ដើម ) ហាសនាដកម្មដែលមានកូដោបាយ និង ការភាន់ច្រឡំ ( comédies de moeurs et de vaudevilles ) ដូចជា :

- Un chapeau de paille d' Italie ( 1851 )
- le Voyage de M. Perrichon ( 1860 )
- le Cagnotte ( 1864 )



**វិចទ័រ យូហ្គោ**

Victor Hugo

( Besançon 1802 -Paris 1885 )

អ្នកនិពន្ធបារាំង ។

យូហ្គោ ជាកូនប្រុសរបស់លោកឧត្តមសេនីយម្នាក់ នៃអធិរាជាណាចក្រ ។ មុនដំបូងគាត់គឺជាកវីក្លាស៊ិកម្នាក់ ហើយនិងជាអ្នករាជាធិបតេយ្យនិយម ( Odes, 1822 ) ។ ក៏ប៉ុន្តែតាមរយៈសៀវភៅដែលបោះពុម្ពផ្សាយនូវអារម្ភកថា Cromwelle ( 1827 ) ហើយនិង Orientales ( 1829 ) និងបន្ទាប់មកគឺការសំដែង ( រឿងល្ខោន ) ឈ្មោះ Hernani ( 1830 ) បានធ្វើឱ្យរូបគាត់ក្លាយទៅជាការចាប់ភពដ៏ប្រសើរបំផុត នៃរ៉ូម៉ង់ទិស្ម ( Romantisme -ចលនាអក្សរសាស្ត្រសិល្បៈនៅចុងស.វទី ១៨ និង ទី ១៩ ) ក្នុងស្នាដៃជាកវីនិពន្ធគឺមាន :

- les Feuilles d'automne ( 1831 )
- les Chants du crépuscule ( 1835 )
- les Voix intérieures ( 1837 )
- les Rayons et les Ombres ( 1840 )

ក្នុងល្ខោនមានដូចជា :

- Marion de Lorme ( 1831 )
- Le roi s'amuse ( 1832 )
- Marie Tudor ( 1833 )
- Ruy Blas ( 1838 )

ហើយនិងតាមរយៈស្នាដៃប្រលោមលោកប្រវត្តិសាស្ត្ររបស់គាត់ដូចជា :

- Notre-Dame de Paris ( 1831 ) – ក្នុងពេលដែលគាត់បានធ្វើវិវត្តតាមរយៈគំនិតសេរីនិយម និងសក្ការៈណាប៉ូលេអុង ។ បន្ទាប់ពីបរាជ័យនៃ Burgraves ( 1843 ) និងមរណភាពរបស់កូនស្រីគាត់ឈ្មោះ Léopoldine កន្លងមក យូហ្គោបានជាប់ចិត្តនឹងរឿងនយោបាយ ( គាត់គឺជាពែរ ( Pair-សមាជិកសភាល័រ Chambre des lords នៅប្រទេសអង់គ្លេស) នៃប្រទេសបារាំងក្នុងឆ្នាំ ១៨៤៥ ជាតំណាងរាស្ត្រក្នុងឆ្នាំ ១៨៤៨។ នៅក្រោយពេលរដ្ឋប្រហារថ្ងៃទី ២ ធ្នូ ឆ្នាំ ១៨៥១ យូហ្គោ បាននិរទេសទៅ Jersey បន្ទាប់មកទៅ Guernesey ។ គឺនៅពេលនោះឯងហើយដែលយូហ្គោបានផ្តល់នូវកំណាព្យដៀលត្មះទាំងឡាយ មានដូចជា Châtiments ( 1853 ) កម្រងអត្ថបទអណ្តែតអណ្តូងដូចជា Contemplations

( 1856 ) វីរកថានៃ la Légende des siècles ( 1859-1883 ) ព្រមទាំងប្រលោមលោកដូចជា :

- les Misérables ( 1862 )
- les Travailleurs de la mer ( 1866 )
- L' homme qui rit ( 1869 )

យូហ្គោបានវិលត្រឡប់មកប្រទេសបារាំងវិញ នៅក្នុងឆ្នាំ ១៨៧០។ ក្នុងនាមជាជនប៉ារទីសង់ ( partisan ) ដែលមានផ្នត់គំនិតសាធារណរដ្ឋនិយម យូហ្គោ គឺជាតួអង្គម្នាក់ប្រកបដោយកិត្តិយស និង ជាផ្លូវការ ហើយនៅពេលដែលគាត់ស្លាប់ទៅ អដ្ឋិធាតុរបស់គាត់ត្រូវបានគេផ្ទេរយកទៅបញ្ចុះនៅឯ Panthéon ។



## អាល់ហ្វ្រេដ ដឺ មូសេ

Alfred de Musset

( Paris 1810 -id. 1857 )

អ្នកនិពន្ធបារាំង ។

មូសេ បានធ្វើឱ្យគេទទួលស្គាល់រូបគាត់តាមរយៈនៃការបង្ហាញនៅក្នុងមណ្ឌល ណូឌីយេរ នូវស្នាដៃរឿងប្រឌិតទាំងឡាយរបស់គាត់គឺ Contes d' Espagne et d' Italie ( 1830 ) ។ ស្នាដៃនិពន្ធល្បងដ៏អភ័ព្វទាំងឡាយរបស់គាត់នៅក្នុងល្ខោន រួចហើយនិងសម្ព័ន្ធការដ៏រំជើបរំជួលមួយជាមួយនឹងលោក George Sand បានធ្វើឱ្យជីវិតរបស់គាត់ជ្រួលច្របល់ ខ្វល់ខ្វាក់ និង រាយពពាយ ។ មូសេ បានបោះពុម្ពផ្សាយនូវរឿងល្ខោនទុកសំរាប់ការអាន ដែលក្នុងនេះមាន :

- les Caprices de Marianne ( 1833 )
- Fantasio, On ne badine pas avec l'amour, Lorenzaccio ( 1834 )
- le Chandelier ( 1835 )
- Il ne faut jurer de rien ( 1836 )

ស្នាដៃកំណាព្យ មានដូចជា : les Nuits ( 1835-1837 )

រឿងប្រលោមលោកស្វ័យជីវប្រវត្តិមួយ : la Confession d'un enfant du siècle ( 1836 ) ។ ចាប់តាំងពីឆ្នាំ ១៨៣៨ ឡើងទៅ មូសេមានជំងឺ និងទន់ខ្សោយដោយសារអតិរេកភាព ។ គាត់បានផ្តល់ជាថ្មីម្តងទៀតនូវរឿងប្រឌិតទាំងឡាយដូចជា : Mini Pinson ភាសិតផ្សេងៗដូចជា : Il faut qu' une porte soit ouverte ou fermée ( 1845 ) ។

មនោវិគតិតាមបែបកំណាព្យ បញ្ជាក់បង្ហាញពីបដិវាទកម្មទាំងឡាយនៃបុគ្គលិកលក្ខណៈរបស់គាត់ : កវីនិពន្ធនៃការឈឺចាប់ និងនៃមនោសញ្ចេតនាដ៏ខ្លាំងក្លា ហើយគាត់ក៏ជាជនមនោវិគតិពាយងាយផងដែរ ។ ប្អូនប្រុសរបស់មូសេឈ្មោះប៉ូល Paul ( 1804-1880 ) គឺជាអ្នកនិពន្ធរឿងប្រលោមលោក និង ជាអ្នកនិពន្ធល្បង ( essayiste ) ។

# ស្កង់ឌីណាវីយ៉ា ស.វ ទី ១៩

( SCANDINAVIA NINETEENTH-CENTURY )

- ហេនរិក អ៊ិបស៊ីន ( Henrik Ibsen )
- អូហ្គើស្ត៍ ស្ត្រីនដ៍ប៊ើរហ្គ ( August Strindburg )



## ហេនរិក អ៊ីបសឹន

Henrik Ibsen

( Skien 1828- Christiania 1906 )

អ្នកនិពន្ធ ន័រវែស ។

ជាអ្នកនិពន្ធរឿងល្ខោនរឿងល្ខោននាដកម្ម ដកស្រង់គំនិតមកពីទស្សនវិជ្ជា និងសង្គម ។

ស្នាដៃរបស់ លោក អ៊ីបសឹន មានដូចជា :

- Brand ( 1866 )
- Peer Gynt (1867 )
- Maison de poupée ( 1879 )
- les Revenants ( 1881 )
- le Canard sauvage ( 1884 )
- Hedda Gabler ( 1890 )



# អូហ្គើស្ដ ស្ដ្រីនដ៍ប៊ើរហ្គ
August Strindburg

( Stockholm 1849 -id.1912 )
អ្នកនិពន្ធ ស៊ុយអែដ ។

បន្ទាប់ពីកុមារភាពមួយដ៏សែនលំបាក ដូចដែលរូបគាត់បានពណ៌នានៅក្នុងរឿង " កូនប្រុសរបស់ទាសី " ( le Fils de la servante ) គាត់ក៏បានបោះពុម្ពផ្សាយនូវរឿងប្រលោមលោក បែបធម្មជាតិនិយមស៊ុយអែដជាលើកទីមួយ គឺរឿង la Chambre rouge ក្នុងឆ្នាំ ១៨៧៩ ។

ជីវិតមួយដែលពោរពេញទៅដោយសេចក្ដីស្នេហា ហើយនិងចលនាអ៊ូអរប្រកបដោយចលនាខ្វល់ខ្វាក់ បានបង្កើននូវវិសមតារបស់គាត់ឱ្យធ្លាក់ទៅក្នុងភាពឆេវឆាវ និង បានបណ្ដុះនូវស្នាដៃនវកថារបស់គាត់ដូចជារឿង Mariés -រឿងនិទានស្វ័យជីវប្រវត្តិទាំងឡាយដូចជា :

- Plaidoyer d' un fou
- Inferno

រឿងល្ខោនរបស់គាត់មាន :

- Père ( 1887 )

- Mademoiselle Julie ( 1888 )

លោក ស្ទ្រីងដ៏បើរហ្គ ក៏ជាអ្នកនិពន្ធរឿងល្ខោនប្រវត្តិសាស្ត្រផងដែរ ដូចជា :

- Eric XIV
- Christine

ហើយនិងធម្មជាតិនិយមដូចជា :

- la Danse de mo:t ( 1901 )

ក្នុងនាមជាអ្នកនាំចូលរបស់ថ្មីនៃ និមិត្តរូបនិយម នៅក្នុងប្រទេសអ៊ុយអែដ ដូចជារឿង " សុបិននិមិត្ត " ( le Songe ) ។ អ-ស្ទ្រីងដ៏បើរហ្គ បានធ្វើការវិវត្តន៍តាមរយៈនៃការនិយមកាន់សាសនាតឹង (le mysticisme) ហើយនិងបានបង្កើតនូវ " ល្ខោនអាំងទីម " ( le Théâtre-Intime ) ដែលជាកន្លែងសំរាប់សំដែង " កាំមើរស្ព៊ីល " Kammerspiel ( mot all, théâtre de chambre ) ដូចជារឿង : la Sonate des spectres និងរឿង le Pélican ជាដើម ។

ស្នាដៃរបស់លោក អ.ស្ទ្រីងដ៏បើរហ្គ មានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើល្ខោនសម័យទំនើប មានជាអាទិ៍ដូចជា " សំដែងនិយមអាល្លឺម៉ង់ " ជាដើម ( expressionnisme allemand ) ។

# រុស្ស៊ី ស.វ ទី ១៩

( RUSSIA NINETEENTH-CENTURY )

- ហ្គូហ្គល់ ( Nikolai Gogol )
- អ៊ីវ៉ាន់ តួរហ្គេណេស ( Ivan Tourgueniev )
- ឆេកូស ( Anton Tchekhov )
- ហ្គរគី ( Maxim Gorki )



**ហ្គូហ្គល់ នីកូឡៃ វ៉ាស៊ីលីអេវិច**

NIKOLAI GOGOL ( NIKOLAÏ VASSILIEVITCH )

( Sorotchintsy 1809 -Moscou 1852 )

អ្នកនិពន្ធរុស្ស៊ី ។

ជាអ្នកនិពន្ធរឿងល្ខោន ដូចជារឿង le Revizor និងនវកថាទាំងឡាយដូចជា Tarass Boulba ។ ហ្គូហ្គល់ គឺជាអ្នកបង្កើតប្រលោមលោកទំនើបរុស្ស៊ី មានដូចជារឿង les Âmes morts ។



## អ៊ីវ៉ាន់ តួរហ្គេណេស

Tourgueniev
( Ivan Sergueïevitch )
( Orel 1818 -Bougival 1883 )

អ្នកនិពន្ធរុស្ស៊ី ។

ជាអ្នកនិពន្ធប្រលោមលោក និង នវកថា មានដូចជា :

- Recits d' un chasseur ( 1852 )
- Pères et fils ( 1862 )
- les Eaux printanières ( 1872 )

និងរឿងល្ខោនមានដូចជា :

- Un mois à la campagne ( 1879 )

អ៊ីវ៉ាន់ តួរហ្គេណេស គឺជាអ្នកនិពន្ធរុស្ស៊ីដ៏មានឥទ្ធិពលបំផុត តាមរយៈគោលគំនិតនៃបស្ចិមប្រទេស ។



**អង់តូន ប៉ាវឡូវិច ឆេកូស**

TCHEKHOV ( Anton Pavlovitch )

( Taganrog 1860 -Badenweiler, Allemagne,1904 )

អ្នកនិពន្ធរុស្ស៊ីដ៏ល្បាញល្បីនៃ " សេចក្ដីស្នេហាដ៏ផ្អែមល្ហែមរបស់ទីក្រុងមូស្គូ និងរបស់ទ្វីបអឺរ៉ុប " ។

មុនដំបូងលោក ឆេកូស គឺជាអ្នកនិពន្ធរឿងប្រឌិត និងនវកថា តែក្រោយមកលោកក៏បានងាកទៅរកល្ខោន ហើយក្លាយទៅជាអ្នកនិពន្ធរឿងល្ខោនមួយរូប ដែលមានឈ្មោះបោះសំលេង នៅក្នុងពិភពអ្នកនិពន្ធរឿងល្ខោនប្រចាំសតវត្ស ទី ១៩ ។

## ជីវប្រវត្តិសង្ខេប :

លោក ឆេកូស គឺជាកូនប្រុសរបស់អ្នកងារ (ដែលរួចពីបំណុល ) កូនប្រុសរបស់អ្នកលក់គ្រឿងទេស ដែលធ្លាក់ខ្លួនក្រតោកយ៉ាកម្នាក់ ។ លោក ឆេកូស បានចំរើនវ័យធំធាត់នៅតាហ្គង់រ៉ុក ( Taganrog ) ក្នុងទុគ្គតភាពរកបានប្រាក់បន្តិចបន្តួច ដោយសារតែការបង្រៀនឡើងវិញ នូវបម្រាប់

( répétitions données ) ដល់កូនប្រុសទាំងឡាយរបស់ពួកអ្នកមុខអ្នកការនៅក្នុងសម័យនោះ ។

នៅក្នុងឆ្នាំ ១៨៧៩ នៅពេលអាយុបាន ១៩ ឆ្នាំ លោកឆេកូស បានទៅជួបគ្រួសាររបស់លោក ដែលកំពុងរស់នៅដោយភាពក្រីក្រតោកយ៉ាកនៅឯទីក្រុងម៉ូស្គូ ហើយដែលនៅទីនោះ លោកក៏បានផុសគំនិតសរសេរកូនរឿងប្រឌិតជាភាគខ្លីៗផ្ញើទៅឱ្យកាសែតកំប្លែងស្ទូត " ឡា ស៊ីហ្គាល់ ( la Cigale ) ដែលគេបានផ្តល់ឱ្យលោកនូវប្រាក់ rouble ខ្លះៗ ។

កម្រងអត្ថបទទីមួយរបស់លោក ឆេកូស មានឈ្មោះថា " les Contes de Melpomène " ប្រាកដឡើងនៅក្នុងឆ្នាំ ១៨៨៤ ។ បន្ទាប់មកកម្រងអត្ថបទទីពីរឈ្មោះ " Récits barrioles" សរសេរឡើងនៅក្នុងឆ្នាំ ១៨៨៦ ។ កិច្ចការទាំងនេះ បាននាំមកនូវការងាយស្រួលដល់រូបលោកគួរឱ្យមោទនៈ ( ទោះបីជាតិចតួចស្តួចស្តើងក៏ពិតមែន ) ក៏ប៉ុន្តែនៅពេលនោះ លោកឆេកូស បានបូជានូវកំលាំងចិត្តកាយទាំងប៉ុន្មានរបស់លោកដើម្បីវិជ្ជាជីវៈពេទ្យ ដែលលោកបានធ្វើការសិក្សាចាប់តាំងពី ឆ្នាំ ១៨៧៩ មក ។ ជាមួយគ្នានេះផងដែរ ពាក្យសរសើរទាំងឡាយរបស់លោក ហ្គ្រីហ្គោរ៉ូវិច ( D.V. Grigorovitch ) ក៏បានមកពញ្ញាក់រូបលោក និង ធ្វើ

ឱ្យរូបលោកមានចិត្តអង់អាចក្លាហានក្នុងការហក់ចូលទៅក្នុងមាគ៌ានៃអក្សរសិល្ប៍ថែមទៀត ។

ក្រោយមកនៅឆ្នាំ ១៨៨៧ លោក ឆេកូស ក៏បានសរសេររឿងល្ខោនមួយឈ្មោះ អ៊ីវ៉ាណុស ( Ivanov ) ហើយនិងនវកថាមួយ ( une nouvelle ) នៅឆ្នាំ ១៨៨៨ ឈ្មោះ ឡាស្តេព ( la Steppe ) រឿងទាំងពីរនេះបានធ្វើឱ្យសាធារណជនទទួលស្គាល់រូបលោក និងផ្ដល់មកឱ្យរូបលោកនូវកិត្តិយស និងកិត្តិនាមដ៏ធំធេង ៖ គេបានរកឃើញជាស្រេចនូវការខកចិត្តហើយនិងការអត់ធ្មត់នៅចំពោះមុខភាពសាមញ្ញនៃជីវិត ក៏ប៉ុន្តែបានបំភ្លឺដោយរសផ្អែមល្ហែមនៃធម្មជាតិ ហើយនិងភាពដែលធ្វើឱ្យរំភើបនៃស្ត្រីដែលសេចក្ដីស្នេហា បានអនុញ្ញាតឱ្យសព្វសត្វនិករទាំងឡាយប្រាកដមានឡើង ។ ម្យ៉ាងទៀត លោកឆេកូស មនោសញ្ចេតនាទាំងឡាយ ហាក់ដូចជាបានជួយឧបត្ថម្ភគាំពាររូបលោក ៖ ជាមនុស្សដែលមានចិត្តល្អ ហើយសប្បុរសទូលាយ លក្ខណៈនេះបានបង្ហាញឱ្យឃើញតាមការនិយាយស្ដីពីសំណាក់មិត្តភក្តិរបស់លោក ពីការព្រងើយកន្តើយ ហើយនិងពីការធុញទ្រាន់ ។ នេះប្រហែលជាធ្វើឱ្យគេកត់សំគាល់តាមរយៈនិមិត្តហេតុនៃរោគរបេង ដែលមិនបានធ្វើឱ្យរូបលោកមានពេលឈប់សំរាកតាំងពី ឆ្នាំ ១៨៨៩ ទៅ ។ ប៉ុន្តែនៅក្នុងឆ្នាំនោះ លោកឆេកូស បានផ្ដើមធ្វើដំណើរដែលធ្វើឱ្យ

ហត់នឿយយ៉ាងខ្លាំងមួយទៅកាន់ សាខាលីន ( Sakhaline ) ដើម្បីសិក្សាអំពីលក្ខខ័ណ្ឌទាំងឡាយនៃការកាន់កាប់គុកទោសឧក្រិដ្ឋ ដែលការណ៍នេះបានធ្វើឱ្យរូបលោកផុសគំនិតបង្កើតបាននូវរឿងមួយ ឈ្មោះ " កោះសាខាលីន " ( l' Île de Sakhaline ) សរសេរឡើងនៅក្នុងឆ្នាំ ១៨៩៣-៩៤។ ហើយលើសពីនេះទៀត កង្វល់ដែលនាំឱ្យរូបលោកមានការហត់នឿយខ្លាំងផងដែរនោះ គឺនៅក្នុងពេលដែលមានកើតជំងឺរាតត្បាតនៃអាសន្នរោគ ហើយនិងទុរ្ភិក្សនៅឆ្នាំ ១៨៩២ ក្នុងការចូលរួមយ៉ាងសកម្មក្នុងការជួយសង្គ្រោះខាងផ្នែកសុខាភិបាល ។

## ជីវិតស្នេហា ក្រោយការបរាជ័យ

ក្រោយពីបានធ្វើដំណើរទៅក្នុងប្រទេសអូទ្រីស អ៊ីតាលី និង បារាំងរួចមក លោកឆេកូស បានទៅនៅក្នុងផ្ទះតូចដែលជាកម្មសិទ្ធិផ្ទាល់របស់លោកនៅម៉ីលី ខូវ៉ូ ជិត ទីក្រុងមូស្គូ ( Melikhovo, près de Moscou ) ក្នុងរយៈពេលនេះ លោកបានសរសេរនវនិយាយល្បីៗបីបួន ដែលសុទ្ធសឹងតែជានវកថាដ៏ល្បីបំផុតរបស់លោកដូចជា :

- បន្ទប់លេខ ៦ ( la Salle n°6 ) សរសេរក្នុង ឆ្នាំ ១៨៩២
- បព្វជិតខ្មៅ ( le Moine noir ) សរសេរក្នុងឆ្នាំ ១៨៩៤

- បីឆ្នាំ ( Trois Années ) សរសេរក្នុងឆ្នាំ ១៨៩៥
- ដីការបស់អាណា ( l' Ordre d' Anna ) សរសេរក្នុងឆ្នាំ ១៨៩៦ ។

ក្នុងឆ្នាំ ១៨៩៦ រឿងល្ខោនមួយរបស់លោកឈ្មោះ " សត្វរំពេ " ( la Mouette ) ត្រូវទទួលបរាជ័យមួយយ៉ាងធំ ។ នៅពេលនោះ ការជុនដាបនៃការនឿយហត់ស្រុតកំលាំងរបស់លោក បានបង្ខំឱ្យលោកត្រូវតែស្វែងរកបរិយាកាសល្អប្រសើរមួយ ។ លោកឆេកូស បានទៅស្នាក់អាស្រ័យនៅទីក្រុងនីស ( Nice ) ធ្វើដំណើរទៅក្នុងប្រទេសអ៊ីតាលី ប្រទេសអាល្លឺម៉ាញ ហើយនិងបានជួបជាមួយសិល្បការិនី អុលហ្គា ឃ្នីពើ ( Olga Kniper ) ដែលសំដែងជាតួអារកាឌីណា ( Arkadina ) នៅក្នុងរឿង la Mouette ក្នុងសំណាក់លោក ស្តានីស្លាវស្គី ។ លោកឆេកូស បានរៀបអាពាហ៍ពិពាហ៍ជាសំងាត់ជាមួយនឹងនាងនេះ នៅក្នុងខែ ឧសភា នាឆ្នាំ ១៩០១ ក្រោយពេលដែលបានទៅស្នាក់នៅជាប់លាប់ក្នុងទីក្រុងយ៉ាល់តា ( Yalta ) ក្នុងឆ្នាំ ១៨៩៩ ក្រោមការឱ្យយោបល់ពីគ្រូពេទ្យទាំងឡាយរបស់លោក ។

# រស់នៅស្រលាញ់មិត្ត ប្ដូរជីវិតដើម្បីស្នាដៃឯក

ជំងឺមិនបានធ្វើឱ្យមានការអាក់ខានដល់លោក ឆេកូស ក្នុងការធ្វើការងារសោះទេ ! លោកឆេកូសនៅតែបន្តសរសេរ និវកថា ជាច្រើនទៀតដែលសុទ្ធតែអាចរាប់បញ្ចូលបានទៅក្នុងស្នាដៃឯករបស់លោក ដូចជា :

- Groseilles à maquereaux ( 1898 )
- l' Homme á l' étui ( 1898 )
- la Dame au petit chien ( 1899 )
- la Fiancée ( 1903 )

លោក ឆេកូស បានយកជីវិតទៅចូលរួមយ៉ាងសកម្មនៅក្នុងជំនាន់របស់លោក ។ លោកបានទទួលឱ្យចូលមកក្នុងគេហដ្ឋានរបស់លោកនូវជនល្បីៗទាំងឡាយដូចជា :

- លោក ប៊ូនីន ( Bounine )
- លោក កូរូឡេនកូ ( Korolenko )
- លោក គូព្រីន ( Kouprine )
- លោក ស្តានីស្លាវស្គី ( Stanislavski )

លោក ឆេកូស បានយកចិត្តទុកដាក់ទៅលើយុវជនហ្គរគី ( Gorki ) ហើយលោកបានសុំលាឈប់ពីតំណែងដូចគ្នានេះដែរពីបណ្ឌិតសភា កាលដែលស្តេចត្សារ ( le trar ) អធិរាជប្រទេសរុស្ស៊ីមានបំណងដករូបលោក Gorki ចេញ នៅក្នុងឆ្នាំ ១៩០២ ។

នៅក្នុងបណ្តាឆ្នាំចុងក្រោយបំផុតនៃជីវិតរបស់លោក លោកឆេកូស បានសរសេររឿងល្ខោនធំបីដ៏ល្បីល្បាញ ។ រឿងទាំងនោះគឺ :

- លោក ពូ វ៉ានីញ៉ា ( Oncle Vania ) សរសេរក្នុងឆ្នាំ ១៨៩៧
- បងប្អូនស្រីបីនាក់ ( les Trois soeurs ) សរសេរក្នុងឆ្នាំ ១៩០១
- ចំការសឺរីស ( la Cerisaie ) សរសេរក្នុងឆ្នាំ ១៩០៤

ក៏ប៉ុន្តែឆ្នាំនៃមហាជោគជ័យដ៏ល្បីនេះ ក៏គឺជាឆ្នាំនៃមរណភាពរបស់រូបលោកឆេកូសផងដែរ ! នៅពេលនោះ លោកឆេកូស គឺជាអ្នកនិពន្ធដ៏ល្បីល្បាញនៃ " សេចក្តីស្នេហាដ៏ផ្អែមល្ហែមរបស់ទីក្រុងមូស្គូ និង ទ្វីបអឺរ៉ុប " ។

## វណ្ណកម្មរបស់លោក ឆេកូស

វណ្ណកម្មរបស់លោក ឆេកូស អាចចែកចេញជាបីផ្នែកសំខាន់ៗ :

១. ផ្នែករឿងប្រឌិត :

- les Contes de Melpomène ( 1884 )
- Récits barrioles ( 1886 )
- l' Île de Sakhaline ( 1893-94 )

២. ផ្នែកនិទានកថា :

- la Steppe ( 1888 )
- la Salle n° 6 ( 1892 )
- le Moine noir ( 1894 )
- Trois Années ( 1895 )
- l'Ordre d'Anna (1895)
- la Maison à mezzanine ( 1896 )
- Groseilles à maquereaux ( 1898 )
- l' Homme á l' étui ( 1898 )
- la Dame du petit chien ( 1899 )
- la Fiancée ( 1903 )

## ៣~ ផ្នែករឿងល្ខោន :

- Ivanov ( 1887 )
- la Mouette ( 1896 )
- Oncle Vania ( 1897 )
- les Trois soeurs ( 1901 )
- la Cerisaie ( 1904 )

## ទស្សនៈរបស់លោក ឆេកូស

ភាពអស់សង្ឃឹម ភាពអាប់អួរ ទម្លាប់ធ្វើដដែលៗ ភាពមិនអាចទាក់ទងគ្នាបាន វាសនាមិនទាន់សំរេច សន្ទុះចិត្តគ្មានអានុភាពគឺមានតិចតួចតែប៉ុណ្ណោះ នៅក្នុងស្នាដៃរបស់លោកឆេកូស ។

លោក ឆេកូស បានរីតច្របាច់ការពិតនៃជីវិតឱ្យស្ថិតនៅក្នុងខ្លឹមនៃសោកនាដកម្មរបស់លោក ហើយសិល្បៈរបស់លោកបានបកស្រាយយ៉ាងសំងាត់នូវការរំភើបចិត្តមួយ នូវសេចក្តីតានតឹងចិត្តមួយ ដែលធ្វើឱ្យមានភាពទំនើបដល់នវកថាទាំងឡាយរបស់លោក និង ល្ខោនរបស់លោក ។ ទស្សនៈរបស់លោកឆេកូសចំពោះល្ខោន គ្មានឧបាយសំងាត់ ( sans intrique ) គ្មានសកម្មភាព ( sans action ) គ្មានផល ( sans effet ) ក៏ប៉ុន្តែគឺជាភាគនៃជីវិត កាត់ផ្តាច់នូវភាពស្ងៀមស្ងាត់ តបសងវិញយ៉ាងឆាប់

ជាក់ស្ដែងនូវឋិរវេលា និងសំណឹក ( érosion ) នៃពេលវេលា ធ្វើឱ្យសិល្បៈល្ខោន រំភើបយ៉ាងខ្លាំងក្លា ។

លោក ឆេកូស បានបង្កើតនូវគ្រប់ភាពខុសគ្នាបន្តិចៗនៃការរំភើបចិត្ត ហើយភាពអណ្ដែតអណ្ដូងនៅក្នុងនេះ គឺមិនអាចបំបែកបានពីសេចក្ដីលន្លង់លន្លោច និងទឹកចិត្តដែលមិនអាចបំបែកបានពីទេសភាព ។ ក៏ប៉ុន្តែក្នុងពេលដែលមានអំពើឃាតកម្មទៅលើមនុស្សម្នាក់ លោក ឆេកូស ជួនកាលក៏មើលឃើញស្រពិចស្រពិលផងដែរ នូវសេចក្ដីសង្ឃឹមនៃបឋមភាគនៃក្ដីសប្បាយរីករាយ... គឺនៅទីនោះហើយដែលមនុស្សទាំងឡាយមិនសូវមានចិត្តឃោរឃៅ មិនសូវមានគំនិតអត្តទត្ថបុគ្គល ហើយពួកគេនឹងកសាងសុភមង្គលរបស់ពួកគេ នៅលើជីវិតការងារ និង វិទ្យាសាស្ត្រមួយ ។

សិល្បៈរបស់លោក ឆេកូស នៅក្នុងនវកថាទាំងឡាយរបស់លោកក៏ដូចជានៅក្នុងរឿងល្ខោនរបស់លោកផងដែរ គ្មាននិទានកថា គ្មានពិពណ៌នា តែវាគឺជារឿងដែលបានធ្វើឱ្យរំជើបរំជួលតាមរយៈនៃការបណ្ដែហើយនិងធ្វើឱ្យរំភើបជាប់ចិត្តនឹងការចាប់អារម្មណ៍ ។

## កំណត់ចំណាំ :

- **Grigorovith** ( Iouri Nikolaïevitch ), danseur et choregraphe soviétique ( Leninegrad 1927 ) maître de ballet du Théâtre Bolchoï, auteur d' oeuvres à grande mise en scène ( Spartacus, 1968 [ en collab ] ; Ivan le Terrible, 1975 ).
- **Bounine** ( Ivan Alekseïevitch ) écrivain russe ( Voronej 1870-Paris 1953 ) fidèle du réalisme classique dans ses romans et ses nouvelles ( le Village, 1910 ) [ Prix Nobel 1933 ]
- **Korolenko** ( Vladimir Galaktionovitch ), écrivain russe ( Jitomir 1853-Polvata 1921 ), auteur de récits et d' une autobiographie, Histoire de mon contemporain ( 1906- 1922 )
- Stanislavski ( នឹងមានបោះពុម្ពនៅពេលក្រោយ )
- Gorki ( សូមអានទំព័របន្ទាប់ )



## ម៉ាក់ស៊ីម ហ្គរគី

Maxim Gorki ( Alekseï Maksimovitch Pechkov )

( Nijni Novgorod 1868-Moscou 1936 )

អ្នកនិពន្ធសូវៀត ។

វិចិត្រករប្រាកដនិយមនៃកុមារភាពដ៏សែនលំបាករបស់គាត់ដូចជា :

- Enfance ( 1913-14 )
- Parmi les hommes ( 1915-16 )
- Mes universités ( 1923 )

នៃ អនាថជន ហើយនិងជនដែលចាកចោលស្រុកកំណើត ដូចជា :

- Foma Gordeïev ( 1899 )
- les Bas-Fonds ( 1902 )

ហ្គរគី គឺជាអ្នកបង្កើតអក្សរសិល្ប៍សង្គមសូវៀត ។ ស្នាដៃខាងផ្នែកនេះរួមមាន :

- la Mère ( 1906 )
- les Artamonov ( 1925 )
- la Vie de Klin Samguine ( 1925-1936 )

# អាល្លឺម៉ង់ ស.វ ទី ១៩

( GERMANY NINETEENTH –CENTURY )

- ហ្សក ប៊ុយឆ្នើរ ( Georg Buechner )
- ហ្វ្រីដ្រីច ហែបបែល ( Friedrich Hebbel )
- រីឆាដ វ៉ាញ្ញេរ ( Richard Wagner )
- ហេ្សរហាត ហ៊ុបត្មាន់ ( Gerhart Hauptmann )



## ហ្សក ប៊ុយឆ្នើរ

Georg Buechner ( Büchner )

( Goddelau 1813 -Zurich 1837 )

កវីអាល្លឺម៉ង់ ។

ស្នាដៃល្ខោននាដកម្មទាំងឡាយរបស់គាត់ ត្រូវបានកត់សំគាល់ថាជាល្ខោនប្រភេទ " សំដែងនិយមទំនើប " ( expressionnisme modern ) ស្នាដៃទាំងនោះមានដូចជា :

- la Mort de Danton
- Woyzeck



## ហ្វ្រីដ្រិច ហេបបែល

Friedrich Hebbel

( Wesselburen 1813 - Vienne 1863 )

អ្នកនិពន្ធល្ខោនទាជកម្មអាល្លឺម៉ង់ ។

ជាអ្នកនិពន្ធរឿងល្ខោនអំណែតអណ្តូង ដូចជារឿង Judith និង ទ្រីឡូហ្សុី មួយនៃ Nibelungen ។



## រីឆាដ វ៉ាញេរ

Richard Wagner

( Leipzig 1813-Venise 1883 )

អ្នកតែងបទភ្លេងអាល្លឺម៉ង់ ។

ជាគ្រូនៃវិហារតូចនៃក្រុមព្រះរាជបរិពារ ដ្រេសដឺ ( Dresde ) ក៏ប៉ុន្តែគាត់បានភៀសខ្លួនទៅក្នុងប្រទេសស្វីស ( ១៨៤៩ - ១៨៦១ ) ដោយមូលហេតុពីគំនិតបដិវត្តរបស់គាត់ ។ វ៉ាញេរបានទទួលជំនួយពី ហ្វ.លីហ្សត៍ ( F.Liszt ) និងពី ល្វីសទី២ ( Louis II ) នៃបាវីយែរ ( Bavière ) ដើម្បីដំណើរការស្នាដៃរបស់គាត់ឱ្យបានល្អប្រសើរ ដែលក្នុងនោះមានដូចជា :

- le Vaisseau fantôme ( 1841 )
- Tannhäuser ( 1845 )
- Lohengrin ( 1850 )
- l' Anneau du Nibelung, dit la Tétralogie ( 1852-1876 )
- Tristan et Isolde ( 1865 )

- les Maîtres chanteurs de Nuremberg ( 1868 )
- Parsifal ( 1876-1882 )

វ៉ាញេរ បានលះបង់នូវលំអសាំញ៉ាំទាំងឡាយនៃសំឡេង និង អត្តសិល្បិនភាព ( ការស្ទាត់ជំនាញខាងសិល្បៈ ) និងបានធ្វើឱ្យមានសកម្មភាពខ្លាំងឡើងនូវការចូលរួមនៃវង់ភ្លេង ដោយបានផាត់ចោលនូវទម្រង់ល្ខោនអូប៉េរ៉ា អ៊ីតាលី ។

ជាជនដែលពាក់ព័ន្ធទៅនឹងល្ខោនទេវកថាមួយ ( គាត់បានដកស្រង់កូនសៀវភៅទាំងឡាយរបស់គាត់នៅក្នុងរឿងព្រេងនិទាន នៃប្រទេសអាល្លឺម៉ាញ ) ទេវកថាពិត ហើយនិងនិមិត្តរូបនិយម គាត់បានសំរេចនូវការរំលាយបញ្ចូលគ្នាមួយយ៉ាងជិតស្និទ្ធ រវាងអត្ថបទ និង តន្ត្រី នូវភាពសមពីរោះដ៏សប្បាយរីករាយមួយរវាងសំលេង និង ឧបករណ៍ទាំងឡាយ ហើយនិងនូវអង្គឯកភាពនៃវិទ្យានិពន្ធដ៏ស៊ីជំរៅមួយ ដោយសារតែការប្រើប្រាស់វា ដែលរូបគាត់បានធ្វើនូវឃ្លា ឬរូបមន្តស្រដែល ( leitmotiv ) ។



## ហេរ្សហាត ហ៊ុបត្មាន់

Gerhart Hauptmann

( Bad Salzbrunn 1862 -Agnetendorf 1946 )

អ្នកនិពន្ធអាល្លឺម៉ង់ ។

ជាអ្នកនិពន្ធរឿងល្ខោនទាជកម្មប្រាកដនិយម ដូចជា :

- les Tisserands ( 1892 )

le Roulier Henschel ( 1898 )

ហើយក្រៅពីនេះ ហ៊ុបត្មាន់ ក៏មានសរសេរកំណាព្យវីរកថាផងដែរ។

ទទួលរង្វាន់ណូបែល ( Prix Nobel ) ក្នុងឆ្នាំ ១៩១២ ។

# ល្ខោនសម័យទំនើប
# អង់គ្លេស និង អៀរឡង់ដ៍

( THE MODERN THEATRE ENGLAND & IRELAND )

- អូស្ការ វីលដ៍ ( Oscar Wilde )
- ហ្សក ប៊ែរណារដ៍ ស្យូវ ( Georg Bernard Shaw )
- វីលៀម ប៊ុត្លើ យៀតស៍ ( William Butler Yeats )
- ជ្យន មីលីងតុន ស៊ីងហ្ស ( Jhon Millington Synge )
- សៀន អូកាសេយ៍ ( Sean O'Casey )
- ជ្យន អូស៊ប៊ៀន ( John Osborne )
- ហារ៉ូលដ៍ ពីនធើរ ( Harold Pinter )



## អូស្ការ វីលដ៍

Oscar Wilde ( Orcar Fingal O'Flahertie Wills )

( Dublin 1854 -Paris 1900 )

អ្នកនិពន្ធអៀរឡង់ស៍ ។

និកាយព័ន្ធនៃអេស្តេទីស្ម ( esthétisme ) អូស្ការ វីលដ៍ មានឈ្មោះល្បីល្បាញតាមរយៈតួអង្គរបស់គាត់ ក៏ដូចជាតាមរយៈស្នាដៃរបស់គាត់ ដែលក្នុងនេះមានដូចជា ៖

ផ្នែករឿងប្រឌិត ៖

- le Crime de lord Arthur Saville

ផ្នែករឿងល្ខោន ៖

- l' Évantail de lady Windemere ( 1892 )
- De l' importance d' être constant ( 1895 )

ផ្នែករឿងប្រលោមលោក ៖

- le Portrait de Dorian Gray ( 1891 )

អូស្ការ វីលដ៍ បានត្រូវជាប់ឃុំឃាំងដោយសារបញ្ហាទំនៀមទំលាប់មួយ ៖

- Ballade de la géôle de Reading ( 1898 )

ហើយបន្ទាប់មក គាត់ក៏បានទៅនៅក្នុងប្រទេសបារាំងវិញ ។



## ហ្សក ប៊ែរណារដ៍ ស្សូវ

George Bernard Shaw

( Dublin 1856 -Ayot Saint Lawrance,Hertfordshire, 1950 )

អ្នកនិពន្ធអៀរឡង់ដ៏ ។

ជាអ្នកនិពន្ធរឿងប្រលោមលោក អ្នកនិពន្ធល្បង និងជាអ្នកនិពន្ធរឿងល្ខោនដូចជា :

- le Héros et le Soldat ( 1894 )
- Pigmalion ( 1913 )
- Sainte Jeanne ( 1923 )

រឿងទាំងអស់នេះ សុទ្ធសឹងតែបញ្ចេញឱ្យឃើញនូវការកំប្លែងស្លូត និង ទុទិដ្ឋិនិយមរបស់គាត់ ។

ស្សូវ បានទទួលរង្វាន់ណូបែល នៅឆ្នាំ ១៩២៥ ។



## វីល្លៀម ប៊ុត្លើ យៀតស៍
William Butler Yeats

( Sandymount 1865-Roquebrune-Cap-Martin 1939 )

អ្នកនិពន្ធអៀរឡង់ដ៏ ។

សហស្ថាបនិកល្ខោនអាប់បេយ៍ ( Abbey Théâtre ) ។ ជាអ្នកនិពន្ធល្បង កំណាព្យកាព្យឃ្លោង និង រឿងល្ខោននាដកម្ម ដូចជា :

- la Comtesse Kathleen ( 1892 )
- Deirdre ( 1907 )

ស្នាដៃទាំងអស់របស់គាត់ សុទ្ធសឹងតែយកគំនិតមកពី "គំនិតជាតិ" ( l' esprit national ) ។ វីល្លៀម ប៊ុត្លើ យៀតស៍ បានទទួលរង្វាន់ណូបែល នៅឆ្នាំ ១៩២៣ ។



## ជ្យន មីលីងតុន ស៊ីងហ្ស
Jhon Millington Synge

( Rathfarnham **1871-Dublin** 1909 )
អ្នកនិពន្ធល្ខោននាដកម្ម អៀរឡង់ដ៍ ។

ល្ខោននាដកម្មរបស់គាត់ បានបញ្ចូលនូវវិទ្យានិពន្ធស្ដីអំពីទំនៀមទំលាប់នៃការប្រតិបត្តិតាមបញ្ញត្តិប្រាកដនិយម នៃជីវិតប្រចាំថ្ងៃរបស់បណ្ដាជននៅក្នុងខេត្ត ។

ស្នាដៃរបស់គាត់មានដូចជា :

- le Baladin du monde occidental ( 1907 ) ។



## សៀន អូកាសេយ៍

Sean O'Casey

( Dublin 1880-Torquay, Devon, 1964 )

អ្នកនិពន្ធល្ខោននាដកម្មអៀរឡង់ស៍ ។

ល្ខោនរបស់គាត់ដែលសរសេរអំពីបញ្ហានយោបាយ និង បញ្ហាសង្គមរបស់ប្រទេសគាត់ ដូចជារឿង :

- la Charrue et les Étoiles ( 1926 )
- la Coupe d'argent ( 1929 )

តមកបានតម្រង់ទិសឆ្ពោះទៅរកការសម្តែង តាមបែបនិមិត្តរូបនិយមមួយនៃជីវិត ។ ស្នាដៃនេះមានដូចជា :

- Roses rouges pour moi ( 1946 ) ។



ជូន អូស្បិន
John Orborne

( Londres b.1929 )
អ្នកនិពន្ធអង់គ្លេស ។

ជាមេខ្លោង (chef de file ) នៃ « Jeunes Gens en colère » ។
ស្នាដៃរបស់គាត់មានដូចជា :

- la Paix du dimanch ( 1956 )
- Témoignage irrecevable ( 1964 )



# ហារ៉ុលដ៍ ពីនធើរ

Harold Pinter

( Londres 1930 ឬ 1932 ? )

សិល្បករ និង ជាអ្នកនិពន្ធល្ខោននាដកម្ម អង់គ្លេស ។ រឿងល្ខោនរបស់គាត់មានដូចជា :

- le Gardien ( 1960 )
- la Collection ( 1962 )
- le Retour ( 1965 )

ហើយដែលរឿងល្ខោនទាំងនេះ បានបញ្ចេញឱ្យឃើញនូវភាពពិបាកក្នុងការទាក់ទងជាមួយនឹងជនដទៃនៅក្នុងពិភពលោកសម័យថ្មីនោះ បានធ្វើឱ្យលេចចេញជារូបរាងឡើងនូវ " ល្ខោន អាប់សៀដ " ដ៏ល្បីល្បាញ ( Théâtre de l' absurde ) ។

# ល្ខោនសម័យទំនើប
# អាល្លឺម៉ង់ និង ស្វីតហ្ស៊ែឡង់ដ៍

( GERMANY AND SWITZERLAND )

- ហ្វ្រាង់ក៍ វេដឺគីនដ៍ ( Frank Wedekind )
- បែរតុលត៍ ប្រិច្ឆត៍ ( Bertolt Brecht )
- ម៉ាក់ ហ្វ្រីស្ឆ ( Max Frisch )
- ហ្វ្រីដ្រិច ឌុយរ៉ែនម៉ាត់ ( Friedrich Duerrenmatt )



## ហ្វ្រង់ក៍ វ៉េដឺគីនដ៍
Frank Wedekind

( Hanovre 1864 -Munich 1918 )

អ្នកនិពន្ធល្ខោននាដកម្មអាល្លឺម៉ង់ ។

ហ្វ្រង់ក៏ វ៉េដឺគីនដ៏ គឺជាអ្នកតំណាងដ៏ល្បីបំផុតម្នាក់នៃ " សំដែងនិយម " ( expressionnisme ) ។

ស្នាដៃរបស់គាត់មានដូចជា :

- l' Éveil du printemps ( 1891 )
- la Danse de mort ( 1906 )



## ប៊ែរតុលត៍ ប្រិច្ឆត៍

Bertolt Brecht

( Augsbourg 1898 - Berlin - Est 1956 )

អ្នកនិពន្ធល្ខោននាដកម្មអាល្លឺម៉ង់ ។

ជាកវី ដូចជាស្នាដៃ : Élégies de Buckow និង ជាអ្នកនិពន្ធរឿងប្រឌិតដូចជា : Histoires de calendrier ។ ប្រិច្ឆត៍មានឈ្មោះល្បីល្បាញ ដោយសារគាត់បានបង្កើតឡើងនូវភាពផ្ទុយគ្នានៃល្ខោនប្រពៃណី ដែលទស្សនិកជនមានមនោសញ្ចេតនាដូចជាវីរបុរស គឺ " ល្ខោនវីរកថា " ( Théatre épique ) ដែលបង្គាប់សិល្បករឱ្យសំដែងឡើងនូវតួអង្គរបស់ខ្លួន ដោយមិនឱ្យមានការច្រឡូកច្រឡំជាមួយនឹងខ្លួនឯង ( នេះគឺជា " លក្ខណៈនៃភាពខុសគ្នាឆ្ងាយ " effet de distanciation [1] ) ហើយទស្សនិកជនមានភារៈលើកឡើងនូវរបៀបមើលរិះគន់ទៅលើសាច់រឿង និងទីដៅ ( objectif ) ដែលធ្វើឱ្យមានការស្រុះស្រួលតាមធម្មតានៃការពិត ។

ស្នាដៃទាំងឡាយរបស់ប្រិច្ឆត៍មានដូចជា :

- l' Opéra de quat ' sous ( 1928 )
- Mère Courage et ses enfants ( 1941 )
- Maître Puntila et son valet Matti ( 1948 )
- le Cercle de craie caucasien ( 1948 )
- la Résistible Ascension d'Arturo Ui ( 1959 )

ប្រិច្ចត៏ បានបង្កើត និងបានដឹកនាំក្រុមល្ខោនបែរលីណេអង់សមប្លឺស ( la troupe du Berliner Ensemble ) នៅក្នុងឆ្នាំ ១៩៤៩ ។



## ម៉ាក់ ហ្រ្វីស្ហ
Max Frisch

( Xurich 1911 -id.1991 )

អ្នកនិពន្ធស្វីស ។

ជាអ្នកនិពន្ធរឿងប្រលោមលោក និងរឿងល្ខោន ដែលបានធ្វើឱ្យគេស្គាល់មុខតាមរយៈលោកប្រិច្ចត៍ និងតាមរយៈអត្ថិភាពនិយម ( existen - tialisme ) ។

ស្នាដៃរបស់គាត់មានដូចជា :

- Biedermann et les incendiaires
- Andorra



## ហ្វ្រីដ្រិច ឌុយរ៉េនម៉ាត់

Friedrich Duerrenmatt ( Dürrenmatt )

( Konolfingen, Berne, 1921-Neuchâtel 1990 )

អ្នកនិពន្ធស្វីស ។

មនសិការប្រូតេស្តង់ ហើយនិងការកំប្លែងស្ងួតដ៏ចំលែករបស់គាត់ បានបូកបញ្ចូលគ្នាជាស្នាដៃនៅក្នុងល្ខោនរបស់គាត់ និងដោយមានភ្ជាប់ទៅនូវការរិះគន់ជាប់ជានិច្ចមួយនៃមាយាការ និងការសង្កត់សង្កិននៃមនុស្ស ។

ស្នាដៃរបស់គាត់មានដូចជា :

- Un ange vient à Babylone
- la Visite de la vieille dame

# ល្ខោនសម័យទំនើប
# អ៊ីតាលី និង អេស្ប៉ាញ

( ITALY AND SPAIN )

- លូអ៊ីហ្ស៊ី ពីរ៉ង់ដែឡូ ( Luigi Pirandello )
- ហ្វេដេរីកូ ហ្គាស៊ា លរកា ( Federico Garcia Lorca )



## លូហ្ស៊ី ពីរ៉ង់ដែឡូ
Luigi Pirandello

( Agrigente 1867 -Rome 1936 )

អ្នកនិពន្ធ អ៊ីតាលី ។

ជាអ្នកនិពន្ធរឿងប្រលោមលោក នវកថាក្នុងប្រពៃណីនៃវេរីស្ម ( vérisme ) ដូចជា : l' Exclue ( 1901 ) ។ នៅក្នុងល្ខោនរបស់គាត់ ពីរ៉ង់ដែឡូ បានចង្អុលបង្ហាញនូវបុគ្គលិកលក្ខណៈមនុស្ស បំបែកចេញទៅជាមុខតូចៗ ហើយនិងគំនិតផ្ទុយគ្នាទាំងឡាយ មិនអាចនឹងរៀបចំ ផ្សំបង្កើតឡើងវិញបានដោយសមហេតុផល ។

ស្នាដៃរបស់គាត់មានដូចជា :

- Chacun sa vérité ( 1917 )
- la Volupté de l'honneur ( 1917 )
- Six personages enquête d'auteur ( 1921 )
- Ce soir on improvise ( 1930 )

លោក ពីរ៉ង់ដែឡូ បានទទួលរង្វាន់ណូបែលនៅឆ្នាំ ១៩៣៤ ។



## ហ្វេដេរីកូ ហ្គារស្យា លរកា

Federico Garcia Lorca

( Fuente Vaqueros 1898-Viznar 1936 )

អ្នកនិពន្ធ អេស្ប៉ាញ៉ុល ។

ជាអ្នកនិពន្ធកំណាព្យដូចជា :

- Romancero gitan ( 1928 )

និងជាអ្នកនិពន្ធរឿងល្ខោន ដូចជា :

- Noces de sang ( 1933 )
- Yerma ( 1934 )
- la Maison de Bernarda ( 1936 )

ហ្គារស្យា ល័រកា ត្រូវបានគេបាញ់សំលាប់ដោយកាំភ្លើង នៅក្នុងពេលសង្គ្រាមស៊ីវិល ដោយពួក ហ្វ្រង់គីស្ត ( franquiste ) ។

# ល្ខោនសម័យទំនើប

## បារាំង ( FRANCE )

- មីស្សែល ដឺ ហ្គែលដឺរ៉ូដ ( Michel de Gheldерode )
- ហ្សង់ ប៉ូលសាត្រ ( Jean-Paul Sartre )
- សាមូអែល បិកេត ( Samuel Beckette )
- ហ្សង់ ហ្សឺណេត ( Jean Genet )
- ហ្សង់ អានូយ ( Jean Anouilh )
- អឺហ្សែន អ៊ីយូណេស្កូ ( Eugène Ionesco )



## មីសែ្សល ដឺ ហ្គែលដឺរ៉ូដ

Michel de Ghelderode

( Ixelles 1898 -Schaerbeek 1962 )

អ្នកនិពន្ធបែលហ្ស៊ីក ។

ល្ខោនបែបសំដែងនិយមរបស់លោក ហ្គែលដឺរ៉ូដ បានរួមបញ្ចូលគ្នាជាមួយនឹងហាសនាដកម្ម ( farce ) នៃបុណ្យការណាវ៉ាល់ ដែលនិយមកាន់សាសនាតឹងទៅនឹងពិធីស្ល័យប្រសិទ្ធិ ។

ស្នាដៃរបស់លោក ម.ហ្គែលដឺរ៉ូដ មានដូចជា :

- Barrabas (1929 )
- Fastes d' enfer ( 1949 )
- Mademoiselle Jaïre ( 1949 )



## ហ្សង់ ប៉ូលសាត្រ

Jean-Paul Sartre

( Paris 1905 -id.1980 )

ទស្សនវិទូ និងជាអ្នកនិពន្ធបារាំង ។

កត់សំគាល់តាមរយៈបាតុភូតវិទ្យា និងតាមរយៈលោក Martin Heidegger ( ទស្សនវិទូអាល្លឺម៉ង់ ១៨៨៩-១៩៧៦ ) ទស្សនវិជ្ជារបស់លោក សាត្រ ត្រូវបានគេទទួលស្គាល់នូវ ទិស្សមានាការ ( phase ) ពីរដោយគ្មានការផ្តាច់ទៅនូវកាលប្រវត្តិដ៏ជាក់ច្បាស់ :

ទីមួយ-ដឹកនាំឆ្ពោះទៅលើ អត្ថិភាពនិយម ( existentialisme ) រាប់អានសេរីភាពទុកដូចជាមូលដ្ឋាននៃជីវិតសត្វលោក មនុស្ស ហើយនិងការពិពណ៌នានៃអត្ថិភាពរបស់គេ ទុកដូចជាការប្រយុទ្ធប្រកបដោយសីលធម៌មួយរវាងសេរីភាពនេះ ហើយនិងការមិនព្រមព្រៀងរបស់គេ ការគេចវេះពីធម្មជាតិ ដោយសារតែជំនឿអាក្រក់ចង្រៃជាដើម ។

ទីពីរ-យកគំនិតមកពីសម្ភារៈនិយមវិចារវិទ្យា ( matérialisme dialectique ) ហើយនិងអួតសរសើរនូវកិច្ចសន្យា ដូចជាការប្រព្រឹត្តត្រឹមត្រូវតាមច្បាប់ដោយឯកឯងរបស់មនុស្ស ។ គំនិតនេះមានទៅក្នុង

ស្នាដៃរបស់គាត់គឺ : Critique de la raison dialectique ( 1960-1985 ) ។ ភាពពុំអាចប្រព្រឹត្តបាននៃការសម្រុះសម្រួលកិច្ចសន្យាសង្គម ( engagement social ) និងយថាភាពផ្ទាល់ខ្លួន បានធ្វើឱ្យលោកសាត្រ តប់ប្រមល់នៅក្នុងជីវិតរបស់គាត់ ដូចជានៅក្នុងតួឯកប្រុសរបស់គាត់ផងដែរ ។ លោក សាត្រ បានធ្វើអត្ថាធិប្បាយនូវគោលគំនិតទាំងឡាយរបស់គាត់នៅក្នុងរឿងប្រលោមលោក ដូចជារឿង :

- la Nausée ( 1938 )
- les Chemins de la liberté ( 1945-1949 )

នៅក្នុងវិនាដកម្មទាំងឡាយមានដូចជា :

- Huis clos ( 1944 )
- les Mains sales ( 1948 )
- le Diable et le Bon Dieu ( 1951 )

បែបនវកថា ដូចជារឿង : le Mur

បែបនិពន្ធល្បង ដូចជា : Situations ( 1947–1976 )

បែបរឿងនិទានស្វ័យជីវប្រវត្តិមួយ : les Mots ( 1964 )

បែបសិក្សាកថាមួយ អំពីលោក Flaubert : l' Idiot de la famille.

នៅក្នុងឆ្នាំ ១៩៦៤ លោកសាត្រ បានបដិសេធរង្វាន់ណូបែលខាងផ្នែកអក្សរសិល្ប៍ ។

ក្រោយមរណភាពរបស់លោក គេឃើញមានបោះពុម្ពផ្សាយនូវស្នាដៃមួយចំនួនដូចជា :

- Cahiers pour une morale ( 1983 )
- Carnets de la drôle de guerre ( 1983 ) និង
- Vérité et Existence ( 1989 )



**សាមូអែល បិកេត**

Samuel Beckette

( Foxrock,près de Dublin, 1906-Paris,1989 )

អ្នកនិពន្ធអៀរឡង់ដ៏ ។

ជាអ្នកនិពន្ធ ( ជាភាសាអង់គ្លេស បន្ទាប់មកជាភាសាបារាំង ) រឿងប្រលោមលោកដូចជា : Molloy, Watt ហើយនិងរឿងល្ខោន ដែលសម្តែងពីភាពមិនទំនងនៃលក្ខណៈសម្បត្តិមនុស្ស ( absurdité de la condition humaine ) ។

ស្នាដៃរបស់គាត់មានដូចជា :

- En attandant Godot ( 1953 )
- Fin de partie ( 1957 )
- Oh les beaux jours ( 1963 )

បិកេត បានទទួលរង្វាន់ណូបែលនៅឆ្នាំ ១៩៦៩ ។



## ហ្សង់ ហ្សឺណេត

Jean Genet

( Paris 1910 – id.1986 )

អ្នកនិពន្ធបារាំង ។

ស្នាដៃរឿងប្រលោមលោករបស់គាត់មានដូចជា :

- Notre-Dame-des-Fleurs ( 1944 )

ស្នាដៃកំណាព្យ និង ល្ខោន មានដូចជា :

- les Bonnes ( 1947 )
- le Balcon ( 1956 )
- les Paravents ( 1961 )

ស្នាដៃទាំងឡាយរបស់លោក ហ្សឺណេត សុទ្ធតែបានរំលឹកឱ្យឃើញនូវយុវភាពរបស់គាត់ ដែលត្រូវបានបោះបង់ នូវភាពជាទាសករ និងនូវការជឿលត្ថះចំពោះការលាក់ពុតទាំងឡាយនៃមនុស្សស្រុកករ ។



## ហ្សង់ អានូយ

Jean Anouilh

( Bordeaux 1910 -Lausanne 1987 )

អ្នកនិពន្ធល្ខោននាដកម្មបារាំង ។

ល្ខោនរបស់លោក ហ្សង់ អានូយ បានផ្តើមចេញមកពីរឿងល្ខោន មនោរិកតិ " ផ្កាកូលាប " ដូចជារឿង le Bal des voleurs និងពីរឿង កំប្លែងស្ងួត " ពន្លឺរស្មី " ឬ " សំលៀកបំពាក់ " ដូចជារឿង : la Répétition ou l' Amour puni, l' Alouette និងអំពីរឿងល្ខោន ដៀលត្មះ " ភាពកោងឈ្លើយ " ដូចជារឿង : Pauvre Bitos ou le Dîner de têtes " មនុស្សក្រមាច់ " ដូចជារឿង : le Nombril ហើយ និងរឿងល្ខោនទុទិដ្ឋិនិយម " ខ្មៅងងឹត " ដូចជារឿង : Antigone ។



## អឺហ្សែន អ៊ីយូណេស្កូ
Eugène Ionesco

( Slatina b.1912 )

អ្នកនិពន្ធបារាំង មានដើមកំណើតរ៉ូម៉ានី ។

ល្ខោនរបស់ អ៊ីយូណេស្កូ បានបញ្ចេញឱ្យឃើញនូវ " ភាពមិនទំនងនៃអត្ថិភាព " ( absurdité de l' existence ) ហើយនិងការទាក់ទងគ្នានៃសង្គម ។ ស្នាដៃទាំងនោះមានដូចជា :

- la Cantatrie chauve ( 1950 )
- la Leçon ( 1951 )
- les Chaises ( 1952 )

ចំណែកឯស្នាដៃផ្សេងទៀត គឺជាស្នាដៃដែលបានកាត់បញ្ចូលទៅនូវការត្រាប់កំប្លែងជាសាកលមួយ ហើយនិងនិមិត្តរូបនិយម ។ ស្នាដៃទាំងនោះមាន :

- Rhinocéros ( 1960 )
- le Roi se meurt ( 1962 )
- le Piéton de l' air ( 1963 )
- la Soif et la Faim ( 1966 )

# ល្ខោនសម័យទំនើប

## អាមេរិក ( AMERICA )

- អឺហ្សេន អូនីល ( Eugene O'Neill )
- ថនតុន វ៉ីលដឺរ ( Thornton Wilder )
- តេណេសសេ វីល្យៀមស៍ ( Tennessee Williams )
- អាធ្ធួរ មីឡើរ ( Arthur Miller )



## អឺហ្សេន អូនីល

Eugene O'Neill

( New York 1888 -Boston 1953 )

អ្នកនិពន្ធរឿងល្ខោននាដកម្មអាមេរិកាំង ។

ល្ខោនរបស់លោក អូនីល បានឆ្លងពីប្រាកដនិយម ដូចជារឿង :

- Anna Christie ( 1922 )
- le Désir sous les ormes ( 1924 )

ទៅកាន់មនោភាពនៃការរវើរវាយ ដែលធ្វើឱ្យរំភើបដោយប្រពលនៃមនុស្សជាតិ ដើម្បីរួមបញ្ចូលទៅក្នុងពិភពលោក ដូចជារឿង : l' Empereur Jones ( 1921 ) ដែលគ្រប់គ្រងសត្វលោក ជាពិសេសដែលអាចនឹងទទួលខុសត្រូវលើជោគវាសនារបស់ពួកគេ ដូចជារឿង : Le deuil sied à Électre ( 1931 ) ។

លោក អូនីល បានទទួលរង្វាន់ណូបែលនៅឆ្នាំ ១៩៣៦ ។



## ថនតុន វីលដឺរ

Thornton Wilder ( Thornt
Niven )

( Madison, Wisconsin 1897
Hamden, Connecticut 1976 )

អ្នកនិពន្ធអាមេរិកកាំង ។

ជាអ្នកនិពន្ធរឿងប្រលោមលោក និង រឿងល្ខោនដែលបានធ្វើវិភា
ធម្មជាតិ និង ជោគវាសនានៃតំលៃប្រាជ្ញាស្មារតី ។ ស្នាដៃរបស់គាត់មានដូ
ជា :

- Notre petite ville

## ឯកសារយោង ( Reference )


- WORLD BOOK ( 1999 )
- The World of the Theatre ( 1979 )
  ( ROBERT W.CORRIGAN )
- LE PETIT LAROUSSE EN COULEURS
  (1995 )

UNESCO
CAMBODIA

First Printing Sponsored by
UNESCO/Japan Funds-in-Trust
January 2002
500 Copies